ក្រសួងអប់រំ យុវជន និង កីឡា

១៦ សេចក្តីថ្លែងការណ៍អនុសញ្ញាអន្តរជាតិ និងរូបភាពពលកម្មកុមារ

បញ្ឈប់ពលកម្មកុមារ

ការពារសិទ្ធិកុមារតាមរយៈការអប់រំ_សិល្បៈ និងប្រព័ន្ធផ្សព្វផ្សាយ

នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

អង្គការពលកម្មអន្តរជាតិ

២០០៣

ស្តីមបញ្ឈប់ពលកម្មកុមារ !

សេចក្តីថ្លែងការណ៍ និងអនុសញ្ញាអន្តរជាតិ

បញ្ជីអត្ថបទ

១-សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស

២-អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ

៣-អនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ ១៣៨

៤-អនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ១៨២

៥-សេចក្តីថ្លែងការណ៍របស់អង្គការពលកម្មអន្តរជាតិស្តីពីគោលការណ៍
និងសិទ្ធិជាមូលដ្ឋាននៅ កន្លែងការងារ ។

១.សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស

នៅថ្ងៃទី១០ ធ្នូ ១៩៤៨ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័ត និងប្រកាសសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្សដែលអត្ថបទទាំងស្រុងមាននៅក្នុងទំព័រជាបន្ទាប់ខាងក្រោម ។ សេចក្តីសម្រេចនៃមហាសន្និបាត ដែលមានសារៈសំខាន់ជាប្រវត្តិសាស្ត្រនេះបានបង្គាប់ឱ្យប្រទេសទាំងអស់ជាសមាជិកប្រកាសផ្សព្វផ្សាយជាសាធារណៈនូវខ្លឹមសារនៃសេចក្តីថ្លែងការណ៍នេះ និងធ្វើឱ្យមានការផ្សព្វផ្សាយការបង្ហាញ និងអានជាពិសេសនៅក្នុងសាលារៀន និងស្ថាប័នអប់រំដទៃទៀតដោយពុំមានភាពខុសគ្នាផ្អែកលើស្ថានភាពនយោបាយនៃប្រទេស ឬតំបន់ទាំងនោះ ។

បុព្វកថា

ដោយការទទួលស្គាល់នូវសេចក្តីថ្លៃថ្នូរដែលមានទីតាំងពីកំណើត និងសិទ្ធិស្មើភាពគ្នាដែលមិនអាចផ្តាច់ចេញបាននៃគ្រប់សមាជិករបស់នៃគ្រួសារគឺជាគ្រឹះនៃសេរីភាពយុត្តិធម៌ និងសន្តិភាពក្នុងពិភពលោក ។

ដោយហេតុថាការមិនយកចិត្តទុកដាក់ និងមិនគោរពសិទ្ធិមនុស្សគឺជាហេតុបណ្តាលឱ្យមានអំពើឃោរឃៅព្រៃផ្សៃ ដែលជាការប្រមាថបំពានទៅលើសម្បៈជញ្ជៈរបស់មនុស្សជាតិ និងការមកដល់នៃពិភពលោកដែលមនុស្សចាប់ផ្តើមទទួលនូវសេរីភាពក្នុងការនិយាយស្តី និងជំនឿ និងរួចផុតពីការភ័យខ្លាច ហើយចង់បានការប្រកាសថានោះគឺជាបំណងប្រាថ្នាដ៏ខ្ពស់បំផុតរបស់មនុស្សទូទៅ ។

ដោយហេតុថា ជាការសំខាន់ណាស់ប្រសិនបើមនុស្សពុំមានមធ្យោបាយដោះស្រាយបញ្ហាទៅតាមផ្លូវច្បាប់ដែលដំណោះស្រាយចុងក្រោយទៅដល់ការបះបោរប្រឆាំងនឹងអំណាចផ្តាច់ការជិះជាន់សង្កត់សង្កិននោះ សិទ្ធិមនុស្សត្រូវបានការពារដោយវិធានការណ៍ច្បាប់ ។

ដោយហេតុថា ជាការចាំបាច់ណាស់ក្នុងការធ្វើឱ្យមានការអភិវឌ្ឍន៍នូវទំនាក់ទំនងជាមិត្តភាពរវាងប្រជា ជាតិ (រដ្ឋ) និងប្រជាជាតិ ។

ដោយហេតុថា ប្រជាជនទាំងឡាយនៃអង្គការសហប្រជាជាតិបានអះអាងបញ្ជាក់ជាថ្មីនៅក្នុងធម្មនុញ្ញនូវជំនឿជាក់ច្បាស់របស់ខ្លួនក្នុងសិទ្ធិជាគ្រឹះរបស់មនុស្សនៅក្នុងសេចក្តីថ្លៃថ្នូរ និងតម្លៃរបស់បុគ្គល និងសិទ្ធិស្មើភាពគ្នារវាងបុរសនិងស្ត្រី ហើយប្តេជ្ញាជំរុញវឌ្ឍនសង្គម និងលក្ខខណ្ឌនៃជីវិតរស់នៅឱ្យកាន់តែប្រសើរក្នុងសេរីភាពមួយកាន់តែទូលាយជាង ។

ដោយហេតុថារដ្ឋជាសមាជិកបានសន្យាថានឹងធ្វើឱ្យបានសម្រេចក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិក្នុងការជំរុញនូវការគោរព និងការប្រតិបត្តិជាសកលនូវសិទ្ធិមនុស្ស និងគ្រឹះនៃសេរីភាព ។

ដោយហេតុថា ការយល់ដឹងជាសកលអំពីសិទ្ធិ និងសេរីភាពនេះគឺមានសារៈសំខាន់បំផុតក្នុងការធ្វើឱ្យសម្រេចទាំងស្រុងនូវការសន្យានេះ ។

ដូច្នេះ នៅពេលនេះមហាសន្និបាតបានប្រកាសសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្សនេះ លក្ខខណ្ឌនៃការធ្វើឱ្យសម្រេចសម្រាប់មនុស្ស និងប្រជាជាតិ(រដ្ឋ)ទាំងអស់ក្នុងគោលដៅដែលបុគ្គលគ្រប់ៗរូប និងគ្រប់អង្គការសង្គមធ្វើការ រក្សាសេចក្តីថ្លែងការណ៍នេះយ៉ាងខ្ជាប់ខ្ជួនក្នុងចិត្ត និងខិតខំប្រឹងប្រែងដោយការបណ្តុះបណ្តាល និងអប់រំ និងដោយវិធានការណ៍ប្រកបដោយវឌ្ឍនភាពជាតិ និងអន្តរជាតិក្នុងការជំរុញនូវការគោរពសិទ្ធិ និងសេរីភាពទាំងនេះ ដើម្បីធ្វើឱ្យមានការ ធានានូវការទទួលស្គាល់ និងការប្រតិបត្តិជាសកល និងប្រកបដោយប្រសិទ្ធភាពទាំងចំពោះប្រជាជាតិនៃរដ្ឋជាសមាជិកខ្លួន ឯងផ្ទាល់ និងទាំងប្រជាជននៃទឹកដីដែលនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ។

មាត្រា១

មនុស្សគ្រប់រូបដែលកើតមកគឺមានតម្លៃ និងសិទ្ធិស្មើគ្នាតាំងពីកំណើត ។ ពួកគេត្រូវបានផ្តល់នូវវិចារណញ្ញាណ និងសម្បៈជញ្ញៈ នឹងប្រតិបត្តិឆ្ពោះទៅរកស្មារតីនៃភាតរភាពថែមទៀត ។

មាត្រា២

មនុស្សគ្រប់រូបត្រូវតែទទួលបាននូវសិទ្ធិ និងសេរីភាពទាំងឡាយដែលមានចែងក្នុងសេចក្តីថ្លែងការណ៍នេះ ដោយពុំមានបែងចែកភាពខុសគ្នារវាងពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា នយោបាយ ឬទស្សនៈផ្សេងៗ សញ្ជាតិ ឬប្រភពនៃសង្គម ទ្រព្យសម្បត្តិកំណើត ឬ លក្ខខណ្ឌផ្សេងៗនោះឡើយ។ ម្យ៉ាងទៀត ពុំមានធ្វើការបែងចែងភាពខុសគ្នា នៅលើមូលដ្ឋាននៃនយោបាយ អំណាចច្បាប់ ឬស្ថានភាពជាអន្តរជាតិនៃប្រទេស ឬដែនដីដែលបុគ្គលនោះរស់នៅ ទោះជាប្រទេសនោះរស់នៅស្ថិតនៅជាឯករាជ្យមានទំនុកចិត្តមិនស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ខ្លួន ឬស្ថិតនៅក្រោមការកំណត់អធិបតេយ្យភាពផ្សេងណាមួយក៏ដោយ ។

មាត្រា៣

មនុស្សគ្រប់រូបមានសិទ្ធិក្នុងការមានជីវិត សេរីភាព និងសន្តិសុខផ្ទាល់ខ្លួន ។

មាត្រា៤

គ្មាននរណាម្នាក់ នឹងស្ថិតក្នុងស្ថានភាពជាទាសភាព ឬជាខ្ញុំកញ្ជះគេ។ ទាសភាព និងការជួញដូរ ជាទាសករ ត្រូវបានហាមឃាត់នៅក្នុងគ្រប់ទម្រង់ ។

មាត្រា៥

គ្មាននរណាម្នាក់ជាកម្មវត្ថុនៃការធ្វើទារុណកម្ម ឬអំពើឃោរឃៅកាចសាហាវឥតមនុស្សធម៌ ឬការប្រព្រឹត្តឱ្យអាម៉ាស់ ឬការដាក់ទណ្ឌកម្មឡើយ ។

មាត្រា៦

នៅគ្រប់ទីកន្លែង គ្រប់ៗរូបមានសិទ្ធិទទួលស្គាល់ថាជាមនុស្សនៅចំពោះមុខច្បាប់ ។

មាត្រា៧

គ្រប់ៗរូបស្មើភាពគ្នាចំពោះមុខច្បាប់ និងទទួលបានដោយគ្មានការរើសអើង នូវកិច្ចការពារស្មើគ្នាពីច្បាប់ ។

មាត្រា៨

គ្រប់ៗរូបមានសិទ្ធិក្នុងការការពារយ៉ាងសក្តិសមដោយតុលាការជាតិទទួលការប្រព្រឹត្តបទល្មើស។ សិទ្ធិជាមូលដ្ឋានគ្រឹះត្រូវផ្តល់ឱ្យគេដោយរដ្ឋធម្មនុញ្ញ ឬដោយច្បាប់។

មាត្រា៩

គ្មាននរណាម្នាក់ជាកម្មវត្ថុនៃការចាប់ចង ឃុំឃាំង ឬនិរទេសដោយរំលោភបំពានឡើយ។

មាត្រា១០

គ្រប់ៗរូបត្រូវបានទទួលនូវសមភាពពេញលេញ ក្នុងការស្តាប់ជាសាធារណៈនូវការកាត់ក្តីដោយតុលាការឯករាជ្យ និងមិនលំអៀងនូវក្នុងការសម្រេចអំពីសិទ្ធិ និងកាតព្វកិច្ចរបស់គេ និងអំពីការចោទប្រកាន់ប្រឆាំង នឹងគេពីបទឧក្រិដ្ឋណាមួយ។

មាត្រា១១

(១) អ្នកដែលត្រូវបានចោទប្រកាន់ថាជាជនជាប់ចោទ មានសិទ្ធិចាត់ទុកថាគ្មានទោសរហូតទាល់តែអាចបង្ហាញភស្តុតាងថា មានកំហុសទៅតាមច្បាប់នៅក្នុងការកាត់ទោសជាសាធារណៈនៅពេលនោះគេត្រូវបានទទួលនូវការធានា ទាំងអស់ដែលចាំបាច់សម្រាប់ការពារខ្លួន ។

(២) គ្មាននរណាម្នាក់នឹងមានទោសទណ្ឌឡើយ នៅក្នុងករណីដែលទោសកំហុសនោះពុំមានចែងនៅក្នុងច្បាប់ជាតិ ក្នុងពេលដែលបទល្មើសនោះបានប្រព្រឹត្ត។ នៅក្នុងករណីមានចែងច្បាប់ជាថ្មីអ្នកមិនមានទោសទណ្ឌឡើយព្រោះច្បាប់នេះអនុវត្តក្រោយការប្រព្រឹត្តិកំហុស គឺមិនអាចយកទៅអនុវត្តលើអំពើដែលបានប្រព្រឹត្តហើយក្នុងអតីតកាលនោះទេ។

មាត្រា១២

គ្មាននរណាម្នាក់ត្រូវបានទៅជាកម្មវត្ថុនៃការជ្រៀតជ្រែកដោយរំលោភបំពាននៅក្នុងជីវិតឯកជន គ្រួសារ ទីលំនៅ ឬទំនាក់ទំនង ឬការបំពារបំពានទៅលើកិត្តិយស ឬកេរ្តិ៍ឈ្មោះរបស់គេបានឡើយ។ គ្រប់ៗរូបមានសិទ្ធិទទួលកិច្ចការពារ ដោយច្បាប់ប្រឆាំងនឹងការជ្រៀតជ្រែក ឬ ការបំពារបំពានទាំងអស់នេះ ។

មាត្រា១៣

(១) គ្រប់រូបមានសិទ្ធិក្នុងការធ្វើដំណើរ និងតាំងទីលំនៅដោយសេរីនៅក្នុងព្រំដែននៃរដ្ឋនីមួយៗ ។

(២) គ្រប់រូបមានសិទ្ធិចាកចេញពីប្រទេសណាមួយរួមទាំងប្រទេសរបស់ខ្លួនផ្ទាល់ និងវិលត្រឡប់មកប្រទេសរបស់ខ្លួន ។

មាត្រា១៤

(១) គ្រប់រូបមានសិទ្ធិក្នុងការស្វែងរក និងទទួលបានការជ្រកកោននៅក្នុងប្រទេសដទៃទៀត ដើម្បីរួចផុតពីការធ្វើទុក្ខទោស។

(២) សិទ្ធិនេះមិនអាចយកមកប្រើនៅក្នុងករណីដែលការធ្វើទុក្ខទោសនោះ ពុំមែនជាទោសនយោបាយ ឬបណ្តាល មកពីប្រព្រឹត្តជំទាស់ទៅនឹងគោលបំណង និងគោលការណ៍អង្គការសហប្រជាជាតិ។

មាត្រា១៥

(១) គ្រប់រូបមានសិទ្ធិក្នុងការមានសញ្ជាតិមួយ ។

(២) គ្មាននរណាម្នាក់មានសិទ្ធិប្តូរសញ្ជាតិរបស់អ្នក ឬដកហូតសញ្ជាតិរបស់អ្នកដោយបំពានតាមអំពើចិត្តបានឡើយ។

មាត្រា១៦

(១) បុរស និងស្ត្រីស្ថិតនៅក្នុងអាយុពេញវ័យមានសិទ្ធិរៀបអាពាហ៍ពិពាហ៍ និងកសាងគ្រួសារដោយពុំមានកំណត់ពីពូជសាសន៍ សញ្ជាតិឬសាសនាឡើយ។ ពួកគេទទួលបាននូវសិទ្ធិស្មើគ្នាទាំងការរៀបអាពាហ៍ពិពាហ៍ទាំងក្នុងកំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ និងក្នុងការរំសាយចំណងអាពាហ៍ពិពាហ៍។

(២) អាពាហ៍ពិពាហ៍ អាចធ្វើទៅបានតាមការព្រមព្រៀងដោយសេរីពីសាមីខ្លួនទាំងសងខាងដោយពុំមានការបង្ខិតបង្ខំ។

(៣) គ្រួសារគឺជាធម្មជាតិ និងជាក្រុមធាតុដ៏សំខាន់របស់សង្គម និងមានសិទ្ធិទទួលបាននូវកិច្ចការពារដោយសង្គម និងរដ្ឋ ។

មាត្រា១៧

(១) គ្រប់រូបមានសិទ្ធិមានទ្រព្យសម្បត្តិកម្មសិទ្ធិផ្ទាល់ខ្លួនក៏ដូចជានៅក្នុងសហគមន៍ជាមួយអ្នកដទៃ។

(២) គ្មាននរណាម្នាក់អាចដកហូតទ្រព្យសម្បត្តិរបស់អ្នកដោយបំពានតាមអំពើចិត្តបានឡើយ ។

មាត្រា១៨

គ្រប់រូបមានសិទ្ធិ និងសេរីភាពក្នុងការគិត ទស្សនៈ និងសាសនា សិទ្ធិនេះរួមបញ្ចូលទាំងសេរីភាពក្នុងការផ្លាស់ប្តូរ ជំនឿ ឬសាសនា និងសេរីភាពទាំងនៅតែឯង ឬ នៅក្នុងសហគមន៍ជាមួយអ្នកដទៃ និងនៅសាធារណៈ ឬឯកជន ការសម្តែង នូវជំនឿ ឬសាសនារបស់គេនៅក្នុងការបង្រៀនការប្រតិបត្តិ ទីសក្ការៈ និងក្នុងពិធីបុណ្យ ។

មាត្រា១៩

គ្រប់រូបមានសិទ្ធិ និងសេរីភាពក្នុងការមានមតិ និងសម្តែងមតិសិទ្ធិនេះរួមបញ្ចូលទាំងសេរីភាពក្នុងការប្រកាន់នូវមតិយោបល់ដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរក ទទួល និងចែករំលែកនូវព័ត៌មាន និងគំនិតយោបល់តាមរយៈការផ្សព្វផ្សាយណាមួយ និងដោយគ្មានគិតព្រំដែន ។

មាត្រា២០

(១) គ្រប់រូបមានសិទ្ធិ និងសេរីភាពក្នុងការជួបប្រជុំ និងចូលរួមជាសហគមន៍ដោយសន្តិវិធី ។

(២) គ្មាននរណាម្នាក់ត្រូវបានបង្ខំជាសមាជិកសហគមន៍ឡើយ ។

មាត្រា២១

(១) គ្រប់រូបមានសិទ្ធិចូលរួមចំណែកនៅក្នុងរដ្ឋាភិបាលនៃប្រទេសរបស់ខ្លួនដោយផ្ទាល់ ឬតាមរយៈការជ្រើសរើសអ្នកតំណាងដោយសេរី ។

(២) គ្រប់រូបមានសិទ្ធិស្មើគ្នាក្នុងការទទួលបាននូវការប្រើប្រាស់សេវាសាធារណៈនៅក្នុងប្រទេសរបស់ខ្លួន ។

មាត្រា២២

គ្រប់រូបក្នុងនាមជាសមាជិកសង្គមមានសិទ្ធិទទួលបាននូវសមិទ្ធិ និងសន្តិសុខសង្គម តាយរយៈការខិតខំប្រឹងប្រែងជាតិ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងស្របតាមការរៀបចំចាត់ចែង និងធនធានរបស់រដ្ឋនីមួយអំពីសិទ្ធិសេដ្ឋកិច្ចសង្គម និងវប្បធម៌ដែលជាកាតព្វកិច្ចសម្រាប់សេចក្តីថ្លៃថ្នូរ និងការអភិវឌ្ឍន៍បុគ្គលិកលក្ខណៈរបស់គេដោយសេរី ។

មាត្រា២៣

(១) គ្រប់រូបមានសិទ្ធិមានការងារធ្វើ សិទ្ធិជ្រើសរើសការងារដោយសេរីត្រឹមត្រូវ និងលក្ខខណ្ឌការងារសមរម្យ និងមានកិច្ចគាំពារប្រឆាំងនឹងភាពគ្មានការងារធ្វើ ។

(២) គ្រប់រូបមានសិទ្ធិទទួលបានប្រាក់កំរៃស្មើគ្នាសម្រាប់ការងារ ដូចគ្នាដោយគ្មានការរើសអើង ។

(៣) បុគ្គលដែលបំរើការងារគ្រប់រូបមានសិទ្ធិទទួលបាននូវប្រាក់ធានារ៉ាប់រងសមរម្យ និងដោយយុត្តិធម៌ សម្រាប់ខ្លួនគេផ្ទាល់ព្រមទាំងគ្រួសារក្នុងការមានជីវភាពសមរម្យសម្រាប់សេចក្តីថ្លៃថ្នូរនៃមនុស្ស ហើយនឹងអ្វីៗដែលបំពេញបន្ថែមទៀតប្រសិនបើចាំបាច់ដោយប្រើកិច្ចគាំពារសង្គមផ្សេងៗ។

(៤) គ្រប់រូបមានសិទ្ធិក្នុងការបង្កើត និងចូលរួមភាគហ៊ុនក្នុងមុខរបរ ដើម្បីការពារផលប្រយោជន៍ខ្លួន ។

មាត្រា២៤

គ្រប់រូបមានសិទ្ធិក្នុងការសម្រាក និងលំហែរួមបញ្ចូលទាំងការកំណត់ចំនួនម៉ោងការងារសមរម្យ ហើយនិងចំនួនថ្ងៃឈប់សម្រាកដោយមានប្រាក់កំរៃ ។

មាត្រា២៥

(១) គ្រប់រូបមានសិទ្ធិក្នុងការមានលក្ខខណ្ឌរស់នៅសមរម្យ ដែលគ្រប់គ្រាន់សម្រាប់សុខភាព និងសុខមាលភាពសម្រាប់ខ្លួន និងក្រុមគ្រួសាររួមបញ្ចូលទាំងចំណីអាហារ សម្លៀកបំពាក់ ផ្ទះសំបែង ការថែទាំផ្នែកវេជ្ជសាស្ត្រ និងសេវាសង្គមនានា និងសិទ្ធិធានាក្នុងគ្រាគ្មានការងារធ្វើមានជំងឺ អសមត្ថភាព ភាពជាមេម៉ាយ។

(២) គ្រប់រូបមានសិទ្ធិក្នុងការការពារនូវសីលធម៌ និងសម្ភារៈសំខាន់ពិសេសដែលជាលទ្ធផលនៃវិទ្យាសាស្ត្រណាមួយ ឬនៃអក្សរសាស្ត្រ ឬជាស្នាដៃសិល្បៈ ដែលខ្លួនជាអ្នកនិពន្ធ ឬជាអ្នកច្នៃប្រឌិត។

មាត្រា២៦

(១) គ្រប់រូបមានសិទ្ធិក្នុងការអប់រំ។ ការអប់រំដោយឥតបង់ថ្លៃយ៉ាងហោចណាស់កម្រិតបឋម និងកម្រិតមូលដ្ឋាន ។ ការអប់រំកម្រិតបឋមត្រូវតែជាកាតព្វកិច្ចសិក្សា។ ការអប់រំបច្ចេកទេស និងជំនាញវិជ្ជាជីវៈត្រូវធ្វើឡើងដោយទូទៅដែលងាយរកបាន ហើយការអប់រំកម្រិតខ្ពស់ត្រូវធ្វើឡើងដែលទាំងអស់គ្នាអាចទទួលបានដោយស្មើភាព។

(២) ការអប់រំត្រូវឆ្ពោះទៅរកការអភិវឌ្ឍន៍ពេញលេញនៃបុគ្គលិកលក្ខណៈរបស់មនុស្ស និងពង្រឹងការគោរពសិទ្ធិមនុស្ស និងគ្រឹះនៃសេរីភាព។ ការអប់រំត្រូវជំរុញឱ្យមានការយោគយល់ ការអត់ឱនអធ្យាស្រ័យ និងមិត្តភាពរវាងប្រជាជាតិទាំងអស់ គ្រប់សាសន៍ ឬក្រុមសាសនា និងជួយជ្រោមជ្រែងសកម្មភាពរបស់អង្គការសហប្រជាជាតិដើម្បីថែរក្សាសន្តិភាព។

(៣) ឪពុកម្តាយមានសិទ្ធិជាអាទិភាពក្នុងការជ្រើសរើសប្រភេទនៃការសិក្សា ដែលត្រូវផ្តល់ដល់កូនរបស់ពួកគេ ។

មាត្រា២៧

(១) គ្រប់រូបមានសិទ្ធិក្នុងការចូលរួមដោយសេរីនៅក្នុងជីវិតវប្បធម៌នៃសហគន៍ ចូលរួមក្នុងសិល្បៈ និងមានចំណែកនៅក្នុងការរីកចម្រើននៃវិទ្យាសាស្ត្រ និងអត្ថប្រយោជន៍របស់វា។

(២) គ្រប់រូបមានសិទ្ធិការពារនូវសីលធម៌ និងសម្ភារៈសំខាន់ពិសេសដែលជាលទ្ធផលនៃវិទ្យាសាស្ត្រណាមួយ ឬនៃអក្សរសាស្ត្រ ឬជាស្នាដៃសិល្បៈដែលខ្លួនជាអ្នកនិពន្ធ ឬជាអ្នកច្នៃប្រឌិត ។

មាត្រា២៨

គ្រប់រូបមានសិទ្ធិទទួលការរៀបចំសង្គម និងអន្តរជាតិដែលក្នុងនោះសិទ្ធិ និងសេរីភាពដែលមានចែងក្នុងថ្លែងការណ៍នេះនឹងអាចប្រតិបត្តិបានទាំងស្រុង ។

មាត្រា២៩

(១) គ្រប់រូបមានករណីយកិច្ចចំពោះសហគមន៍ ដែលនៅក្នុងនោះគេអាចធ្វើការអភិវឌ្ឍន៍ពេលលេញ និងដោយសេរីនូវបុគ្គលិកលក្ខណៈរបស់ខ្លួនគេ ។

(២) ការកំណត់ព្រំដែននៅក្នុងការប្រើប្រាស់សិទ្ធិ និងសេរីភាពរបស់បុគ្គលគ្រប់រូបអាចធ្វើបានតែតាមបញ្ញត្តិច្បាប់ដើម្បីឆ្ពោះទៅនៅក្នុងសង្គមប្រជាធិបតេយ្យ ។

(៣) សិទ្ធិ និងសេរីភាពទាំងនេះមិនអាចប្រើប្រាស់ក្នុងករណីផ្ទុយទៅនឹងគោលបំណង និងគោលការណ៍របស់អង្គការសហប្រជាជាតិឡើយ ។

មាត្រា៣០

គ្មានបញ្ញត្តិណាមួយនៅក្នុងសេចក្តីថ្លែងការណ៍នេះត្រូវបានបកប្រែសម្រាប់រដ្ឋណាមួយក្រុម ឬបុគ្គលណាមួយដើម្បីជំរុញសកម្មភាព ឬ ធ្វើអំពើណាមួយក្នុងបំណងបំផ្លាញសិទ្ធិ និងសេរីភាពនីមួយៗដែលមានចែងក្នុង សេចក្តីថ្លែងការណ៍នេះឡើង ។

២.អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ

អនុម័ត និងចុះហត្ថលេខាផ្តល់សច្ចាប័ន និងយល់ព្រមដោយមហាសន្និបាត ៤៤/២៥ ថ្ងៃទី២០ វិច្ឆិកា ១៩៨៩ ។ ចូលជាធរមាន ២ កញ្ញា ១៩៩០ ដោយមាន៤៩មាត្រា

សំនាំដើម

រដ្ឋជាភាគីនាំឱឡាយនៃអនុសញ្ញានេះ

ដោយសង្កេតឃើញថា អនុលោមតាមគោលការណ៍នានាដែលបានប្រកាសក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ ការទទួលស្គាល់នូវភាពថ្លៃថ្នូរ ដែលមានតាំងពីកំណើត និងសិទ្ធិស្មើភាព ដែលមិនអាចផ្តាច់ចេញបាននៃរាល់សមាជិកនៃគ្រួសារមនុស្សគឺ ជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពនៅក្នុងពិភពលោក ។

ដោយចងចាំនៅក្នុងចិត្តថា ប្រជាជនទាំងឡាយនៃអង្គការសហប្រជាជាតិបានអះអាងជាថ្មីនៅក្នុងធម្មនុញ្ញ នេះនូវជំនឿជាក់ច្បាស់របស់ខ្លួនក្នុងសិទ្ធិជាគ្រឹះរបស់មនុស្ស និងភាពថ្លៃថ្នូរ និងតម្លៃរបស់បុគ្គល ហើយបានប្តេជ្ញាជំរុញវឌ្ឍនៈសង្គម និងលក្ខខណ្ឌរស់នៅឱ្យកាន់តែប្រសើរក្នុងសេរីភាពមួយកាន់តែទូលាយជាងមុន ។

ដោយទទួលស្គាល់ថាអង្គការសហប្រជាជាតិនៅក្នុងសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស ហើយនិងនៅក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្សបានប្រកាស និងឯកភាពថាបុគ្គលគ្រប់រូបសុទ្ធតែត្រូវទទួលបានសិទ្ធិ និងសេរីភាព ដែលមានចែងនៅក្នុងឯកសារទាំងនោះ ដោយគ្មានការបែងចែកអ្វីទាំងអស់ដូចជាពូជសាសន៍ពណ៌សម្បុរ ភេទ សាសនា នយោបាយ ឬទស្សនៈផ្សេងៗ សញ្ជាតិ ឬប្រភពសង្គមទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពផ្សេងៗទៀត ។

ដោយរំលឹកឡើងវិញថា នៅក្នុងសេចក្តីថ្លែងការណ៍ជាសកល ស្តីពីសិទ្ធិមនុស្សអង្គការសហប្រជាជាតិបានប្រកាសថាកុមារត្រូវទទួលបាននូវកិច្ចថែទាំ និងការជួយឧបត្ថម្ភជាពិសេស ។

ដោយមានជំនឿថា គ្រួសារក្នុងតួនាទីជាអង្គភាពគ្រឹះនៃសង្គមហើយ និងជាបរិស្ថានធម្មជាតិសម្រាប់ការរីកចម្រើនលូតលាស់ និងផាសុខភាពរបស់សមាជិកទាំងមូលជាពិសេសកុមារត្រូវតែមានកិច្ចគាំពារ និងជួយឧបត្ថម្ភចាំបាច់ ដើម្បីឱ្យគេអាចបំពេញភារកិច្ចទទួលខុសត្រូវរបស់គេបានពេញលេញនៅក្នុងសហគមន៍បាន ។

ដោយទទួលស្គាល់ថាកុមារ ដើម្បីការអភិវឌ្ឍពេលលេញ និងសមស្របទៅនឹងបុគ្គលិកលក្ខណៈរបស់ពួកគេត្រូវបានលូតលាស់នៅក្នុងមជ្ឈដ្ឋានគ្រួសារ នៅក្នុងបរិយាកាសប្រកបដោយសុភមង្គល សេចក្តីស្រលាញ់ និងការយោគយល់ ។

ដោយសង្កេតឃើញថា កុមារត្រូវតែមានការរៀបចំខ្លួនឱ្យបានពេញលេញ ដើម្បីរស់នៅក្នុងជីវភាពជាបុគ្គលនៅក្នុងសង្គម ហើយនឹងត្រូវធ្វើការអប់រំក្នុងស្មារតីឧត្តមគតិ ដែលបានចែងនៅក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិជាពិសេសនៅក្នុងស្មារតីសន្តិភាព ភាពថ្លៃថ្នូរ ភាពអនុគ្រោះ សេរីភាព សមភាព និងសាមគ្គីភាព ។

ដោយចងចាំក្នុងចិត្តថា សេចក្តីត្រូវការនូវការពង្រឹងកិច្ចថែទាំជាពិសេសចំពោះកុមារ ត្រូវបានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍ក្រុងហ្សឺណែវស្តីពីសិទ្ធិកុមារឆ្នាំ១៩២៤ និងសេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិកុមារដែលត្រូវបានអនុម័ត ដោយមហាសន្និបាតនាថ្ងៃទី២០ វិច្ឆិកា ១៩៥៩ ហើយដែលត្រូវទទួលស្គាល់នៅក្នុងសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្សនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ (ជាពិសេសក្នុងមាត្រា២៣ និង ២៤) នៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ជាពិសេសនៅក្នុងមាត្រា១០) ហើយនៅក្នុងលក្ខន្តិកៈ និង ឯកសារទាក់ទងរបស់ភ្នាក់ងារឯកទេស និងអង្គការអន្តរជាតិទាំងឡាយដែលទាក់ទងទៅនឹងសុខមាលភាពរបស់កុមារ ។

ដោយចងចាំក្នុងចិត្ត ដូចដែលបានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិកុមាររួចហើយ "កុមារអាស្រ័យដោយភាពមិនទាន់ចាស់ទុំផ្នែករាងកាយ និងសតិបញ្ញារមែងត្រូវការការពារ និងថែទាំជាពិសេសរួមបញ្ចូលទាំងកិច្ចការពារត្រឹមត្រូវផ្នែកផ្លូវច្បាប់ ទាំងមុន និងក្រោយពេលប្រសូត្រ "។

ដោយរំលឹកឡើងវិញថា បទបញ្ញត្តិនៃសេចក្តីថ្លែងការណ៍ស្តីពីគោលការណ៍ច្បាប់ និងគោលការណ៍សង្គមដែលទាក់ទងនឹងកិច្ចការពារ និងសុខមាលភាពរបស់កុមារ សំដៅពិសេសទៅលើការដាក់ឱ្យចិញ្ចឹម និងការសុំកូនចិញ្ចឹម ទាំងក្នុងកម្រិតជាតិ និងអន្តរជាតិបញ្ញត្តិជាបទដ្ឋានអប្បបរមានៃអង្គការសហប្រជាជាតិស្តីពីការងារយុត្តិធម៌សម្រាប់យុវជន (បញ្ញត្តិទីក្រុងប៉េកាំង) ហើយនឹងសេចក្តីថ្លែងការណ៍ស្តីពីកិច្ចគាំពារស្ត្រី និងកុមារនៅក្នុងភាពអាសន្ន និង ពេលមានជម្លោះដោយអាវុធ ។

ដោយទទួលស្គាល់ថា នៅក្នុងគ្រប់ប្រទេសទាំងអស់ក្នុងពិភពលោកមានកុមារដែលកំពុងរស់នៅក្នុងស្ថានភាពដ៏លំបាកយ៉ាប់យ៉ឺនបំផុត ហើយកុមារទាំងនេះត្រូវការយកចិត្តទុកដាក់ជាពិសេស ។

ដោយបានគិតគូរយ៉ាងសមស្របដោយសារៈសំខាន់នៃតម្លៃប្រពៃណី និងវប្បធម៌របស់ប្រជាជននីមួយៗនៅក្នុងកិច្ចគាំពារ ហើយនឹងការអភិវឌ្ឍដោយសមស្របរបស់កុមារ ។

ដោយទទួលស្គាល់ពីសារៈសំខាន់នៃកិច្ចប្រតិបត្តិការជាអន្តរជាតិ ដើម្បីលើកកម្ពស់លក្ខខណ្ឌនៃការរស់នៅរបស់កុមារក្នុងប្រទេសនីមួយៗជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍ ។

បានឯកភាពដូចខាងក្រោមនេះ

ភាគ I

មាត្រា១

ក្នុងគោលដៅអនុសញ្ញានេះ កុមារមានន័យថាមនុស្សគ្រប់រូបដែលមានអាយុតិចជាង១៨ឆ្នាំអនុលោមតាមច្បាប់សម្រាប់អនុវត្តន៍ចំពោះកុមារ ។

មាត្រា២

១- រដ្ឋជាភាគីត្រូវគោរព និងធានានូវសិទ្ធិទាំងប៉ុន្មានដែលមានចែងក្នុងអនុសញ្ញានេះចំពោះរាល់កុមារដែលស្ថិតនៅក្នុងដែនអំណាចច្បាប់របស់ខ្លួន ដោយគ្មានការរើសអើងអ្វីទាំងអស់លើពូជសាសន៍ ពណ៌ សំបុរ ភេទ ភាសា សាសនា នយោបាយ ឬទស្សនៈផ្សេងៗ សញ្ជាតិ ប្រភពសង្គម ទ្រព្យសម្បត្តិ អសមត្ថភាព ស្ថានភាពកំណើត ឬ ស្ថានភាពផ្សេងៗ ទៀតរបស់កុមារ ឬរបស់ឪពុកម្តាយ ឬ អ្នកអាណាព្យាបាលស្របច្បាប់របស់ខ្លួនឡើយ ។

២- រដ្ឋជាភាគីត្រូវប្រកាន់យកវិធានការសមស្របទាំងឡាយ ដើម្បីធានាថាកុមារត្រូវបានការពារប្រឆាំងនឹងរាល់ទម្រង់នៃការរើសអើង ឬការផ្តន្ទាទោសដោយឈរលើមូលដ្ឋាននៃស្ថានភាព សកម្មភាពការបញ្ចេញមតិ ឬជំនឿរបស់ឪពុកម្តាយ អ្នកអាណាព្យាបាលស្របច្បាប់ ឬសមាជិកនានានៃគ្រួសាររបស់កុមារ ។

មាត្រា៣

(១)នៅក្នុងសកម្មភាពទាំងអស់ដែលមានទាក់ទងនឹងកុមារ ទោះជាសកម្មភាពនេះត្រូវធ្វើឡើងដោយស្ថាប័នសង្គមកិច្ចសាធារណៈ ឬឯកជនដោយតុលាការអាជ្ញាធររដ្ឋបាល ឬដោយស្ថាប័ននៃនីតិបញ្ញត្តិក្តី ក៏ផលប្រយោជន៍ ដ៏ល្អបំផុតរបស់កុមារត្រូវតែចាត់ទុកជាចម្បង។ ។

(២)រដ្ឋជាភាគីសន្យាថានឹងធានាដល់កុមារនូវកិច្ចគាំពារ និងការថែទាំដែលចាំបាច់ដល់សុខមាលភាពរបស់កុមារដោយគិតគូរដល់សិទ្ធិ និងករណីយកិច្ចឪពុកម្តាយ អ្នកអាណាព្យាបាលស្របច្បាប់ និងបុគ្គលឯទៀតដែលទទួលខុសត្រូវស្របច្បាប់លើកុមារ ហើយក្នុងទិសដៅនេះត្រូវប្រកាន់យកនូវរាល់វិធានការផ្នែកច្បាប់ និងផ្នែករដ្ឋបាលទាំងអស់ដែលសមស្រប។

(៣)រដ្ឋជាភាគីធានាថាស្ថាប័នកិច្ចការទំនុកបំរុងនិងស្ថាប័នទទួលខុសត្រូវក្នុងការសម្របសម្រួលសម្រាប់ការថែរក្សា ឬ ការពារកុមារត្រូវមានលក្ខណៈត្រឹមត្រូវស្របតាមបទដ្ឋាន(ខ្នាត) ដែលអាជ្ញាធរមានសមត្ថកិច្ចត្រូវឱ្យមាននៅក្នុងចំនួន និងសម្បទានៃបុគ្គលិករបស់ខ្លួនព្រមទាំងសមត្ថភាពគ្រប់គ្រងពិសេសនៅក្នុងវិស័យសន្តិសុខ និងសុខភាព ។

មាត្រា៤

រដ្ឋជាភាគីប្រកាន់យកវិធានការសមស្របទាំងអស់ទាំងផ្នែកច្បាប់ ផ្នែករដ្ឋបាល និងផ្នែកផ្សេងទៀតក្នុងការដាក់ឱ្យប្រើប្រាស់នូវសិទ្ធិដែលមានចែងក្នុងអនុសញ្ញានោះ។ ទាក់ទងទៅនឹងសិទ្ធិសេដ្ឋកិច្ចសង្គម និងវប្បធម៌ រដ្ឋជាភាគីត្រូវប្រកាន់យកវិធានការទាំងអស់នោះនៅក្នុងកម្រិតអតិបរមានៃប្រភពធនធានដែលខ្លួនមាន និងប្រសិនបើចាំបាច់ ត្រូវស្ថិតក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ។

មាត្រា៥

រដ្ឋជាភាគីត្រូវគោរពដល់ការទទួលខុសត្រូវ សិទ្ធិ និងគោរពករណីយកិច្ចរបស់ឪពុក ម្តាយ ឬសមាជិកគ្រួសារដែលជាសាច់ញាតិឆ្ងាយ ឬសមាជិកនៃសហគមន៍ដែលតាមទំនៀមទម្លាប់ប្រចាំភូមិស្រុក គេចាត់ឱ្យមានអាណាព្យាបាលស្របច្បាប់ ឬអ្នកឯទៀតដែលជាអ្នកទទួលខុសត្រូវតាមច្បាប់លើកុមារនៅក្នុងការផ្តល់ដល់កុមារទៅតាមរបៀបមួយ ដែលស្របគ្នាទៅនឹងការីកចម្រើនលូតលាស់នៃសមត្ថភាពរបស់កុមារ នូវការដឹកនាំ និងដំបូន្មានសមស្របទៅនឹងការប្រើប្រាស់សិទ្ធិទាំងឡាយដែលត្រូវបានទទួលស្គាល់ដោយអនុសញ្ញានេះ ។

មាត្រា៦

(១) រដ្ឋជាភាគីទទួលស្គាល់ថាកុមារគ្រប់រូបមានសិទ្ធិក្នុងការរស់រានមានជីវិតដែលមិនអាចដកហូតបាន ។

(២) រដ្ឋជាភាគីត្រូវធានាការរស់នៅ និងការអភិវឌ្ឍរបស់កុមារឱ្យបានដល់កម្រិតខ្ពស់បំផុត ។

មាត្រា៧

(១) កុមារត្រូវបានចុះបញ្ជីកំណើត(អត្រានុកូលដ្ឋាន) ភ្លាមក្រោយពេលប្រសូត្រ ហើយមានសិទ្ធិក្នុងការមានឈ្មោះមួយមានសិទ្ធិទទួលបានសញ្ជាតិមួយតាំងពីពេលកើតមកភ្លាម និងមានសិទ្ធិស្គាល់ឪពុកម្តាយខ្លួនព្រមទាំងទទួលបានការថែទាំពីអ្នកទាំងនោះឱ្យបានពេញលេញតាមតែអាចធ្វើទៅបាន ។

(២) រដ្ឋជាភាគីត្រូវធានាការអនុវត្តប្រើប្រាស់នូវសិទ្ធិទាំងនេះស្របទៅតាមច្បាប់របស់ជាតិខ្លួន និងស្របទៅនឹងកាតព្វកិច្ចរបស់ខ្លួនដែលចែងក្នុងឯកសារអន្តរជាតិស្តីអំពីប្រការនេះ ពិសេសកុមារនឹងមានសិទ្ធិជាពលរដ្ឋពេលលេញនៅក្នុងប្រទេសរបស់ខ្លួនប្រសិនណាបើគ្មានឯកសារទាំងនោះ ។

មាត្រា៨

(១) រដ្ឋជាភាគីសន្យាថាគោរពសិទ្ធិរបស់កុមារក្នុងការរក្សានូវអត្តសញ្ញាណរបស់គេ ដោយរាប់បញ្ចូលទាំងសញ្ជាតិឈ្មោះព្រមទាំងទំនាក់ទំនងគ្រួសារ ដែលទទួលតាមផ្លូវច្បាប់ដោយគ្មានការជ្រៀតជ្រែកចូលដោយខុសច្បាប់ ឡើយ ។

(២) នៅពេលដែលកុមារបាត់បង់ដោយខុសច្បាប់នូវអត្តសញ្ញាណរបស់ខ្លួនមួយភាគ ឬទាំងស្រុង រដ្ឋជាភាគីត្រូវផ្តល់នូវកិច្ចការពារ និងជួយឧបត្ថម្ភឱ្យបានសមស្រប ដើម្បីធ្វើឱ្យមានឡើងវិញយ៉ាងឆាប់រហ័សនូវអត្តសញ្ញាណនេះ ។

មាត្រា៩

(១) រដ្ឋជាភាគីធានាថា កុមារមិនត្រូវបានបំបែកចេញពីឪពុកម្តាយដោយផ្ទុយអំពីឆន្ទៈរបស់ពួកគេឡើយលើកលែងតែអាជ្ញាធរមានសមត្ថកិច្ចកំណត់តាមច្បាប់ និងនីតិវិធីដែលអាចអនុវត្តបានក្នុងន័យថាការបំបែកនេះគឺ ជាការចាំបាច់សម្រាប់ផលប្រយោជន៍ល្អបំផុតរបស់កុមារ ។ការកំណត់បែបនេះអាចជាការចាំបាច់ក្នុងករណីពិសេសណាមួយដូចជាករណី ដែលឪពុកម្តាយបំពាន ឬមិនសូវគិតដល់កុមារ ឬក្នុងករណីដែលឪពុកម្តាយរស់នៅបែកគ្នាហើយទាមទារនូវការសម្រេចចិត្តស្តីពីកន្លែងស្នាក់នៅរបស់កុមារ ។

(២) នៅក្នុងរាល់កិច្ចការដែលស្របទៅនឹងកថាខណ្ឌ១នៃមាត្រានេះ ភាគីទាំងអស់ដែលទាក់ទងត្រូវបានអនុញ្ញាតឱ្យចូលរួមនៅក្នុងកិច្ចពិភាក្សា និងបង្ហាញយោបល់របស់ខ្លួនបាន ។

(៣) រដ្ឋជាភាគីគោរពសិទ្ធិរបស់កុមារដែលត្រូវបំបែកចេញពីឪពុក ឬម្តាយ ឬពីឪពុកម្តាយទាំងពីរ ក្នុងការរក្សាទំនាក់ទំនងដោយផ្ទាល់ជាមួយឪពុកម្តាយឱ្យបានទៀងទាត់ លើកលែងតែប្រការនោះផ្ទុយនឹងផលប្រយោជន៍ល្អបំផុតរបស់កុមារ។

(៤) នៅពេលដែលការបំបែកចេញនោះបណ្តាលមកពីសកម្មភាពរបស់រដ្ឋ ជាភាគីដូចជាការឃាត់ខ្លួនការដាក់ពន្ធនាគារ ការនិរទេស ឬមរណភាព (រួមទាំងមរណភាពដែលបណ្តាលមកពីហេតុអ្វីក៏ដោយនៅក្នុងពេលដែលបុគ្គលនោះស្ថិតនៅកន្លែងឃាត់ខ្លួនរបស់រដ្ឋ) របស់អ្នកណាម្នាក់ជាឪពុក ឬជាម្តាយ ឬរដ្ឋជាភាគីនោះនៅពេលមានសំណើត្រូវផ្តល់ដល់ឪពុកម្តាយ ឬកុមារ ឬ សមាជិកផ្សេងទៀតនៃគ្រួសារនូវព័ត៌មានសំខាន់ៗដែលទាក់ទង ទៅនឹងទីកន្លែងនៃសមាជិកគ្រួសារដែលបាត់បង់ ឬស្លាប់ លើកលែងតែការផ្តល់ព័ត៌មានអាចធ្វើឱ្យប៉ះពាល់ដល់សុខមាលភាពរបស់កុមារ ម៉្យាងទៀតរដ្ឋជាភាគីត្រូវធានាថាការលើកឡើងនូវសំណើបែបនេះ នឹងមិននាំជាផលវិបាកអាក្រក់ដល់សាមីជន ដែលទាក់ទិនឡើយ ។

មាត្រា១០

(១) ដោយស្របទៅនឹងកាតព្វកិច្ចរបស់រដ្ឋជាភាគីដែលមាននៅក្នុងមាត្រា៩កថាខណ្ឌ១ រាល់សំណើសុំរបស់កុមារ ឬឪពុកម្តាយដើម្បីចូល ឬចាកចេញពីប្រទេស ដើម្បីទៅជួបជុំគ្រួសារវិញនោះ រដ្ឋជាភាគីត្រូវតែដោះស្រាយដោយអនុគ្រោះប្រកបដោយមនុស្សធម៌ និងឱ្យបានឆាប់រហ័ស។ ម៉្យាងទៀតរដ្ឋជាភាគីត្រូវធានាថាការស្នើសុំនោះ នឹងមិនត្រូវឱ្យមានផលវិបាកអាក្រក់ដល់អ្នកស្នើសុំ និងដល់សមាជិកនៃគ្រួសារនេះឡើយ។

(២) កុមារដែលមានឪពុកម្តាយរស់នៅក្នុងរដ្ឋផ្សេងនោះមានសិទ្ធិរក្សាចំណងមេត្រីភាពជាធម្មតានិងទាក់ទងផ្ទាល់ជាមួយឪពុកម្តាយរបស់ខ្លួនលើកលែងតែក្នុងកាលៈទេសៈជាពិសេសចេញ។ ក្នុងទិសដៅនោះ និងដោយស្របទៅតាមកាតព្វកិច្ចរបស់រដ្ឋជាភាគី ដែលមានចែងក្នុងមាត្រា៩កថាខណ្ឌ១នោះ មានន័យថារដ្ឋជាភាគីត្រូវគោរពសិទ្ធិរបស់កុមារ ឬ របស់ឪពុកម្តាយកុមារក្នុងការចាកចេញពីប្រទេសរួមទាំងពីប្រទេសរបស់ខ្លួនផង និងសិទ្ធិចូលមកក្នុងប្រទេសវិញ។ សិទ្ធិចាកចេញពីប្រទេសណាមួយអាចត្រូវរារាំងបានតាមបញ្ញត្តិច្បាប់ ហើយដែលចាំបាច់ដើម្បីការពារសន្តិសុខជាតិ របៀបរៀបរយសង្គម សុខភាពសាធារណៈ ឬ សីលធម៌ ឬសិទ្ធិសេរីភាពរបស់អ្នកដទៃដែលត្រូវបាន ទទួលស្គាល់ដោយអនុសញ្ញានេះ ។

មាត្រា១១

(១) រដ្ឋជាភាគីត្រូវប្រកាន់យកវិធានការនានាក្នុងការទប់មិនឱ្យមានការផ្ទេរចេញដោយខុសច្បាប់ និងការមិនត្រឡប់មកវិញរបស់កុមារដែលនៅឯបរទេស ។

(២) ក្នុងទិសដៅនេះ រដ្ឋជាភាគីត្រូវជំរុញការចុះកិច្ចព្រមព្រៀងជាទ្វេភាគី ឬជាពហុភាគី ឬចូលរួមក្នុងកិច្ចព្រមព្រៀងដែលមានស្រាប់ ។

មាត្រា១២

(១) រដ្ឋជាភាគីត្រូវធានាដល់កុមារដែលមានទស្សនៈផ្ទាល់ខ្លួនឱ្យមានសិទ្ធិបញ្ចេញទស្សនៈទាំងនោះដោយសេរីនៅក្នុងវិស័យទាំងអស់ដែលទាក់ទងនឹងកុមារ ។ ទស្សនៈរបស់កុមារនឹងត្រូវបានយកមកពិចារណាថ្លឹងថ្លែងសមស្របអាយុ និងចំណាស់ទុំរបស់កុមារនោះ ។

(២) ក្នុងចំណុចនេះកុមារត្រូវទទួលបានជាពិសេសនូវឱកាសក្នុងការស្តាប់នៅក្នុងដំណើរការច្បាប់ និងផ្នែករដ្ឋបាល ដែលទាក់ទងដល់កុមារ ក្នុងលក្ខណៈសមស្របទៅនឹងបញ្ញត្តិនៃនីតិក្រមរបស់ច្បាប់ជាតិ ទោះជាដោយផ្ទាល់ ឬ តាមរយៈអ្នកតំណាង ឬតាមរយៈស្ថាប័នសមស្របណាមួយក៏ដោយ ។

មាត្រា១៣

(១) កុមារមានសិទ្ធិសម្តែងមតិដោយសេរី សិទ្ធិនេះរួមបញ្ចូលទាំងសេរីភាពក្នុងការស្វែងរក សេរីភាពក្នុងការទទួលសេរីភាពក្នុងការផ្សាយព័ត៌មាន និងរាល់គំនិត ឬទស្សនៈដោយពុំគិតពីព្រំដែនអ្វីឡើយ ទោះជាការនិយាយស្តីការសរសេរ ឬការបោះពុម្ពក្នុងទម្រង់ជាសិល្បៈ ឬតាមរយៈបណ្តាញឃោសនាផ្សេងៗ ស្របទៅតាមការជ្រើសរើស របស់កុមារ ។

(២) ការប្រើប្រាស់សិទ្ធិនេះ អាចស្ថិតនៅក្នុងកម្រិតព្រំដែនមួយ ប៉ុន្តែការដាក់កំហិតនេះអាចប្រព្រឹត្តទៅបានលុះត្រាមានការកំណត់ដោយច្បាប់ និងមានការចាំបាច់ ។

ក- ដើម្បីការគោរពសិទ្ធិ និងកិត្តិនាមរបស់អ្នកដទៃ

ខ-ដើម្បីការពារសន្តិសុខជាតិ ឬ សណ្តាប់ធ្នាប់សាធារណៈ ឬ សុខភាពសាធារណៈ ឬ សីលធម៌ ។

មាត្រា១៤

(១) រដ្ឋជាភាគីត្រូវគោរពសិទ្ធិរបស់កុមារនៅផ្នែកខាងសេរីភាពនៃគំនិតមនសិកា និងសាសនា ។

(២) រដ្ឋជាភាគីត្រូវគោរពសិទ្ធិ និងកាតព្វកិច្ចរបស់ឪពុកម្តាយ និងអ្នកអាណាព្យាបាលស្របច្បាប់ ក្នុងការផ្តល់ឱ្យកុមារនូវការប្រើប្រាស់សិទ្ធិទាំងនេះតាមរបៀបមួយ ដែលស្របទៅនឹងការអភិវឌ្ឍសមត្ថភាពរបស់កុមារ ។

(៣) សេរីភាពក្នុងការសម្តែងនូវជំនឿឬសាសនាអាចដាក់ឱ្យមានកម្រិតព្រំដែនបានលុះត្រាមានកំណត់ដោយច្បាប់ ហើយជាការចាំបាច់ដើម្បីការពារសុវត្ថិភាពសាធារណៈ សុខភាព ឬ សីលធម៌ ឬសិទ្ធិ និងសេរីភាព ជាមូល ដ្ឋានគ្រឹះរបស់អ្នកដទៃ ។

មាត្រា១៥

(១) រដ្ឋជាភាគីទទួលស្គាល់សិទ្ធិរបស់កុមារផ្នែកខាងសេរីភាពនៃការចូលរួមជាសមាគម និងសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី ។

(២) គ្មានកំហិតណាមួយ ត្រូវបានដាក់ទៅលើការប្រើប្រាស់សិទ្ធិទាំងនេះទេ លើកលែងតែកំហិតនោះត្រូវបានកំណត់ដោយច្បាប់ ហើយចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ ដើម្បីផលប្រយោជន៍នៃសន្តិសុខ និងសុវត្ថិភាពសង្គម ឬ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខភាពសាធារណៈ ឬ សីលធម៌ ឬដើម្បីការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ។

មាត្រា១៦

(១) គ្មានកុមារណាម្នាក់ត្រូវបានទៅជាកម្មវត្ថុនៃការរំលោភបំពាន ឬជ្រៀតជ្រែកដោយខុសច្បាប់នៅក្នុងជីវិតជាឯកជន គ្រួសារ ទីលំនៅ ឬទំនាក់ទំនង ឬការបំពារបំពានដោយខុសច្បាប់លើកត្តិនាមរបស់គេបានឡើយ

(២) កុមារមានសិទ្ធិទទួលកិច្ចការពារដោយច្បាប់ប្រឆាំងនឹងការជ្រៀតជ្រែក ឬ រំលោភបំពានទាំងអស់នេះ ។

មាត្រា១៧

រដ្ឋជាភាគីទទួលស្គាល់តួនាទីដ៏សំខាន់របស់បណ្តាញឃោសនាមហាជន ហើយធានាថាកុមារទទួលបាននូវព័ត៌មាន និងឯកសារពីប្រភពផ្សេងៗផ្នែកជាតិ និងអន្តរជាតិជាពិសេសគឺព័ត៌មាន និងឯកសារសំដៅលើកស្ទួយសុខមាលភាពសង្គម ស្មារតី និងសីលធម៌ ហើយ និងសុខភាពផ្នែករាងកាយ និងសតិបញ្ញាក្នុងទិសដៅនេះរដ្ឋជាភាគីត្រូវ :

ក- លើកទឹកចិត្តបណ្តាញឃោសនាមហាជនឱ្យផ្សព្វផ្សាយព័ត៌មាន និងឯកសារដែលមានអត្ថប្រយោជន៍ផ្នែកសង្គម និងវប្បធម៌ដល់កុមារ និងស្របតាមស្មារតីនៃមាត្រា២៩។

ខ- លើកទឹកចិត្តកិច្ចសហប្រតិបត្តិការជាអន្តរជាតិក្នុងផលិតកម្ម បំលាស់ប្តូរ និងផ្សព្វផ្សាយនូវព័ត៌មាន និងឯកសារពីប្រភពផ្សេងៗនៃវប្បធម៌ជាតិ និងអន្តរជាតិ។

គ- លើកទឹកចិត្តដល់ផលិតកម្ម និងការផ្សព្វផ្សាយស្បៀវភៅសម្រាប់កុមារ។

ឃ-លើកទឹកចិត្តដល់បណ្តាញឃោសនាមហាជនឱ្យមានការគិតគូរ ជាពិសេសដល់តម្រូវការផ្នែកភាសារបស់កុមារដែលជាក្រុមជនជាតិភាគតិច ឬជាអ្នកស្រុកដើម។

ង- លើកទឹកចិត្តដល់ការអភិវឌ្ឍន៍នូវគោលការណ៍ដឹកនាំសមស្រប ដើម្បីការពារកុមារអំពីព័ត៌មាន និងឯកសារទាំងឡាយដែលប៉ះពាល់ដល់សុខមាលភាពរបស់កុមារ ដោយយោងលើបទបញ្ញាតិ៍នៃមាត្រា១៣ និង១៨។

មាត្រា១៨

(១) រដ្ឋជាភាគីត្រូវប្រឹងប្រែងអស់ពីលទ្ធភាព ដើម្បីធានាឱ្យមានការទទួលស្គាល់គោលការណ៍ដែលចែងថា ទាំងឪពុកទាំងម្តាយ សុទ្ធតែមានការទទួលខុសត្រូវរួមក្នុងការចិញ្ចឹមបីបាច់ និងការអភិវឌ្ឍរបស់កុមារ។ ឪពុកម្តាយ ឬអ្នកអាណាព្យាបាលស្របច្បាប់ (បើសិនជាមាន)សុទ្ធតែមានការទទួលខុសត្រូវជាចម្បងក្នុងការចិញ្ចឹមបីបាច់ និងក្នុងការអភិវឌ្ឍរបស់កុមារ។ ផលប្រយោជន៍ល្អបំផុតសម្រាប់កុមារ គឺជាទិសដៅមូលដ្ឋានបំផុត។

(២) ដើម្បីធានា និងលើកកម្ពស់សិទ្ធិទាំងឡាយដែលមានចែងនៅក្នុងអនុសញ្ញានោះរដ្ឋជាភាគីផ្តល់នូវជំនួយឧបត្ថម្ភសមស្របដល់ឪពុកម្តាយ និងអ្នកអាណាព្យាបាលស្របច្បាប់នៅក្នុងការចិញ្ចឹមបីបាច់កុមារ ហើយ និងធានាការអភិវឌ្ឍនូវស្ថាប័នផ្សេងៗ ការសម្របសម្រួល និងសេវាធានាដើម្បីថែទាំកុមារ ។

(៣) រដ្ឋជាភាគីត្រូវប្រកាន់យកវិធានការសមស្របនានា ដើម្បីធានាចំពោះកុមារដែលឪពុកម្តាយជាប់បំពេញការងារឱ្យមានសិទ្ធិទទួលបាននូវសេវាសមស្រប និងភាពងាយស្រួលក្នុងការថែទាំកុមារទៅតាមលក្ខខណ្ឌ ដែលពួកគេត្រូវទទួលបាន ។

មាត្រា១៩

(១) អ្នកជាភាគីប្រកាន់យកវិធានការច្បាប់រដ្ឋបាល សង្គម និងផ្នែកអប់រំនានា ដើម្បីការពារកុមារពីរាល់ទម្រង់អំពើហិង្សា ការរំលោភបំពានលើរាងកាយ ឬគំនិតបញ្ឆោ ការបោះបង់ ឬ ការមិនគិតគូរដល់ការធ្វើបាប រួមទាំង ការបំពានផ្លូវភេទ ក្នុងពេលដែលកុមារស្ថិតនៅក្រោមការបីបាច់ថែរក្សារបស់ឪពុក ឬម្តាយ ឬទាំងឪពុកម្តាយ អ្នកអាណាព្យាបាលស្របច្បាប់ ឬក៏បុគ្គលផ្សេងទៀតដែលទទួលថែរក្សាកុមារ។

(២)វិធានការការពារសមស្របទាំងនេះ រួមបញ្ចូលទាំងរាល់នីតិវិធីដ៏មានប្រសិទ្ធភាពក្នុងការបង្កើតឡើងនូវកម្មវិធីសង្គម ដើម្បីផ្តល់នូវកិច្ចគាំទ្រចាំបាច់ចំពោះកុមារ និងចំពោះអ្នកដែលទទួលថែទាំកុមារក៏ដូចជារាល់ទម្រង់ផ្សេងទៀត សម្រាប់បង្ការ និងដើម្បីរកឱ្យឃើញរបាយការណ៍ផ្អែកលើការអង្កេតការវិភាគពិនិត្យ និងតាមដានរាល់ករណីនៃការធ្វើបាបកុមារដែលបានលើកឡើងខាងលើហើយក្នុងករណីសមស្របអន្តរាគមន៍ផ្នែកផ្លូវច្បាប់ថែមទៀត។

មាត្រា២០

(១) កុមារដែលយកចេញជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍ពីមជ្ឈដ្ឋានគ្រួសាររបស់គេ ឬក៏ផលប្រយោជន៍ល្អបំផុតរបស់កុមារ មិនអនុញ្ញាតឱ្យកុមាររស់នៅក្នុងមជ្ឈដ្ឋាននោះបានត្រូវមានសិទ្ធិទទួលកិច្ចការពារជាពិសេស និងជំនួយឧបត្ថម្ភដែលផ្តល់ដោយរដ្ឋ។

(២) ដោយស្របទៅតាមច្បាប់ប្រទេសរបស់ខ្លួន រដ្ឋជាភាគីត្រូវធានានូវកិច្ចថែទាំក្នុងជម្រើសផ្សេងទៀត ដល់កុមារបែបនេះ។

(៣) កិច្ចថែទាំបែបនេះ រួមបញ្ចូលទាំងការដាក់ឱ្យចិញ្ចឹមទៅតាមគ្រួសារជាបែបកាហ្វាឡា (Kafalah) តាមច្បាប់អីស្លាមគឺការទទួលចិញ្ចឹមជាកូន ឬបើសិនជាចាំបាច់ការដាក់ឱ្យនៅតាមស្ថាប័នថែទាំកុមារ ដែលសមស្រប។ នៅក្នុងជម្រើសដំណោះស្រាយនេះ ត្រូវយកចិត្តទុកដាក់លើភាពចាំបាច់នៃនិរន្តរភាព នៃការថែទាំកុមារ និងប្រភពជាតិ សាសន៍ សាសនា វប្បធម៌ និងភាសារបស់កុមារ។

មាត្រា២១

រដ្ឋជាភាគីដែលទទួលស្គាល់ និងឬអនុញ្ញាតនូវប្រព័ន្ធសុំកូនចិញ្ចឹមត្រូវធានាថាផលប្រយោជន៍ល្អបំផុតរបស់កុមារគឺជាការពិចារណាពិនិត្យពិច័យដ៏ខ្ពស់បំផុតនៅក្នុងបញ្ហានេះហើយ :

(ក) ធានាថាការសុំកូនចិញ្ចឹមត្រូវបានអនុញ្ញាតដោយអាជ្ញាធរមានសមត្ថកិច្ចតែមួយគត់ ដែលនឹងកំណត់ដោយស្របទៅតាមនីតិវិធីនៃច្បាប់ និងឈរលើមូលដ្ឋាននៃព័ត៌មានត្រឹមត្រូវ និងទុកចិត្តបានហើយធានាថា ការសុំកូនចិញ្ចឹមនេះអាចធ្វើទៅបានអាស្រ័យដោយស្ថានភាពរបស់កុមារទាក់ទងទៅនឹងឪពុកម្តាយ សាច់ញាតិ និងអាណាព្យាបាលស្របច្បាប់ ហើយបើសិនជាចាំបាច់បុគ្គល ដែលមានទាក់ទងបានផ្តល់ការយល់ព្រមរបស់ខ្លួនលើការសុំកូនចិញ្ចឹមនេះ ដោយមានការផ្អែកលើការយល់ដឹងច្បាស់លាស់ និងបានទទួលការបំភ្លឺជាចាំបាច់រួចមក។

(ខ) ទទួលស្គាល់ថា ការសុំកូនចិញ្ចឹមជាអន្តរប្រទេសអាចចាត់ទុកជាជម្រើសមួយនៃការថែទាំកុមារ ប្រសិនបើកុមារមិនអាចបញ្ចូលឱ្យទៅរស់នៅតាមគ្រួសារ ឬមានការសុំកូនចិញ្ចឹមតាមគ្រួសារ ឬមិនអាចទទួល បាន នូវការថែទាំឱ្យបានសមស្របនៅក្នុងប្រទេសដើមកំណើតរបស់ខ្លួន។

(គ) ធានាថាកុមារដែលត្រូវគេសុំយកទៅចិញ្ចឹមនៅឯប្រទេសផ្សេងនោះទទួលបាននូវកិច្ចការពារ និងបទដ្ឋាននានាដូចគ្នាទៅនឹងកិច្ចការពារ ហើយនឹងបទដ្ឋាននានាដែលមាននៅក្នុងប្រទេស។

(ឃ) ប្រកាន់យកនូវរាល់វិធានការសមស្របនានា ដើម្បីធានាថាការសុំកូនចិញ្ចឹមជាអន្តរប្រទេស ការផ្តល់កូននេះមិនមែនជាលទ្ធផលនៃការចំណេញផ្នែកហិរញ្ញវត្ថុមិនត្រឹមត្រូវសម្រាប់រាល់បុគ្គលដែលមានការទាក់ទងក្នុងរឿងនេះឡើយ។

(ង) ក្នុងករណីដែលសមស្រប ជំរុញគោលដៅនៃមាត្រានេះដោយមានការចុះកិច្ចព្រមព្រៀង ឬកិច្ចសម្រុះសម្រួលជាទ្វេភាគី ឬជាពហុភាគី ហើយដោយក្របខណ្ឌនេះប្រឹងប្រែងធានាឱ្យបានថា ការយកកុមារទៅឱ្យគេចិញ្ចឹមនៅឯប្រទេសផ្សេងត្រូវចាត់ចែងឡើងដោយអង្គការ ឬអាជ្ញាធរមានសមត្ថកិច្ច។

មាត្រា២២

១-រដ្ឋភាគីប្រកាន់យកនូវរាល់វិធានការសមស្របទាំងឡាយ ដើម្បីធានាឱ្យកុមារដែលស្វែងរកឋានៈជាអ្នកភៀសខ្លួន ឬដែលត្រូវចាត់ទុកជាអ្នកភៀសខ្លួន ដោយស្របទៅតាមនីតិវិធីដែលអាចអនុវត្តបានតាមច្បាប់អន្តរជាតិ ឬច្បាប់ជាតិ ទោះជាកុមារនោះតែម្នាក់ឯង ឬមានឪពុកម្តាយ ឬអ្នកដទៃទៀតមកជាមួយក្តីក៏កុមារទទួលបាននូវកិច្ចគាំពារ និងជំនួយឧបត្ថម្ភមនុស្សធម៌ដ៏សមស្របក្នុងការប្រើប្រាស់សិទ្ធិ ដែលអាចអនុវត្តបានក្នុងប្រការនេះ ហើយដែលចែងក្នុងអនុសញ្ញានេះ និងនៅក្នុងឯកសារអន្តរជាតិនានាស្តីពីសិទ្ធិមនុស្ស ឬមនុស្សធម៌ដែលសាមីរដ្ឋបានចូលជាភាគី។

២-ក្នុងទិសដៅនេះ ប្រសិនបើពិនិត្យថាសមស្របរដ្ឋជាភាគីនឹងផ្តល់កិច្ចសហប្រតិបត្តិការដល់កិច្ចប្រឹងប្រែងរបស់អង្គការសហប្រជាជាតិ និងអង្គការអន្តររដ្ឋាភិបាល ឬអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើសហការជាមួយអង្គការសហប្រជាជាតិ ដើម្បីគាំពារ និងជួយឧបត្ថម្ភកុមារទាំងនោះ ហើយនិងស្វែងរកឪពុកម្តាយ ឬសមាជិកដទៃ ទៀតនៃគ្រួសាររបស់កុមារភៀសខ្លួនទាំងនេះ ដើម្បីទទួលបាននូវព័ត៌មានចាំបាច់សម្រាប់ការជួបជុំគ្រួសារឡើងវិញ។ ដូចមានចែងក្នុងអនុសញ្ញានេះស្រាប់ក្នុងករណីដែលរកមិនឃើញឪពុកម្តាយ ឬសមាជិកដទៃទៀតនៃគ្រួសារនោះទេកុមារត្រូវទទួលបានកិច្ចគាំពារដូចគ្នានឹងកុមារដែលបានបែកចេញជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្នពីមជ្ឈដ្ឋាន គ្រួសារខ្លួនទោះជាអំពីមូលហេតុអ្វីក៏ដោយ។

មាត្រា ២៣

(១) រដ្ឋជាភាគីទទួលស្គាល់ថា កុមារដែលមានពិការភាពផ្នែកសតិបញ្ញា ឬរាងកាយគួរទទួលបាននូវជីវភាពរស់នៅសមរម្យ និងពេញលេញក្នុងលក្ខខណ្ឌដែលធានានូវភាពថ្លៃថ្នូរ ជំរុញនូវភាពម្ចាស់ការហើយដែលជួយសម្រួលឱ្យ កុមារអាចចូលរួមយ៉ាងសកម្មនៅក្នុងសហគមន៍។

(២) រដ្ឋជាភាគីទទួលស្គាល់សិទ្ធិកុមារពិការក្នុងការទទួលបាននូវការថែទាំពិសេស ហើយជំរុញ និងពង្រីកនូវជំនួយឧបត្ថម្ភតាមធនធានដែលមានឱ្យដល់កុមារ និងអ្នកទទួលខុសត្រូវក្នុងការថែទាំកុមារ ដែលមានលក្ខណៈបែបនេះ ប្រសិនបើមានសំណើសមស្របទៅនឹងស្ថានភាពរបស់កុមារ និងរបស់ឪពុកម្តាយ ឬអ្នកទទួលថែទាំកុមារនោះ។

(៣) ដោយទទួលស្គាល់ពីតម្រូវការពិសេសរបស់កុមារពិការជំនួយឧបត្ថម្ភដែលផ្តល់ដោយស្របទៅតាមកថាខណ្ឌ២នៃមាត្រានេះ ត្រូវតែផ្តល់ឱ្យដោយឥតគិតថ្លៃបើសិនជាមានលទ្ធភាព ដោយផ្អែកលើធនធានហិរញ្ញវត្ថុរបស់ឪពុកម្តាយ ឬរបស់អ្នកឯទៀតដែលទទួលថែទាំកុមារ ហើយត្រូវគិតគូរយ៉ាងណាដើម្បីឱ្យកុមារពិការអាចឈោងចាប់យកបាន និងទទួលបានដោយផ្ទាល់នូវការអប់រំបណ្តុះបណ្តាលសេវាថែទាំសុខភាព កិច្ចទំនុកបំរុងឱ្យមានសម្បទាឡើងវិញ ការរៀបចំខ្លួនដើម្បីបំពេញការងារ និងការ

សំរាកលំហែកាយក្នុងលក្ខណៈដែលអាចនាំឱ្យកុមារសម្របខ្លួនបានយ៉ាងពេញលេញទៅក្នុងសង្គម និងការអភិវឌ្ឍន៍បុគ្គលិកលក្ខណៈរួមបញ្ចូលទាំងការអភិវឌ្ឍន៍ផ្នែកវប្បធម៌ និងស្មារតី។

(៤) នៅក្នុងស្មារតីនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ រដ្ឋជាភាគីនឹងជំរុញឱ្យមានការផ្លាស់ប្តូរព័ត៌មានសមស្របទៅក្នុងកិច្ចបង្ការការការពារសុខភាព ហើយនិងការព្យាបាលផ្នែកវេជ្ជសាស្ត្រ ចិត្តសាស្ត្រ និងដំណើរមុខងារសរីរាង្គដល់កុមារពិការ រួមបញ្ចូលទាំងការផ្សាយ និងការអនុញ្ញាតឱ្យទទួលបាននូវព័ត៌មានទាក់ទងទៅនឹងវិធីធ្វើឱ្យមានសម្បទាឡើងវិញ ការងារអប់រំ និងការអប់រំវិជ្ជាជីវៈក្នុងទិសដៅអាចឱ្យរដ្ឋជាភាគីបង្កើនសមត្ថភាព និងជំនាញដើម្បីបើកទូលាយបទពិសោធន៍របស់ខ្លួន។ ក្នុងចំណុចនេះត្រូវយកចិត្តទុកដាក់ជាពិសេស លើតម្រូវការនៃប្រទេសកំពុងអភិវឌ្ឍ។

មាត្រា២៤

(១) រដ្ឋជាភាគីទទួលស្គាល់សិទ្ធិរបស់កុមារក្នុងការទទួលបាននូវកម្រិតសុខភាពខ្ពស់បំផុត ដែលអាចធ្វើទៅបាន និងទទួលបាននូវភាពងាយស្រួលក្នុងការព្យាបាលជំងឺ និងស្តារសុខភាព។ រដ្ឋជាភាគីនឹងប្រឹងប្រែងធានាឱ្យបានថា គ្មានកុមារណាម្នាក់ត្រូវបាត់បង់សិទ្ធិទទួលយកសេវាថែទាំសុខភាពឡើយ។

(២) រដ្ឋជាភាគីប្រឹងប្រែងធ្វើឱ្យបានសម្រេចទាំងស្រុងនូវសិទ្ធិនេះ ជាពិសេសនឹងប្រកាន់យកនូវវិធានការសមស្របទាំងឡាយ

ក-កាត់បន្ថយមរណៈភាពទារក និងកុមារ។

ខ-ធានាផ្តល់ជំនួយចាំបាច់ផ្នែកវេជ្ជសាស្ត្រ និងការថែទាំសុខភាពគ្រប់កុមារទាំងអស់ដោយផ្តោតទៅលើការថែទាំសុខភាពបឋម។

គ-កំចាត់រោគ និងជំងឺកង្វះអាហារ ដោយរួមបញ្ចូលទាំងក្របខណ្ឌនៃការថែទាំសុខភាពបឋមតាមរយៈការអនុវត្តបច្ចេកវិទ្យាដែលមានស្រាប់ និងងាយរក និងតាមរយៈការផ្គត់ផ្គង់ឱ្យបានគ្រប់គ្រាន់នូវអាហារូបត្ថម្ភ និងទឹកស្អាតដោយយោងទៅលើគ្រោះថ្នាក់ និងភាពប្រថុយប្រថានដែលបណ្តាលពីភាពកខ្វក់នៃបរិស្ថាន។

ឃ-ធានានូវការថែទាំសុខភាពមាតានៅមុនពេល និងក្រោយពេលសំរាលកូន។

ង-ធានាថាគ្រប់ក្រុមនៅក្នុងសង្គមជាពិសេសឪពុកម្តាយ និងកុមារទទួលបាននូវព័ត៌មានស្តីពីការអប់រំ និងទទួលបាននូវការគាំទ្រក្នុងការប្រើប្រាស់ចំណេះដឹងជាមូលដ្ឋានអំពីសុខភាពកុមារ និងអាហារូបត្ថម្ភ អត្ថប្រយោជន៍នៃការបំបៅកូនដោយទឹកដោះ អនាម័យ និងការសំអាតបរិស្ថាន ហើយនិងការការពារបង្ការគ្រោះថ្នាក់។

ច-អភិវឌ្ឍកិច្ចការពារការថែទាំសុខភាព ផ្តល់ការណែនាំដល់ឪពុកម្តាយ ហើយនឹងផ្តល់សេវា និង
ការអប់រំ ស្តីពីផែនការនីយកម្មគ្រួសារ ។

(៣) រដ្ឋជាភាគីប្រកាន់យកវិធានការដ៏មានប្រសិទ្ធភាព និងសមស្របក្នុងទិសដៅលុបបំបាត់នូវការអនុវត្ត
តាមទំនៀមទំលាប់ប្រពៃណីដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពកុមារ ។

(៤) រដ្ឋជាភាគីនឹងជំរុញ និងលើកទឹកចិត្តកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងទិសដៅឈានធ្វើឱ្យបានសម្រេច
ទាំងស្រុងនូវសិទ្ធិដែលបានទទួលស្គាល់នៅក្នុងមាត្រានេះ ។

ក្នុងប្រការនេះជាពិសេសត្រូវបានយកចិត្តទុកដាក់លើតម្រូវការរបស់ប្រទេសកំពុងអភិវឌ្ឍ ។

មាត្រា ២៥

រដ្ឋជាភាគីទទួលស្គាល់ចំពោះកុមារដែលបានទទួលយកមករក្សាដោយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីថែទាំ
ការពារ ឬព្យាបាលផ្នែករាងកាយ ឬសតិបញ្ញានូវសិទ្ធិទទួលបានការពិនិត្យជាទ្បើងទាត់លើការព្យាបាល ថែទាំ
ដែលបានផ្តល់ទៅឱ្យកុមារនោះ និងពិនិត្យទៅលើកាល:ទេស:ផ្សេងៗទ្បើតដែលទាក់ទងទៅនឹងការស្នាក់នៅរបស់
កុមារនោះ ។

មាត្រា ២៦

(១) រដ្ឋជាភាគីទទួលស្គាល់នូវសិទ្ធិរបស់កុមារគ្រប់រូប ក្នុងការទទួលបាននូវអត្ថប្រយោជន៍ ពីសន្តិសុខសង្គម
ដោយរួមទាំងការធានារ៉ាប់រងសង្គម និងប្រកាន់យករាល់វិធានការចាំបាច់ ដើម្បីធានាឱ្យបានសម្រេច
ទាំងស្រុងនូវ សិទ្ធិ នេះដោយស្របទៅតាមច្បាប់ក្នុងប្រទេសរបស់ពួកគេ ។

(២) គុណប្រយោជន៍ បើសិនជាមានត្រូវបានផ្តល់ឱ្យដោយគិតគូទៅលើធនធាន និងស្ថានភាពរបស់កុមារ និង
អ្នកដែលទទួលខុសត្រូវក្នុងការចិញ្ចឹមបីបាច់កុមារដូចជាយោងទៅលើចំណុចថ្នឹងថ្លែងផ្សេងទ្បើត ដែល
ទាក់ទងទៅនឹងសំណើសុំគុណប្រយោជន៍ផ្សេងទ្បើតដែលបានស្នើឡើងដោយកុមារ ឬក្នុងនាមកុមារ
នោះ ។

មាត្រា ២៧

(១) រដ្ឋជាភាគីទទួលស្គាល់ថា កុមារគ្រប់រូបមានសិទ្ធិក្នុងការមានកម្រិតជីវភាពរស់នៅសមរម្យ ធានាដល់
ការអភិវឌ្ឍន៍ផ្នែករាងកាយ សតិបញ្ញាស្មារតី សីលធម៌ និងសង្គមរបស់កុមារបាន ។

(២) ឪពុកម្តាយ ឬអ្នកឯទ្បើតដែលទទួលខុសត្រូវលើកុមារមានភារកិច្ចទទួលខុសត្រូវជាចម្បងក្នុងការធានា
នូវកម្រិតលទ្ធភាព និងសមត្ថភាពហិរញ្ញវត្ថុរបស់ខ្លួននូវកម្រិតជីវភាពរស់នៅមួយ ដែលចាំបាច់ដល់ការ
អភិវឌ្ឍន៍របស់កុមារ ។

(៣) ដោយយោងទៅតាមស្ថានភាពប្រទេស និងប្រភពធនធានរបស់ខ្លួន រដ្ឋជាភាគីនឹងប្រកាន់យកនូវវិធានការសមស្រប ដើម្បីជួយឧបត្ថម្ភដល់ឪពុកម្តាយ ឬអ្នកដែលទទួលខុសត្រូវលើកុមារក្នុងការអនុវត្តន៍សិទ្ធិនេះ ហើយនៅពេលដែលមានតម្រូវការនឹងត្រូវផ្តល់ជំនួយឧបត្ថម្ភផ្នែកសម្ភារ ហើយនិង កម្មវិធីគាំទ្រទាំងឡាយជាពិសេស ការផ្តល់អាហារូបត្ថម្ភ សំលៀកបំពាក់ និងផ្ទះសំបែង។

(៤) រដ្ឋជាភាគីប្រកាន់យកវិធានការសមស្រប ដើម្បីធានាឱ្យកុមារទទួលបានសោធនអាហារកិច្ចពីឪពុកម្តាយ ឬពីអ្នកដទៃទៀតដែលទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុលើកុមារទាំងរស់នៅក្នុង និងក្រៅប្រទេស។ ជាពិសេស នៅពេលដែលអ្នកទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុលើកុមាររស់នៅក្នុងរដ្ឋផ្សេងពីកុមារ ទោះរដ្ឋជាភាគីឱ្យមានកិច្ចព្រមព្រៀងជាអន្តរជាតិ ឬការសម្រេចកិច្ចព្រមព្រៀងបែបនេះក៏ដូចជាការព្រមព្រៀងផ្សេងៗទៀតដែលសមស្រប។

មាត្រា២៨

(១) រដ្ឋជាភាគីទទួលស្គាល់សិទ្ធិរបស់កុមារក្នុងការទទួលបានការអប់រំជាពិសេសក្នុងទិសដៅឈានឡើងទៅសម្រេចបាននូវសិទ្ធិនេះ និង ដោយឈរលើមូលដ្ឋាននៃលទ្ធភាពស្មើគ្នាជាពិសេស :

ក-ធ្វើឱ្យការសិក្សាកម្រិតបឋមសិក្សាមានលក្ខណៈជាកាតព្វកិច្ច និងឥតបង់ថ្លៃសម្រាប់គ្រប់ៗគ្នា។

ខ-លើកទឹកចិត្តដល់ការអភិវឌ្ឍន៍ទម្រង់នានាផ្នែកមធ្យមសិក្សារួមទាំងផ្នែកចំណេះទូទៅ និងការអប់រំវិជ្ជាជីវៈបើកទូលាយឱ្យដល់គ្រប់កុមារ ហើយនិងប្រកាន់យកនូវវិធានការសមស្របនានាដូចជាការបញ្ចូលការសិក្សាដោយឥតបង់ថ្លៃ និងការផ្តល់ជំនួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុករណីដែលមានតម្រូវការ។

គ-ធានាតាមគ្រប់មធ្យោបាយ ដើម្បីឱ្យកុមារទាំងអស់អាចទទួលបានការសិក្សាកម្រិតឧត្តមទៅតាមសមត្ថភាពរបស់ពួកគេ។

ឃ-បើកទូលាយនូវព័ត៌មាន និងការណែនាំតម្រង់ទិសផ្នែកអប់រំ និងអប់រំវិជ្ជាជីវៈដល់គ្រប់កុមារទាំងអស់។

ង-ប្រកាន់យកនូវវិធានការធានាក្នុងការលើកទឹកចិត្តការសិក្សាជាទ្បើងទាត់នៅក្នុងសាលា និងកាត់បន្ថយអត្រាបោះបង់ការសិក្សា។

(២) រដ្ឋជាភាគីប្រកាន់យកនូវវិធានការសមស្របក្នុងការធានាថាវិន័យសាលា ត្រូវបានរៀបចំក្នុងលក្ខណៈមួយដែលស្របគ្នាទៅនឹងភាពថ្លៃថ្នូរជាមនុស្សរបស់កុមារ និងស្របទៅតាមអនុសញ្ញានេះ។

(៣) រដ្ឋជាភាគី និងលើកទឹកចិត្តកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងវិស័យនានា ដែលទាក់ទងនឹងការអប់រំជាពិសេសក្នុងទស្សនៈរួមចំណែកលុបបំបាត់ភាពល្ងង់ខ្លៅ និងអនក្ខរភាពនៅទូទាំងពិភពលោក ហើយ

និងសម្រួលដល់ ការឈោងចាប់យកនូវចំណេះដឹងដែលមានលក្ខណៈជាវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងវិធីបង្រៀនតាមបែបទំនើបក្នុងចំណុចនេះត្រូវយកចិត្តទុកដាក់ជាពិសេសដល់តម្រូវការរបស់ប្រទេសកំពុងអភិវឌ្ឍ ។

មាត្រា ២៩

សេចក្តីអធិប្បាយទូទៅលើការប្រតិបត្តិនៃមាត្រានេះ

(១) រដ្ឋជាភាគីឯកភាពថាការអប់រំកុមារត្រូវតែឆ្ពោះទៅរក :

ក-ការអភិវឌ្ឍន៍បុគ្គលិកលក្ខណៈរបស់កុមារ ហើយនិងការអភិវឌ្ឍន៍យ៉ាងពេញលេញនៃទេពកោសល្យ និង សមត្ថភាពផ្នែករាងកាយ និងសតិបញ្ញារបស់កុមារ ។

ខ-ការអភិវឌ្ឍន៍នៃការគោរពសិទ្ធិមនុស្ស និងគ្រឹះនៃសេរីភាពក៏ដូចជាការគោរពនូវគោលការណ៍ដែលមានចារទុកនៅក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ

គ-ការអភិវឌ្ឍនៃការគោរពឪពុកម្តាយរបស់កុមារអត្តសញ្ញាណ វប្បធម៌ ភាសា និងតម្លៃរបស់ខ្លួនគេផ្ទាល់ គោរពតម្លៃជាតិនៃប្រទេសដែលកុមារកំពុងរស់នៅ ប្រទេសដែលជាដើមកំណើតរបស់កុមារ និងអារ្យធម៌ដែលខុសប្លែកៗគ្នាពីអារ្យធម៌របស់គេផ្ទាល់ ។

ឃ-ការត្រៀមរបស់កុមារចំពោះជីវិតប្រកបដោយការទទួលខុសត្រូវនៅក្នុងសង្គមមានសេរីភាពក្នុងស្មារតី នៃការយោគយល់ សន្តិភាព ភាពអនុគ្រោះ ភាពស្មើគ្នារវាងភេទ ហើយនិងមិត្តភាពរវាងប្រជាជនទាំងអស់ ពូជសាសន៍ ជាតិ ក្រុមសាសនា និងរវាងបុគ្គលដែលមានប្រភពជាអ្នកស្រុកដើម ។

ង- ការរីកចម្រើននៃការគោរពបរិស្ថានធម្មជាតិ ។

(២) គ្មានផ្នែកណាមួយនៃការបង្ហាញក្នុងមាត្រានេះ ឬមាត្រា ២៨ ដែលត្រូវបានយកមកបកស្រាយប៉ះពាល់ទៅលើសេរីភាពរបស់បុគ្គល ឬស្ថាប័នដែលបានបង្កើត និងដឹកនាំគ្រឹះស្ថានសិក្សា ក្នុងលក្ខខណ្ឌនៃគោលការណ៍ដែលបានចែងនៅក្នុងកថាខណ្ឌ១នៃមាត្រានេះ ហើយការអប់រំដែលត្រូវបានផ្តល់ក្នុងគ្រឹះស្ថានសិក្សានោះត្រឹមត្រូវតាមបទដ្ឋានអប្បបរមាដែលបានកំណត់ឡើងដោយរដ្ឋ ។

មាត្រា ៣០

នៅក្នុងរដ្ឋដែលមានក្រុមជនជាតិភាគតិច សាសនា ឬភាសា ឬមានបុគ្គលជាអ្នកស្រុកដើម កុមារដែលស្ថិតនៅក្នុងក្រុមជនជាតិភាគតិច ឬជាអ្នកស្រុកដើមនោះមិនត្រូវបានហូតសិទ្ធិចូលរួមជាមួយនឹងសមាជិកឯទៀតនៃសមាគមរបស់ខ្លួនឡើយនៅក្នុងជីវភាព វប្បធម៌ ការផ្សព្វផ្សាយ និងគោរពសាសនា ឬប្រើប្រាស់ភាសារបស់ខ្លួនផ្ទាល់ ។

មាត្រា ៣១

(១) រដ្ឋជាភាគីទទួលស្គាល់សិទ្ធិរបស់កុមារក្នុងការសំរាក និងកំសាន្ត ការលេងល្បែងកំសាន្ត និងសកម្មភាពលំហែសមស្របទៅតាមអាយុរបស់កុមារ និងសិទ្ធិចូលរួមដោយសេរីនៅក្នុងជីវភាព វប្បធម៌ និងសិល្បៈ។

(២) រដ្ឋជាភាគីគោរពសិទ្ធិរបស់កុមារក្នុងការរួមចំណែកយ៉ាងពេញលេញនៅក្នុងជីវភាព វប្បធម៌ និងសិល្បៈ ហើយនឹងលើកទឹកចិត្តដល់ផ្តល់លទ្ធភាពសមស្រប និងដោយស្មើភាពនូវការលំហែ និងសកម្មភាពកំសាន្តផ្នែកវប្បធម៌ និងសិល្បៈ។

មាត្រា ៣២

(១) រដ្ឋជាភាគីទទួលស្គាល់សិទ្ធិរបស់កុមារ ក្នុងការទទួលបាននូវកិច្ចការពារពីការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច ពីការបំពេញការងារណាដែលអាចប៉ះពាល់ ឬដែលអាចរំខានដល់ការអប់រំរបស់កុមារ ឬដែលអាចបំផ្លាញសុខភាព ឬការអភិវឌ្ឍន៍ផ្នែករាងកាយ សតិបញ្ញា ស្មារតី សីលធម៌ និងសង្គមរបស់កុមារ។

(២) រដ្ឋជាភាគីនឹងប្រកាន់យកវិធានការច្បាប់ រដ្ឋបាល សង្គម និងអប់រំ ដើម្បីធានាដល់ការអនុវត្តន៍មាត្រានេះ។ ក្នុងចំណុចនេះនិងដោយយោងទៅលើបទបញ្ញត្តិដែលទាក់ទងឯកសារអន្តរជាតិផ្សេងៗទៀត រដ្ឋជាភាគីពិសេស

ក- កំណត់អាយុអប្បបរមា ឬរាល់អាយុអប្បបរមាសម្រាប់ទទួលឱ្យចូលធ្វើការ

ខ-កំណត់នូវបញ្ញត្តិសមស្របស្តីពីម៉ោងពេល និងលក្ខខណ្ឌការងារ

គ-កំណត់នូវទោស និងទណ្ឌកម្មផ្សេងៗដ៏សមស្របដើម្បីធានាដល់ការអនុវត្តន៍ប្រកបដោយប្រសិទ្ធិភាពនូវមាត្រានេះ។

មាត្រា៣៣

រដ្ឋជាភាគីប្រកាន់យកវិធានការសមស្រប រួមទាំងវិធានការច្បាប់ រដ្ឋបាល សង្គម និងអប់រំ ដើម្បីការពារកុមារពីការប្រើប្រាស់ខុសច្បាប់នូវគ្រឿងញៀន និងសារជាតិទាក់ទងទៅនឹងចិត្តសាស្ត្រដូចដែលត្រូវបានកំណត់ដោយសន្ធិសញ្ញាអន្តរជាតិនានាដែលទាក់ទងទៅនឹងបញ្ហានេះក៏ដូចជាដើម្បីបង្ការការប្រើប្រាស់កុមារក្នុងការផលិត និងជួញដូរដោយខុសច្បាប់នូវប្រភេទសារជាតិទាំងនេះ។

មាត្រា៣៤

រដ្ឋជាភាគីសន្យាថានឹងការពារកុមារពីរាល់ទម្រង់នៃការកេងប្រវ័ញ្ច និងការរំលោភផ្លូវភេទ។ ក្នុងទិសដៅនេះ រដ្ឋជាភាគីប្រកាន់យកជាពិសេសនូវវិធានការសមស្របក្នុងក្របខណ្ឌជាតិ ទ្វេភាគី និងពហុភាគីដើម្បីការពារ :

ក-ការញុះញង់ ឬការបង្ខិតបង្ខំកុមារឱ្យប្រព្រឹត្តសកម្មភាពផ្លូវភេទដោយខុសច្បាប់

ខ-ការប្រើប្រាស់កុមារក្នុងអាជីវកម្មពេស្យាចារ ឬរាល់ការប្រព្រឹត្តផ្លូវភេទដោយខុសច្បាប់ផ្សេងទៀត

គ-ការប្រើប្រាស់កុមារក្នុងអាជីវកម្មសម្តែង ឬផលិតជាសម្ភារៈផ្ទែកអាសគ្រាម ។

មាត្រា៣៥

រដ្ឋជាភាគីនឹងប្រកាន់យកនូវរាល់វិធានការសមស្របក្នុងក្របខណ្ឌជាតិទ្វេភាគី ឬពហុភាគី ដើម្បីការពារមិនឱ្យមានការចាប់ពង្រត់ ការលក់ ឬជួញដូរកុមារទោះជាក្នុងទិសដៅ ឬក្នុងទម្រង់ណាក៏ដោយ ។

មាត្រា៣៦

រដ្ឋជាភាគីការពារកុមារពីរាល់ទម្រង់ផ្សេងទៀតនៃការកេងប្រវ័ញ្ច ដែលប៉ះពាល់ដល់គ្រប់ទិដ្ឋភាពនៃសុខុមាលភាពរបស់កុមារ ។

មាត្រា៣៧

រដ្ឋជាភាគីធានាថា

ក-គ្មានកុមារណាម្នាក់ត្រូវរងទារុណកម្ម ឬទទួលការផ្តន្ទាទោស ឬការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅអមនុស្សធម៌ ឬដែលនាំឱ្យបាត់បង់តម្លៃជាមនុស្សឡើយ ។ ការប្រហារជីវិត និងការឃុំឃាំងអស់មួយជីវិត ដោយគ្មានលទ្ធភាពដោះលែងមិនត្រូវអនុវត្តចំពោះបទល្មើស ដែលត្រូវបានប្រព្រឹត្តដោយបុគ្គលដែលមានអាយុតិចជាងដប់ប្រាំបីឆ្នាំឡើយ ។

ខ-គ្មានកុមារណាម្នាក់ត្រូវបានដកហូតសេរីភាពដោយខុសច្បាប់ ឬដោយតាមឯកចិត្តនោះឡើយ ។ ការចាប់ខ្លួន ការឃុំខ្លួន ឬការដាក់ពន្ធនាគារចំពោះកុមារត្រូវតែស្របច្បាប់ ហើយត្រូវបានប្រើតែសម្រាប់វិធានការចុងក្រោយ ហើយសម្រាប់តែក្នុងរយៈពេលយ៉ាងខ្លីដោយសមស្រប ។

គ-រាល់កុមារដែលត្រូវបានដកហូតសេរីភាព ត្រូវទទួលបាននូវការប្រព្រឹត្តទៅលើប្រកបដោយមនុស្សធម៌ និងដោយការគោរពចំពោះភាពថ្លៃថ្នូររបស់បុគ្គលជាមនុស្ស ហើយនិងក្នុងលក្ខណៈមួយដែលស្របទៅតាមតម្រូវការរបស់បុគ្គលក្នុងអាយុនោះ ។ ជាពិសេសរាល់កុមារដែលត្រូវបានដកហូតសេរីភាព ត្រូវតែបំបែកចេញពីមនុស្សពេញវ័យ លើកលែងតែផលប្រយោជន៍ល្អបំផុតរបស់កុមារតម្រូវមិនឱ្យធ្វើយ៉ាងនេះ ហើយកុមារត្រូវមានសិទ្ធិរក្សាទំនាក់ទំនងជាមួយគ្រួសារខ្លួនតាមរយៈការឆ្លើយឆ្លង និងការជួបសួរសុខទុក្ខលើកលែងតែក្នុងកាលៈទេសៈពិសេសដោយឡែក ។

ឃ-រាល់កុមារដែលត្រូវបានបំបិទសេរីភាព មានសិទ្ធិទទួលបានយ៉ាងរហ័សនូវការជួយឧបត្ថម្ភផ្នែកច្បាប់ និងក្នុងផ្នែកផ្សេងៗទៀតដែលសមស្របក៏ដូចជាសិទ្ធិក្នុងការតវ៉ាពីកិត្យានុកូលភាព នៃការដកហូតសេរីភាព

ខ្លួននេះ នៅចំពោះមុខតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចឯករាជ្យ និងមិនលំអៀង និងសិទ្ធិទទួលបានសេចក្តីសម្រេចយ៉ាងរហ័សចំពោះទង្វើនេះ។

មាត្រា៣៨

(១) រដ្ឋជាភាគីសន្យាគោរព និងធានាឱ្យមានការគោរពនូវបញ្ញត្តិច្បាប់មនុស្សធម៌អន្តរជាតិ ដែលត្រូវអនុវត្តមកលើខ្លួនពួកគេនៅក្នុងជម្លោះដោយអាវុធ ហើយដែលទាក់ទងដល់កុមារ។

(២) រដ្ឋជាភាគីប្រកាន់យកវាល់វិធានការដែលអាចធ្វើទៅបាន ដើម្បីធានាថាបុគ្គលដែលមិនទាន់ដល់អាយុ ១៥ ឆ្នាំ មិនត្រូវឱ្យចូលរួមដោយផ្ទាល់នៅក្នុងចំបាំងឡើយ។

(៣) រដ្ឋជាភាគីច្បៀសវាងមិនកេណ្ឌរើសបុគ្គល ដែលមានអាយុមិនទាន់ដល់១៥ឆ្នាំឱ្យចូលក្នុងកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនឡើយ។ ពេលកេណ្ឌរើសក្នុងចំណោមបុគ្គល ដែលមានអាយុចាប់ពី ១៥ ឆ្នាំ ឡើងទៅតែមិនទាន់ដល់អាយុ ១៨ ឆ្នាំ នោះរដ្ឋជាភាគីនឹងប្រឹងប្រែងជ្រើសរើសជាអាទិភាពអ្នកដែលមានអាយុច្រើនជាងគេ។

(៤) ស្របទៅតាមកាតព្វកិច្ចរបស់ខ្លួន ក្រោមច្បាប់មនុស្សធម៌អន្តរជាតិដែលត្រូវការពារប្រជាជនស៊ីវិលនៅក្នុងជម្លោះដោយអាវុធរដ្ឋជាភាគីនឹងប្រកាន់យកនូវរាល់វិធានការដែលអាចធ្វើបានដើម្បីធានាកិច្ចការពារ និងថែទាំដល់កុមារដែលត្រូវប៉ះពាល់ដោយជម្លោះអាវុធ។

មាត្រា៣៩

រដ្ឋជាភាគីប្រកាន់យករាល់វិធានការសមស្របទាំងអស់ ដើម្បីជំរុញការស្តារផ្នែករាងកាយ និងចិត្តសាស្ត្រ ក៏ដូចជាការបញ្ចូលក្នុងសង្គមវិញនូវកុមារដែលរងគ្រោះដោយការមិនបានថែទាំ ការកេងប្រវ័ញ្ច ឬការរំលោភបំពានទារុណកម្ម ឬទម្រង់ផ្សេងទៀតនៃការប្រព្រឹត្ត ឬផ្តន្ទាទោសដែលឃោរឃៅអមនុស្សធម៌ ឬដោយជម្លោះអាវុធ។ការស្តារឡើងវិញ និងការបញ្ចូលក្នុងសង្គមវិញ ត្រូវប្រព្រឹត្តទៅក្នុងលក្ខណៈដែលអំណោយផលដល់សុខភាព ការគោរពខ្លួនឯង និងភាពថ្លៃថ្នូររបស់កុមារ។

មាត្រា៤០

(១) រដ្ឋជាភាគីទទួលស្គាល់សិទ្ធិរបស់កុមារដែលត្រូវសង្ស័យ ចោទប្រកាន់ ឬត្រូវបានទទួលស្គាល់ថា បានប្រព្រឹត្តល្មើសនឹងច្បាប់ព្រហ្មទណ្ឌ នូវសិទ្ធិទទួលបាននូវការប្រព្រឹត្តមកលើខ្លួនដោយសមស្របជាមួយនឹងការជំរុញស្មារតីនៃភាពថ្លៃថ្នូរ និងតម្លៃរបស់កុមារ ហើយនឹងពង្រឹងបន្ថែមការគោរពរបស់កុមារនូវសិទ្ធិមនុស្ស និងគ្រឹះនៃសេរីភាពរបស់អ្នកដទៃដោយគិតគូរដល់អាយុរបស់កុមារ និងដល់ភាពចាំបាច់ក្នុងការជួយបញ្ចូលកុមារទៅក្នុងសង្គមវិញ និងឱ្យកុមារអាចប្រកាន់យកបាននូវតួនាទីស្ថាបនាក្នុងសង្គម។

(២) ក្នុងចំណុចនេះ និងដោយយោងទៅតាមបញ្ញត្តិនៃឯកសារអន្តរជាតិដែលទាក់ទងទៅនឹងបញ្ហានេះ រដ្ឋជាភាគីត្រូវធានាជាពិសេសថា :

ក-គ្មានកុមារណាម្នាក់ត្រូវបានសង្ស័យ ចោទប្រកាន់ ឬត្រូវបានទទួលស្គាល់ថាបានប្រព្រឹត្តបទល្មើសនឹងច្បាប់ព្រហ្មទណ្ឌអាស្រ័យដោយទង្វើ ឬការខកខានទាំងឡាយណាដែលមិនត្រូវបានហាមឃាត់ដោយច្បាប់ជាតិ ឬច្បាប់ អន្តរជាតិនៅក្នុងពេលដែលអំពើទាំងនោះត្រូវបានប្រព្រឹត្តឡើយ។

ខ-កុមារគ្រប់រូបដែលត្រូវបានសង្ស័យ ឬចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើសនឹងច្បាប់ព្រហ្មទណ្ឌ យ៉ាងហោច ណាស់ត្រូវទទួលបាននូវកិច្ចធានាដូចខាងក្រោម :

ខ.១-ទទួលចាត់ទុកជាឥតកំហុសរហូតដល់ពេលដែលពិរុទ្ធភាពរបស់កុមារត្រូវបានកំណត់ស្របតាមច្បាប់។

ខ.២-ត្រូវទទួលបានព័ត៌មានជាបន្ទាន់ និងដោយផ្ទាល់ស្តីពីបទចោទប្រកាន់មកលើខ្លួន និងប្រសិនបើសមស្រប គឺតាមរយៈឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់របស់ខ្លួន និងទទួលបាននូវកិច្ចឧបត្ថម្ភសមតាមផ្លូវច្បាប់ ឬជំនួយសមស្របផ្សេងៗទៀតក្នុងការរៀបចំ និងដាក់ចេញនូវកិច្ចការពារខ្លួន។

ខ.៣-ទទួលបានការដោះស្រាយសំណុំរឿងដោយគ្មានការយឺតយ៉ាវដោយអាជ្ញាធរឬស្ថាប័នតុលាការដែលមានសមត្ថកិច្ចឯករាជ្យ និងមិនលំអៀងនៅក្នុងការជំនុំជំរះមួយដែលស្របតាមផ្លូវច្បាប់ ឬដោយមានជំនួយឧបត្ថម្ភផ្នែកច្បាប់ និងលើកលែងតែមានការពិនិត្យថាប្រការនេះគឺផ្ទុយនឹងផលប្រយោជន៍ល្អបំផុតរបស់កុមារជាពិសេសដោយគិតទៅលើអាយុ ឬស្ថានភាពរបស់កុមារ របស់ឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់របស់កុមារ។

ខ.៤-មិនត្រូវបានទទួលការបង្ខិតបង្ខំឱ្យធ្វើជាសាក្សី ឬទទួលសារភាពកំហុស ឬត្រូវបានសាកសួរជាសាក្សីដើមចោទ និងបានការចូលរួមធ្វើការសាកសួរក្នុងនាមជាសាក្សីចុងចោទក្នុងលក្ខខណ្ឌស្មើភាព

ខ.៥-ប្រសិនបើពិនិត្យឃើញថាបានប្រព្រឹត្តល្មើសនឹងច្បាប់ កុមារអាចតវ៉ា សើរើឡើងវិញនូវសេចក្តីវិនិច្ឆ័យ និងវិធានការផ្សេងៗដែលបានដាក់ចុះជាផលវិបាកនៃសេចក្តី វិនិច្ឆ័យនេះនៅមុខអាជ្ញាធរមានសមត្ថកិច្ច ឬស្ថាប័ន តុលាការឯករាជ្យ និងមិនលំអៀងដែលខ្ពស់ជាង

ខ.៦-ទទួលបានដោយឥតគិតថ្លៃនូវការជួយបកប្រែប្រសិនបើកុមារមិនអាចយល់ឬមិនអាចនិយាយភាសាដែលត្រូវបានប្រើ

ខ.៧-ជីវិតជាឯកជនរបស់កុមារត្រូវបានគោរពទាំងស្រុងនៅគ្រប់ដំណាក់កាលទាំងអស់នៃនីតិវិធី

(៣) រដ្ឋជាភាគីស្វះស្វែងជំរុញការចាត់តាំងច្បាប់នីតិវិធីអាជ្ញាធរ និងស្ថាប័នដែលទទួលអនុវត្តដោយឡែកលើបញ្ហាកុមារដែលត្រូវសង្ស័យចោទប្រកាន់ ឬបានទទួលស្គាល់ថាបានប្រព្រឹត្តល្មើសនឹងច្បាប់ព្រហ្មទណ្ឌ និងជាពិសេស

ក-ការកំណត់នូវអាយុអប្បបរមាមួយដែលក្រោមពីអាយុនេះ កុមារនឹងត្រូវបានសន្មត់ មិនមានសមត្ថភាព ក្នុងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ

ខ-ប្រសិនបើសមស្របនិងជាប្រការល្អ វិធានការនានាដែលទាក់ទងនឹងកុមារប្រភេទនេះមិនចាំបាច់ឆ្លងកាត់ នីតិវិធីតុលាការ ឱ្យតែសិទ្ធិមនុស្សនិងកិច្ចការពារផ្នែកច្បាប់ ត្រូវបានគោរពទាំងស្រុង

(៤) ការចាត់ចែងរៀបចំច្រើនប្រភេទដូចជាការថែទាំ ការណែនាំ និងពិនិត្យគ្រប់គ្រង ការផ្តល់មតិទូន្មាន ការសាកល្បង ការដាក់ឱ្យចិញ្ចឹមតាមគ្រួសារកម្មវិធីអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជម្រើសការថែទាំជាស្ថាប័នផ្សេងៗទៀតត្រូវបានរៀបចំឡើងធានាថា កុមារត្រូវបានទទួលការថែទាំសមស្របទៅនឹងសុខុមាលភាពរបស់ពួកគេ ហើយស្របទៅនឹងស្ថានភាពរបស់កុមារ និងទម្ងន់នៃបទល្មើសនោះ ។

មាត្រា៤១

គ្មានបញ្ញត្តិណាមួយនៃអនុសញ្ញានេះប៉ះពាល់បញ្ញត្តិណាមួយទៀត ដែលបណ្តាលឱ្យល្អជាងការធ្វើឱ្យសម្រេចនូវសិទ្ធិទាំងឡាយរបស់កុមារដែលមានចែងនៅក្នុង :

ក-ច្បាប់របស់រដ្ឋជាភាគី

ខ-ច្បាប់អន្តរជាតិដែលមានជាធរមានចំពោះរដ្ឋនោះ

មាត្រា៤២

រដ្ឋជាភាគីសន្យានឹងផ្សព្វផ្សាយឱ្យបានទូលំទូលាយដោយមធ្យោបាយសមស្រប និងសកម្មនូវគោលការណ៍និង បទបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះឱ្យយល់ទាំងមនុស្សពេញវ័យ និងកុមារ ។

មាត្រា៤៣

(១)ដើម្បីត្រួតពិនិត្យវឌ្ឍនភាព ដែលត្រូវបានធ្វើឡើងដោយរដ្ឋជាភាគីក្នុងការធ្វើឱ្យចេញជាក់ស្តែងនូវកាតព្វកិច្ចនានារបស់ខ្លួនដែលបានសន្យានៅក្នុងអនុសញ្ញានេះ និងត្រូវបង្កើតឡើងនូវគណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ ដែលនឹងមានភារកិច្ចដូចបានកំណត់ខាងក្រោមនេះ ។

(២) គណៈកម្មាធិការមានសមាជិកអ្នកឯកទេសចំនួនដប់នាក់ ដែលប្រកបដោយសីលធម៌ខ្ពស់ និងមានការទទួលស្គាល់ទៅលើផ្នែកសមត្ថកិច្ចក្នុងវិស័យជាមុខសញ្ញានៃអនុសញ្ញានេះ។ សមាជិកនៃគណៈកម្មាធិការនេះនឹងត្រូវបោះឆ្នោតជ្រើសតាំងឡើងដោយរដ្ឋជាភាគីក្នុងចំណោមពលរដ្ឋរបស់ខ្លួន ហើយនឹងបំពេញការងារក្នុងសមត្ថភាពផ្ទាល់ខ្លួន និងដោយយោលទៅលើការបែងចែកសមស្របតាមភូមិសាស្ត្រ និងស្របតាមប្រព័ន្ធច្បាប់សំខាន់ៗ។

(៣) សមាជិកទាំងឡាយនៃគណៈកម្មាធិការនឹងត្រូវជ្រើសតាំងឡើងតាមរយៈការបោះឆ្នោតជាសម្ងាត់លើបញ្ជីរាយនាមមួយដែលស្នើឡើងដោយរដ្ឋជាភាគីទាំងឡាយ។ រដ្ឋជាភាគីនីមួយៗអាចស្នើបេក្ខជនម្នាក់ក្នុងចំណោម ពលរដ្ឋផ្ទាល់របស់ខ្លួន។

(៤) ការបោះឆ្នោតជាលើកដំបូងបង្អស់ មិនត្រូវឱ្យយូរលើសពីប្រាំមួយខែក្រោយពីអនុសញ្ញានេះចូលជាធរមានឡើយ ហើយនៅពេលក្រោយៗមកទៀតជារៀងរាល់ឆ្នាំទីពីរ។ បួនខែយ៉ាងតិចបំផុតមុនដល់ពេលកំណត់បោះឆ្នោតនីមួយៗអគ្គលេខាធិការអង្គការសហប្រជាជាតិ និងផ្ញើលិខិតទៅរដ្ឋជាភាគីទាំងឡាយ ស្នើសុំឱ្យដាក់ឈ្មោះបេក្ខជនរបស់ខ្លួនក្នុងរយៈពេលពីរខែ។ អគ្គលេខាធិការនឹងរៀបចំបញ្ជីឈ្មោះបេក្ខជនដែលស្នើឡើងនោះតាមលំដាប់អក្សរ ហើយនឹងបញ្ជូនបញ្ជីនេះទៅរដ្ឋជាភាគីទាំងឡាយនៃអនុសញ្ញានេះ។

(៥) ការបោះឆ្នោតនឹងត្រូវធ្វើឡើងក្នុងសម័យប្រជុំនៃរដ្ឋជាភាគីទាំងឡាយ នៅទីស្នាក់ការរបស់អង្គការសហប្រជាជាតិ ហើយដែលត្រូវបានកោះអញ្ជើញដោយអគ្គលេខាអង្គការសហប្រជាជាតិ។ នៅក្នុងកិច្ចប្រជុំនោះដែលទាមទារឱ្យមានវត្តមានពីរភាគបីនៃរដ្ឋជាភាគីទើបយកជាការបាន អ្នកដែលជាប់ជាសមាជិកគណៈកម្មាធិការគឺបេក្ខជនដែលទទួលបានសម្លេងច្រើនជាងគេបំផុត និងដែលបានសម្លេងភាគច្រើនដាច់ខាតនៃអ្នកតំណាងរដ្ឋជាភាគីដែលមានវត្តមាននៅក្នុងសម័យប្រជុំ និងដែលបានបោះឆ្នោត។

(៦) សមាជិកនៃគណៈកម្មាធិការនឹងត្រូវបានបោះឆ្នោតជ្រើសតាំងសម្រាប់រយៈពេលបួនឆ្នាំ។ សមាជិកទាំងនេះអាចឈរឈ្មោះបោះឆ្នោតជ្រើសតាំងជាថ្មីទៀតបាន នៅពេលណាដែលមានការដុះខ្នែសនាមជាថ្មី។ អាណត្តិរបស់សមាជិក៥នាក់ដែលបានជាប់ឆ្នោតក្នុងពេលបោះឆ្នោតលើកទីមួយ នឹងត្រូវបានបញ្ចប់តែក្នុងរយៈពេលពីរឆ្នាំក្រោយការបោះឆ្នោតលើកទីមួយភ្លាម ឈ្មោះសមាជិកទាំងប្រាំនាក់នេះនឹងត្រូវបានធ្វើការជ្រើសរើសដោយចាប់ឆ្នោតដោយ ប្រធានអង្គប្រជុំ។

(៧) បើសិនជាមានសមាជិកនៃគណៈកម្មាធិការណាម្នាក់ស្លាប់ ឬសុំឈប់ ឬប្រកាសដោយហេតុផលណាមួយថាខ្លួនមិនអាចបំពេញភារកិច្ចរបស់គណៈកម្មាធិការបានទេនោះ រដ្ឋជាភាគីដែលបានតែងតាំងសមា

ជិកនេះនឹងត្រូវចាត់តាំងអ្នកឯកទេសម្នាក់ទៀតក្នុងចំណោមពលរដ្ឋរបស់ខ្លួនឱ្យបំពេញអាណត្តិនៅសល់ដោយមានការយល់ព្រមពី គណៈកម្មាធិការ ។

(៨) គណៈកម្មាធិការនឹងបង្កើតច្បាប់នីតិវិធីរបស់ខ្លួនផ្ទាល់ ។

(៩) គណៈកម្មាធិការនឹងជ្រើសតាំងមន្ត្រីផ្លូវការរបស់ខ្លួនសម្រាប់រយៈពេលពីរឆ្នាំ

(១០) សម័យប្រជុំរបស់គណៈកម្មាធិការនឹងត្រូវធ្វើឡើងជាធម្មតានៅទីស្នាក់ការអង្គការសហប្រជាជាតិ ឬនៅកន្លែងសមស្របណាមួយដោយការកំណត់របស់គណៈកម្មាធិការ ។ គណៈកម្មាធិការនឹងប្រជុំជាធម្មតារៀងរាល់ឆ្នាំ ។ រយៈពេលនៃការប្រជុំរបស់គណៈកម្មាធិការនឹងត្រូវបានកំណត់ និង កែប្រែឡើងវិញប្រសិនបើចាំបាច់ដោយការប្រជុំរបស់រដ្ឋជាភាគីអនុសញ្ញានេះ ហើយដោយមានការយល់ព្រមពីមហាសន្និបាត ។

(១១) អគ្គលេខាធិការនៃអង្គការសហប្រជាជាតិនឹងផ្តល់បុគ្គលិកនិងឧបករណ៍ប្រើប្រាស់ចាំបាច់នានាសម្រាប់ឱ្យគណៈកម្មាធិការអាចបំពេញកិច្ចការរបស់ខ្លួនបានដោយប្រសិទ្ធភាពនៅក្នុងអនុសញ្ញានេះ ។

(១២) ដោយមានការយល់ព្រមពីមហាសន្និបាត សមាជិកនៃគណៈកម្មាធិការដែលបានចាត់តាំងឡើងក្រោមអនុសញ្ញានឹងបានទទួលប្យៀវត្សន៍ពីថវិកាអង្គការសហប្រជាជាតិក្នុងកម្រិត និងលក្ខខណ្ឌដែលមហាសន្និបាតបានសម្រេច ។

មាត្រា៤៤

(១) រដ្ឋជាភាគីដាក់ជូនគណៈកម្មាធិការតាមរយៈអគ្គលេខាធិការអង្គការសហប្រជាជាតិនូវរបាយការណ៍ស្តីពីវិធានការនានាដែលពួកគេបានប្រកាន់យក ដើម្បីធ្វើឱ្យមានប្រសិទ្ធភាពដល់សិទ្ធិទាំងឡាយដែលត្រូវបានទទួល ស្គាល់នៅក្នុងអនុសញ្ញា និងស្តីពីវឌ្ឍនភាពដែលមាននៅក្នុងការប្រើប្រាស់សិទ្ធិទាំងនេះ :

ក- ក្នុងរយៈពេលពីរឆ្នាំក្រោយពីអនុសញ្ញានេះចូលជាធរមានចំពោះរដ្ឋជាភាគីដែលទាក់ទង

ខ-បន្ទាប់មករៀងរាល់ពីរឆ្នាំម្តង

(២) របាយការណ៍ដែលបានធ្វើឡើងតាមការបង្ហាញក្នុងមាត្រានេះ ត្រូវតែលើកឡើងពីកត្តា និងការលំបាកនានា ប្រសិនបើមានការជះឥទ្ធិពលដល់ការធ្វើឱ្យសម្រេចនូវកាតព្វកិច្ចដែលមានចែងក្នុងអនុសញ្ញានេះ ។ របាយការណ៍ត្រូវតែផ្តល់ផងដែរនូវព័ត៌មានគ្រប់គ្រាន់ ដើម្បីឱ្យគណៈកម្មាធិការមានការយល់ដឹងច្បាស់លាស់ ពេញលេញ ស្តីពីការអនុវត្តន៍នូវអនុសញ្ញានេះនៅក្នុងប្រទេសដែលមានការទាក់ទង ។

(៣) រដ្ឋជាភាគីដែលបានដាក់ជូនគណៈកម្មាធិការនូវរបាយការណ៍គ្រប់គ្រាន់ពេញលេញនាពេលដំបូង យោងតាមកថាខណ្ឌ១ (ខ) នៃមាត្រានេះនៅក្នុងរបាយការណ៍ក្រោយៗទៀតមិនចាំបាច់លើកឡើងវិញពីព័ត៌មានជាមូល ដ្ឋានដែលបានលើកឡើងពីលើកមុននោះឡើយ ។

(៤) គណៈកម្មាធិការ អាចដាក់សំណើដល់រដ្ឋជាភាគីនូវព័ត៌មានបន្ថែមទាក់ទងទៅនឹងការអនុវត្តន៍អនុសញ្ញានេះ។

(៥) គណៈកម្មាធិការត្រូវដាក់ជូនទៅមហាសន្និបាតតាមរយៈក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមនូវរបាយការណ៍ស្តីពីសកម្មភាពរបស់ខ្លួនរៀងរាល់ពីរឆ្នាំម្តង។

(៦) រដ្ឋជាភាគីត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវរបាយការណ៍របស់ខ្លួនជាសាធារណៈ នៅក្នុងប្រទេសរបស់ខ្លួន។

មាត្រា៤៥

ដើម្បីជំរុញការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពនូវអនុសញ្ញា និងដើម្បីលើកទឹកចិត្តដល់កិច្ចសហប្រតិបត្តិការជាអន្តរជាតិនៅក្នុងក្របខណ្ឌនៃអនុសញ្ញា :

ក-ទីភ្នាក់ងារឯកទេសមូលនិធិរបស់អង្គការសហប្រជាជាតិសម្រាប់កុមារ និងស្ថាប័នដទៃទៀតនៃអង្គការសហប្រជាជាតិត្រូវចាត់តាំងតំណាងរបស់ខ្លួនឱ្យចូលរួមពិនិត្យតាមដានការអនុវត្តន៍បទបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះដែលស្ថិតក្នុងក្របខណ្ឌនៃការងាររបស់ខ្លួន។ គណៈកម្មាធិការអាចអញ្ជើញភ្នាក់ងារឯកទេស មូលនិធិរបស់អង្គការសហប្រជាជាតិសម្រាប់កុមារ និងស្ថាប័នមានសមត្ថកិច្ចដទៃទៀតដែលសមស្របដើម្បីផ្តល់យោបល់ដំបូន្មាន ឯកទេសស្តីពីការអនុវត្តអនុសញ្ញានេះនៅក្នុងវិស័យដែលទាក់ទងនឹងការងាររបស់ខ្លួន។ គណៈកម្មាធិការអាចអញ្ជើញភ្នាក់ងារឯកទេសមូលនិធិរបស់អង្គការសហប្រជាជាតិសម្រាប់កុមារ និងស្ថាប័នដទៃទៀតរបស់អង្គការសហប្រជាជាតិឱ្យដាក់ជូននូវរបាយការណ៍ស្តីពីការអនុវត្តន៍អនុសញ្ញានេះនៅក្នុងដែនសកម្មភាពរបស់ខ្លួន។

ខ-គណៈកម្មាធិការ ត្រូវបញ្ជូនព័ត៌មាននៅពេលដែលយល់ថាចាំបាច់ទៅភ្នាក់ងារឯកទេសមូលនិធិរបស់អង្គការសហប្រជាជាតិសម្រាប់កុមារ និងស្ថាប័នមានសមត្ថកិច្ចដទៃទៀតនូវរបាយការណ៍ពីរដ្ឋជាភាគីណាដែលមានសំណើ ឬបង្ហាញថាមានតម្រូវការស្តីពីមតិណែនាំផ្នែកបច្ចេកទេស ឬជំនួយប្រសិនបើមានដោយភ្ជាប់ជាមួយនូវការពិនិត្យកត់សំគាល់ និងសំណើរបស់គណៈកម្មាធិការទៅលើសំណើឬចង្អុលបង្ហាញទាំងនេះ។

គ-គណៈកម្មាធិការ អាចផ្តល់យោបល់ដាក់ជូនមហាសន្និបាតនូវសំណើទៅអគ្គលេខាធិការឱ្យចាត់ចែងក្នុងនាមរបស់គណៈកម្មាធិការឱ្យសិក្សាស្រាវជ្រាវលើបញ្ហាដោយឡែកដែលទាក់ទងទៅនឹងសិទ្ធិរបស់កុមារ។

ឃ-គណៈកម្មាធិការ អាចធ្វើសំណើ និងផ្តល់យោបល់ជាទូទៅដោយឈរលើមូលដ្ឋាននៃព័ត៌មានដែលទទួលបានដោយអនុលោមតាមមាត្រា៤៤ និងមាត្រា៤៥នៃអនុសញ្ញា។ សំណើ និងយោបល់ដែលមាន

លក្ខណៈជាទូទៅនេះនឹងត្រូវបានផ្ញើជូនទៅរដ្ឋជាភាគីដែលទាក់ទង និងដាក់ជូនទៅមហាសន្និបាតដោយភ្ជាប់ជាមួយនូវមតិយោបល់របស់រដ្ឋជាភាគីប្រសិនបើមាន។

ភាគ III

មាត្រា៤៦

អនុសញ្ញាត្រូវបានបើកចំហសម្រាប់ចុះហត្ថលេខាដល់គ្រប់រដ្ឋទាំងអស់។

មាត្រា៤៧

អនុសញ្ញាត្រូវទទួលការផ្តល់សច្ចាប័ន។ ឯកសារនៃការផ្តល់សច្ចាប័ននេះត្រូវបានតម្កល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ។

មាត្រា៤៨

អនុសញ្ញានេះ បើកឱ្យមានការចូលរួមពីគ្រប់រដ្ឋ។ ឯកសារស្តីពីការចូលរួមនឹងត្រូវតម្កល់ទុកនៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។

មាត្រា៤៩

(១) អនុសញ្ញានេះ នឹងចូលជាធរមានសាមសិបថ្ងៃក្រោយពីការផ្តល់សច្ចាប័ន និងតម្កល់ទុកនៅនឹងអគ្គលេខាអង្គការសហប្រជាជាតិ។

(២) ចំពោះរដ្ឋនីមួយៗ ដែលបានផ្តល់សច្ចាប័នឬបានចូលរួមក្នុងអនុសញ្ញានេះ ក្រោយពីឯកសារនៃការផ្តល់សច្ចាប័ន ឬការចូលរួមទីម្ភៃ ត្រូវបានតម្កល់ទុកហើយនោះ អនុសញ្ញានឹងចូលជាធរមាននៅសាមសិបថ្ងៃក្រោយពីការដាក់ចូលនូវឯកសារការផ្តល់សច្ចាប័នដោយរដ្ឋទាំងនោះ។

មាត្រា ៥O

(១) គ្រប់រដ្ឋជាភាគីអាចស្នើសុំវិសោធនកម្ម និងដាក់សំណើនេះជូនទៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ។ អគ្គលេខាធិការនឹងបញ្ជូនសំណើវិសោធនកម្មនេះទៅរដ្ឋជាភាគីទាំងឡាយដោយស្នើសុំឱ្យពួកគេផ្តល់ដំណឹងថា តើពួកគេគាំទ្រការកោះប្រជុំសន្និសីទនៃរដ្ឋជាភាគី ដើម្បីពិនិត្យ និងបោះឆ្នោតទៅលើសំណើនោះឬទេ។ បើសិនជារយៈពេលបួនខែចាប់ពីពេលជូនដំណឹងមានមួយភាគបីយ៉ាងតិចនៃរដ្ឋជាភាគីបានគាំទ្រសន្និសីទប្រភេទនេះ អគ្គលេខាធិការនឹងកោះប្រជុំក្រោមការចាត់ចែងរបស់អង្គការសហប្រជាជាតិ។ វាល់វិសោធនកម្មដែលត្រូវបានអនុម័តដោយសម្លេងភាគច្រើននៃរដ្ឋជាភាគីដែលមានវត្តមាន និងបានបោះឆ្នោតក្នុងសន្និសីទនោះត្រូវដាក់ជូនសុំការឯកភាពពីមហាសន្និបាត។

(២) វិសោធនកម្មដែលបានអនុម័តដូចមានចែងនៅក្នុងកថាខណ្ឌ (១) នៃមាត្រានេះនឹងត្រូវចូលជាធរមាន នៅពេលដែលបានទទួលការឯកភាពពីមហាសន្និបាតនៃអង្គការសហប្រជាជាតិ និងទទួលយកដោយសម្លេងពីរភាគបីនៃរដ្ឋជាភាគី។

(៣) នៅពេលវិសោធនកម្មចូលជាធរមាន វានឹងមានអានុភាពជាកំហិតទៅលើរដ្ឋជាភាគីដែលបានទទួលយកវិសោធនកម្មនេះ រដ្ឋជាភាគីឯទៀតស្ថិតនៅក្រោមអានុភាពនៃបទបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ ហើយនិងរាល់វិសោធនកម្មមុនៗដែលខ្លួនបានទទួលយក។

មាត្រា ៥១

(១) អគ្គលេខាធិការនៃអង្គការសហប្រជាជាតិត្រូវទទួល និងបញ្ជូនទៅគ្រប់រដ្ឋទាំងអស់នូវអត្ថបទនៃការដាក់លក្ខខណ្ឌដែលបានធ្វើឡើងដោយរដ្ឋទាំងឡាយនៅពេលផ្តល់សច្ចាប័ន ឬនៅពេលសុំចូលរួម។

(២) លក្ខខណ្ឌដែលមិនស្របគ្នាគឺផ្ទុយទៅនឹងកម្មវត្ថុ និងគោលដៅនៃអនុសញ្ញានេះមិនត្រូវបានអនុញ្ញាតឡើយ។

(៣) លក្ខខណ្ឌនេះអាចដកវិញបានគ្រប់ពេលដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ដែលអគ្គលេខាធិការត្រូវជូនដំណឹងដល់រដ្ឋទាំងអស់។ ការជូនដំណឹងជាលាយលក្ខណ៍អក្សរ នេះនឹងមានប្រសិទ្ធភាពនៅថ្ងៃដែលអគ្គលេខាធិការបានទទួល។

មាត្រា៥២

រដ្ឋជាភាគីអាចសុំរំសាយពីអនុសញ្ញា ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អគ្គលេខាធិការនៃអង្គការ សហប្រជាជាតិ។ ការសុំរំសាយខ្លួនមានប្រសិទ្ធភាពមួយឆ្នាំក្រោយពីពេលដែលអគ្គលេខាធិការបានទទួលការជូនដំណឹងនេះ។

មាត្រា៥៣

អគ្គលេខាធិការនៃអង្គការ សហប្រជាជាតិត្រូវបានចាត់តាំងជាអ្នករក្សាទុកអនុសញ្ញានេះ។

មាត្រា៥៤

សំណៅដើមនៃអនុសញ្ញាដែលមានអត្ថបទជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និង អេស្បាញ មានតម្លៃស្មើគ្នានឹងត្រូវតម្កល់ទុកនៅនឹងអគ្គលេខាធិការនៃអង្គការ សហប្រជាជាតិ។

ជាបន្ទាប់នៃកិច្ចការនេះ ភាគីអ្នកចុះហត្ថលេខាខាងក្រោមដែលបានទទួលការអនុញ្ញាតយ៉ាងពេញលេញពីរដ្ឋាភិបាលរបស់ខ្លួនបានចុះហត្ថលេខានៅលើអនុសញ្ញា។

៣.អនុសញ្ញានៃអង្គការពលកម្មអន្តរជាតិលេខ១៣៨ស្តីពីអាយុអប្បបរមាឆ្នាំ១៩៧៣

អនុសញ្ញាទាក់ទងទៅនឹងអាយុអប្បបរមាក្នុងការអនុញ្ញាតឱ្យចូលបំរើការងារ(កំណត់សម្គាល់: កាលបរិច្ឆេទចូលជាធរមាន ១៩ មិថុនា ១៩៧៦) សន្និសីទសកលនៃអង្គការពលកម្មអន្តរជាតិ

ដោយមានការកោះប្រជុំនៅទីក្រុងហ្សឺណែវ ដោយស្ថាប័នគ្រប់គ្រងរបស់អង្គការពលកម្មអន្តរជាតិ និងដោយមានការជួបប្រជុំលើកទីហាសិបប្រាំបី នាសម័យប្រជុំថ្ងៃទី ៦ មិថុនា ១៩៧៣ និងដោយមានការព្រមព្រៀងលើការអនុម័តនៃសំណើទាក់ទងទៅនឹងអាយុអប្បបរមាក្នុងការអនុញ្ញាតឱ្យចូលបំរើការងារដែលជារបៀបវារៈទីបួននៃសម័យប្រជុំ និងដោយមានការកំណត់លក្ខខណ្ឌនៃអាយុអប្បបរមា (ឧស្សាហ កម្ម) អនុសញ្ញា ១៩១៩ - អាយុអប្បបរមា (សមុទ្រ) អនុសញ្ញា ១៩២០-អាយុអប្បបរមា (កសិកម្ម) អនុ សញ្ញា១៩២១-អាយុអប្បបរមា (ការថែរក្សា និងដុតភ្លើងឡចំហាយ ឬម៉ាស៊ូនចំហាយ) អនុសញ្ញា១៩២១-អាយុអប្បបរមា (មិនមែនការងារឧស្សាហកម្ម) អនុសញ្ញា ១៩៣២- អាយុអប្បបរមា (សមុទ្រ) អនុសញ្ញា (បន្ថែម) ១៩៣៦-អាយុអប្បបរមា (ឧស្សាហកម្ម) អនុសញ្ញា (បន្ថែម) ១៩៣៧ -អាយុអប្បបរមា (មិនមែនការងារឧស្សាហកម្ម) អនុសញ្ញាបន្ថែម ១៩៣៧ -អាយុអប្បបរមា (នេសាទ) អនុសញ្ញា ១៩៥៩ និងអាយុអប្បបរមា(ការងារ ក្រោមដី) អនុសញ្ញា ១៩៦៥ និង

ដោយសង្កេតឃើញថា ដល់ពេលវេលាដែលត្រូវបង្កើតឱ្យមានឯកសារជាសកលមួយស្តីពីកម្មវត្ថុ (ស្តីពីអាយុអប្បបរមាក្នុងការអនុញ្ញាតឱ្យចូលបំរើការងារ) ដែលបន្តិចម្តងៗត្រូវជំនួសដោយអត្ថិភាពមួយដែលអាចអនុវត្តបានដើម្បីកំណត់ព្រំដែនផ្នែកសេដ្ឋកិច្ច និងទស្សនៈនៃការធ្វើឱ្យសម្រេចនូវការលុបបំបាត់ទាំងស្រុងនៃពលកម្មកុមារ និងដោយមានការប្តេជ្ញា ថា សំណើទាំងនេះត្រូវតែមានទម្រង់ជា អនុសញ្ញាអន្តរជាតិមួយ ។

អនុម័តនៅថ្ងៃទី ម្ភៃប្រាំមួយ ខែ មិថុនា ឆ្នាំ មួយពាន់ប្រាំបួនរយចិតសិបបីអនុសញ្ញាដូចខាងក្រោមនឹងត្រូវប្រកាសថាជាអនុសញ្ញា ១៩៧៣ ស្តីពីអាយុអប្បបរមា ។

មាត្រា១

សមាជិកទាំងអស់នៃអនុសញ្ញានេះ ដែលចូលជាធរមានសន្យាធ្វើតាមគោលនយោបាយជាតិក្នុងការធានានូវប្រសិទ្ធភាពនៃការលុបបំបាត់ពលកម្មកុមារ និងធ្វើឱ្យមានការជឿនលឿនទៅមុខនៃអាយុអប្បបរមាក្នុងការអនុញ្ញាតឱ្យចូលបំរើការងារ ឬការងារក្នុងកម្រិតមួយដែលស្របទៅនឹងការអភិវឌ្ឍន៍យ៉ាងពេញលេញផ្នែករូបរាងកាយ និងសតិបញ្ញារបស់យុវវ័យ ។

មាត្រា២

(១) សមាជិកទាំងអស់ដែលផ្តល់សច្ចាប័នលើអនុសញ្ញានេះ ត្រូវបញ្ជាក់នៅក្នុងសេចក្តីប្រកាសបន្ថែមលើការផ្តល់សច្ចាប័ននៃអាយុអប្បបរមាក្នុងការអនុញ្ញាតឱ្យចូលបំរើការងារ ឬធ្វើការនៅក្នុងតំបន់របស់ខ្លួន និងពីវិធីចុះបញ្ជី ដឹកនាំនេះក្នុងតំបន់របស់ខ្លួន បញ្ញត្តិនៅក្នុងមាត្រា ៤ ដល់មាត្រា ៨ នៃអនុសញ្ញានេះ

គ្មានអ្នកណាម្នាក់នៅក្រោមអាយុនោះ ត្រូវបានអនុញ្ញាតឱ្យចូលបំរើការងារ ឬធ្វើការនៅកន្លែងការងារ ឬក្នុងមុខរបរណាមួយបានឡើយ ។

(២) សមាជិកទាំងអស់ដែលបានផ្តល់សច្ចាប័នលើអនុសញ្ញានេះអាចជូនដំណឹងជាលាយលក្ខណ៍អក្សរ ជាបន្ត បន្ទាប់ទៅអគ្គនាយកនៃការិយាល័យពលកម្មអន្តរជាតិដោយធ្វើឱ្យជឿនលឿនទៅមុខនូវសេចក្តីប្រកាស ដែលបាន កំណត់អាយុអប្បបរមាខ្ពស់ជាងការកំណត់ពីលើកមុន ។

(៣) អាយុអប្បបរមាដែលបានកំណត់ ដូចមានចែងក្នុងកថាខណ្ឌ១នៃមាត្រានេះមិនត្រូវតិចជាងអាយុនៃ ការបញ្ចប់កាតព្វកិច្ចសិក្សា និងគ្រប់ករណីមិនត្រូវតិចជាងអាយុ ១៥ ឆ្នាំឡើយ ។

(៤) ដូចបទបញ្ញត្តិទាំងអស់នៃកថាខណ្ឌ៣នៃមាត្រានេះ សមាជិកណាដែលការសម្របសម្រួលផ្នែកសេដ្ឋកិច្ច និង ការអប់រំមានការអភិវឌ្ឍន៍ពុំទាន់គ្រប់គ្រាន់ក្រោយការពិគ្រោះយោបល់ជាមួយអង្គការនិយោជក និងអ្នកធ្វើការដែលទាក់ទិនទាំងអស់ នៅពេលមានការចាំបាច់បែបនេះ អាចធ្វើការកំណត់ជាដំបូងនូវ អាយុអប្បបរមា១៤ឆ្នាំ ។

(៥) សមាជិកទាំងអស់ដែលបានកំណត់អាយុអប្បបរមា១៤ឆ្នាំដូចមានចែងក្នុងបទបញ្ញត្តិនៃកថាខណ្ឌមុនត្រូវ បញ្ជូលទៅក្នុងរបាយការណ៍របស់ខ្លួនស្តីពីសំណើនៃអនុសញ្ញានេះ ដែលបានស្នើក្រោមមាត្រា២២នៃរដ្ឋ ធម្មនុញ្ញរបស់អង្គការពលកម្មអន្តរជាតិសេចក្តីប្រកាស

(ក) ថាមានហេតុផលគ្រប់គ្រាន់ក្នុងការកំណត់បែបនេះ ឬ

(ខ) ថាសុំរំសាយសិទ្ធិរបស់ខ្លួនក្នុងការប្រើប្រាស់នូវបទបញ្ញត្តិក្នុងបញ្ហាដែលត្រូវយកមកដោះស្រាយ ចាប់ពីពេលប្រកាសនេះទៅ ។

មាត្រា៣

(១) អាយុអប្បបរមាក្នុងការអនុញ្ញាតឱ្យចូលបំរើការងារគ្រប់ប្រភេទ ឬការងារដែលជាលក្ខណៈធម្មជាតិ ឬ ក្នុងករណីបំពេញការងារនោះនឹងបណ្តាលឱ្យមានគ្រោះថ្នាក់ដល់សុខភាព សុវត្ថិភាព ឬសីលធម៌របស់ យុវវ័យមិនត្រូវ មានអាយុតិចជាង ១៨ ឆ្នាំឡើយ ។

(២) ប្រភេទនៃមុខរបរ ឬការងារក្នុងកថាខណ្ឌ១នៃមាត្រានេះដែលដាក់ស្នើ ត្រូវបានសម្រេចដោយអាជ្ញាធរ មានសមត្ថកិច្ច ឬដោយបទបញ្ជា ឬដោយច្បាប់ជាតិ ក្រោយពីការពិគ្រោះយោបល់ជាមួយអង្គការ និយោជក និងអ្នក ធ្វើការទាក់ទិនទាំងអស់ នៅពេលមានការចាំបាច់បែបនេះ ។

(៣) ដូចបទបញ្ញត្តិទាំងអស់នៃកថាខណ្ឌ១នៃមាត្រានេះ អាជ្ញាធរមានសមត្ថកិច្ច ឬបទបញ្ជា ឬច្បាប់ជាតិ អាច ក្រោយពីការពិគ្រោះយោបល់ជាមួយអង្គការនិយោជក និងអ្នកធ្វើការទាក់ទិនទាំងអស់នៅពេល មានការចាំបាច់បែបនេះអនុញ្ញាតឱ្យបំរើការងារចាប់ពីអាយុ ១៦ ឆ្នាំ ក្នុងលក្ខខណ្ឌដែលសុខភាព

សុវត្ថិភាព និងសីលធម៌របស់ យុវវ័យត្រូវបានការពារយ៉ាងពេញលេញ ហើយដែលយុវវ័យត្រូវទទួលបាននូវការអប់រំត្រឹមត្រូវ ឬការបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងវិស័យសកម្មភាពការងារដែលគេត្រូវធ្វើ

មាត្រា៤

(១) ប្រសិនបើចាំបាច់ក្រោយពីការពិគ្រោះយោបល់ជាមួយអង្គការនិយោជក និងអ្នកធ្វើការដែលទាក់ទិនទាំងអស់នៅពេលមានការចាំបាច់បែបនេះ អាជ្ញាធរមានសមត្ថកិច្ចអាចបដិសេធពីការអនុវត្តន៍នៃអនុសញ្ញាដែលបានកំណត់ប្រភេទមុខរបរ ឬការងារនេះនៅក្នុងលក្ខណៈពិសេស និងទម្ងន់នៃបញ្ហាដែលកើតមានឡើងក្នុងការអនុវត្តន៍។

(២) សមាជិកនីមួយៗដែលផ្តល់សច្ចាប័នលើអនុសញ្ញានេះ ត្រូវធ្វើតារាងបញ្ជីនៅក្នុងរបាយការណ៍ដំបូងរបស់ខ្លួនស្តីពីសំណើនៃអនុសញ្ញាដែលបានដាក់ស្នើក្រោមមាត្រា ២២នៃរដ្ឋធម្មនុញ្ញរបស់អង្គការពលកម្មអន្តរជាតិនូវផ្នែកដែលអាចត្រូវបានបដិសេធ ដូចមានចែងក្នុងកថាខណ្ឌ១នៃមាត្រានេះ ដោយផ្តល់ហេតុផលនៃការបដិសេធនោះ និងត្រូវលើកឡើងនៅក្នុងរបាយការណ៍ពីស្ថានភាពនៃច្បាប់របស់ខ្លួន និងការប្រតិបត្តិក្នុងលក្ខណៈពិសេសនូវផ្នែក ដែលត្រូវបដិសេធ ហើយដែលវិសាលភាពនោះត្រូវបានជះឥទ្ធិពលទៅដល់ការផ្តល់ ឬការស្នើឡើង(ការកំណត់ប្រភេទនៃមុខរបរ ឬការងារដែលបានបដិសេធ) ដែលត្រូវបានដាក់បញ្ចូលក្នុងអនុសញ្ញាដែលរំពឹងថាគោរពដល់ផ្នែកទាំងនេះ។

(៣) មុខរបរឬការងារដែលគ្របដណ្តប់ដោយមាត្រា៣នៃអនុសញ្ញានេះមិនត្រូវបានដកចេញពីការអនុវត្តន៍នៃអនុសញ្ញានេះឡើយដោយអនុលោមតាមមាត្រានេះ ។

មាត្រា៥

(១) សមាជិកណាដែលស្ថានការណ៍ផ្នែកសេដ្ឋកិច្ច និងរដ្ឋបាលពុំទាន់មានការអភិវឌ្ឍន៍សមស្របក្រោយពីការពិគ្រោះយោបល់ជាមួយអង្គការនិយោជក និងអ្នកដែលធ្វើការទាក់ទិនទាំងអស់នៅពេលមានករណីបែបនេះអាចកំណត់ជាដំបូងនូវព្រំដែននៃការអនុវត្តន៍អនុសញ្ញានេះ ។

(២) គ្រប់សមាជិកដែលប្រើប្រាស់នូវបទបញ្ញត្តិក្នុងកថាខណ្ឌ១នៃមាត្រានេះ ត្រូវបញ្ជាក់នៅក្នុងសេចក្តីថ្លែងការណ៍បន្ថែមនូវការផ្តល់សច្ចាប័នរបស់ខ្លួនវិស័យនៃសកម្មភាពសេដ្ឋកិច្ច ឬ ប្រភេទនៃកិច្ចការដែលនឹងត្រូវអនុវត្តនូវបទបញ្ញត្តិនៃអនុសញ្ញានេះ ។

(៣) បទបញ្ញត្តិនៃអនុសញ្ញាត្រូវតែអាចអនុវត្តបានក្នុងកម្រិតអប្បបរមាដូចតទៅៈការជីករ៉ែ និងថ្ម ការងារក្នុងរោងចក្រ សំណង់ អគ្គិសនី ឧស្ម័ននិងទឹក បម្រើផ្នែកអនាម័យ ការដឹកជញ្ជូន ឃ្លាំងទំនិញ និងគមនាគមន៍ ចំការធំៗ និង កិច្ចការកសិកម្មផ្សេងទៀតដែលច្រើនតែផលិតសម្រាប់ពាណិជ្ជកម្ម ប៉ុន្តែមិន

រាប់បញ្ចូលការផលិតក្នុងកម្រិតគ្រួសារ និងកម្រិតតូចសម្រាប់ការប្រើប្រាស់ ឬបរិភោគក្នុងស្រុក និងមិនមែនជាអ្នកស៊ីឈ្នួលទៀងទាត់ ។

(៤) សមាជិកទាំងអស់ដែលបានកំណត់ព្រំដែននៃការអនុវត្តន៍នូវអនុសញ្ញានេះ ដូចមានចែងក្នុងមាត្រានេះ

(ក) ត្រូវបង្ហាញនៅក្នុងរបាយការណ៍របស់ខ្លួនក្រោមមាត្រា២២នៃរដ្ឋធម្មនុញ្ញរបស់អង្គការពលកម្មអន្តរជាតិនូវស្ថានភាពទូទៅទាក់ទងទៅនឹងកិច្ចការឬការងាររបស់យុវវ័យ និងកុមារនៅក្នុងផ្នែកនៃសកម្មភាព ដែលត្រូវបានបដិសេធពីវិសាលភាពនៃការអនុវត្តន៍នូវអនុសញ្ញានេះក្នុងលក្ខណៈមួយទូលាយជាង ។

(ខ) អាចពង្រីកទម្រង់វិសាលភាពនៃការអនុវត្តន៍នៅពេលណាមួយដោយផ្ញើសេចក្តីថ្លែងការណ៍ជូនទៅអគ្គនាយកនៃការិយាល័យពលកម្មអន្តរជាតិ។

មាត្រា៦

អនុសញ្ញានេះ មិនត្រូវអនុវត្តចំពោះការងារដែលធ្វើដោយកុមារ ឬយុវវ័យនៅក្នុងសាលាចំណេះទូទៅការអប់រំវិជ្ជាជីវៈ ឬបច្ចេកទេស ឬនៅក្នុងស្ថាប័នបណ្តុះបណ្តាលផ្សេងទៀត ឬបុគ្គលដែលមានអាយុតិចជាង ១៤ ឆ្នាំនៃអាយុនៅក្នុងកិច្ចសន្យាដែលការងារទាំងនេះ ត្រូវបំពេញដោយអនុលោមទៅតាមលក្ខខណ្ឌដែលបានកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ចក្រោយការពិគ្រោះយោបល់ជាមួយអង្គការនិយោជក និងអ្នកធ្វើការងារដែលពាក់ព័ន្ធទាំងអស់នៅពេលមានការចាំបាច់បែបនេះ និងជាផ្នែកទាំងអស់នៃ

(ក) មុខវិជ្ជានៃការអប់រំ ឬការបណ្តុះបណ្តាល គឺសាលា ឬស្ថាប័នបណ្តុះបណ្តាលជាអ្នកទទួលខុសត្រូវជាចម្បង

(ខ) កម្មវិធីនៃការបណ្តុះបណ្តាលជាច្រើន ឬទាំងស្រុងនៅក្នុងកិច្ចសន្យា ដែលកម្មវិធីទាំងនេះមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ។

(គ) កម្មវិធីនៃការណែនាំ ឬការតម្រង់ទិសបានរៀបចំឡើងដើម្បីជួយសម្របសម្រួលការការជ្រើសរើសការងារអាជីព ឬ ការបណ្តុះបណ្តាលមួយសមស្រប ។

មាត្រា៧

(១) ច្បាប់ជាតិ ឬបទបញ្ជា អាចអនុញ្ញាត មុខរបរ ឬការងារសម្រាប់អ្នកដែលមានអាយុ ១៣ ទៅ ១៥ ឆ្នាំលើការងារស្រាលដែល

(ក) មិនធ្វើឱ្យប៉ះពាល់ដល់សុខភាព ឬការអភិវឌ្ឍន៍ និង

(ខ) មិនធ្វើឱ្យលំអៀងការយកចិត្តទុកដាក់ចំពោះការសិក្សា ការចូលរួមរបស់ពួកគេនៅក្នុងការតម្រង់ទិសវិជ្ជាជីវៈ ឬកម្មវិធីបណ្តុះបណ្តាលដែលផ្តល់ឱ្យដោយអាជ្ញាធរមានសមត្ថកិច្ច ឬ ចំណេះដឹងជាអត្ថប្រយោជន៍ដែលទទួល បានពីការអប់រំ ។

(២) ច្បាប់ជាតិ ឬបទបញ្ជាក៏អាចអនុញ្ញាតផងដែរចំពោះមុខរបរ ឬការងារសម្រាប់អ្នកដែលមាន អាយុតិចជាង ១៥ ឆ្នាំ ប៉ុន្តែមិនទាន់បានបំពេញកាតព្វកិច្ចសិក្សារបស់គេនៅឡើយចំពោះការងារដែលតម្រូវឱ្យមានចែងនៅក្នុងកថាខណ្ឌរង (ក) និង (ខ) នៃកថាខណ្ឌ១នៃមាត្រានេះ ។

(៣) អាជ្ញាធរមានសមត្ថកិច្ចត្រូវកំណត់សកម្មភាពក្នុងមុខរបរ ឬការងារ ដែលអាចអនុញ្ញាតក្នុងកថាខណ្ឌ ១ និងកថាខណ្ឌ ២ នៃមាត្រានេះ និងត្រូវកំណត់ចំនួនម៉ោងធ្វើការងារ និងលក្ខខណ្ឌដែលអាចទទួលយកនៅក្នុងមុខរបរ ឬការងារទាំងនេះ។

(៤) ដូចបទបញ្ញត្តិទាំងអស់នៃកថាខណ្ឌ ១ និង កថាខណ្ឌ ២ នៃមាត្រានេះ សមាជិកដែលប្រើប្រាស់បទបញ្ញត្តិ នៃកថាខណ្ឌ ៤ នៃមាត្រា ២ អាចបន្តប្រើប្រាស់ដូចនេះតទៅទៀត ដោយអាចដាក់ជំនួសអាយុ ១២ ឆ្នាំ និង ១៤ ឆ្នាំ សម្រាប់អាយុ ១៣ ឆ្នាំ និង ១៥ ឆ្នាំ ក្នុងកថាខណ្ឌ ១ និង អាយុ ១៤ ឆ្នាំ សម្រាប់ជំនួស ១៥ ឆ្នាំ នៅក្នុងកថាខណ្ឌ ២ នៃមាត្រានេះ ។

មាត្រា ៨

(១) ក្រោយពីការពិគ្រោះយោបល់ជាមួយអង្គការនិយោជក និងអ្នកធ្វើការដែលទាក់ទិនទាំងអស់ នៅទីណាដែលមានការចាំបាច់បែបនេះ អាជ្ញាធរមានសមត្ថកិច្ចដោយមានការព្រមព្រៀង អនុញ្ញាតឱ្យក្នុងករណីបុគ្គលលើកលែងតែការហាមឃាត់នូវមុខរបរ ឬ ការងារ ដែលបានផ្តល់ក្នុងមាត្រា ២នៃអនុសញ្ញានេះ ក្នុងប្រការនេះដូចជាអ្នកចូលរួមក្នុងការសម្តែងសិល្បៈ ។

(២) ផ្តល់ការអនុញ្ញាតដូចនេះ ត្រូវកំណត់ចំនួនម៉ោងនៃរយៈពេលធ្វើការងារ និងកំណត់លក្ខខណ្ឌក្នុងមុខរបរ ឬ ការងារដែលត្រូវបានអនុញ្ញាត ។

មាត្រា ៩

(១) រាល់វិធានការណ៍ចាំបាច់ទាំងអស់ រួមបញ្ចូលទាំងការដាក់ទោសទណ្ឌដោយសមស្របផង ត្រូវបានប្រកាន់យកដោយអាជ្ញាធរមានសមត្ថកិច្ចក្នុងការធានានូវការប្រតិបត្តិប្រកបដោយប្រសិទ្ធភាពនូវបទបញ្ញត្តិនៃអនុសញ្ញា នេះ ។

(២) ច្បាប់ជាតិ ឬ បទបញ្ជ ឬ អាជ្ញាធរមានសមត្ថកិច្ចត្រូវកំណត់ឱ្យច្បាស់លាស់នូវអ្នកទទួលខុសត្រូវក្នុងការប្រតិបត្តិតាមបទបញ្ញត្តិនៃអនុសញ្ញានេះប្រកបដោយប្រសិទ្ធភាព ។

(៣)ច្បាប់ជាតិ ឬបទបញ្ជាឬអាជ្ញាធរមានសមត្ថកិច្ច ត្រូវដាក់កំហិតឱ្យធ្វើការចុះបញ្ជី ឬឯកសារផ្សេងទៀត ដែលត្រូវបានរក្សាទុក និងប្រើប្រាស់ដោយនិយោជក ។ បញ្ជី ឬឯកសារទាំងនេះ ត្រូវមានដាក់ឈ្មោះ និង អាយុ ឬ ប្រសិនបើអាច កាលបរិច្ឆេទកំណើតដោយមានការបញ្ជាក់ត្រឹមត្រូវរបស់បុគ្គលដែល និយោជកជួលប្រើ ឬ អ្នកដែល ធ្វើការឱ្យនិយោជក និង អ្នកដែលមានអាយុតិចជាង ១៦ ឆ្នាំ ។

មាត្រា១០

(១)អនុសញ្ញានេះធ្វើការពិនិត្យឡើងវិញទៅលើលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រានេះ អាយុអប្បបរមា (ឧស្សាហកម្ម)អនុសញ្ញា១៩១៩ - អាយុអប្បបរមា (សមុទ្រ)អនុសញ្ញា ១៩២០- អាយុអប្បបរមា (កសិកម្ម) អនុសញ្ញា ១៩២១ - អាយុអប្បបរមា (ការថែរក្សា និងដុតភ្លើងឡចំហាយ ឬម៉ាស៊ីនចំហាយ) អនុសញ្ញា១៩២១- អាយុអប្បបរមា (ការងារក្រៅឧស្សាហកម្ម) អនុសញ្ញា១៩៣២ - អាយុអប្បបរមា (សមុទ្រ) អនុសញ្ញា (បន្ថែម)១៩៣៦ អាយុអប្បបរមា (ឧស្សាហកម្ម) អនុសញ្ញា (បន្ថែម) ១៩៣៧- អាយុអប្បបរមា(ការងារ ក្រៅឧស្សហកម្ម) អនុសញ្ញា(បន្ថែម)១៩៣៧ - អាយុអប្បបរមា (ការនេសាទ) អនុសញ្ញា ១៩៥៩ និង អាយុអប្បបរមា (ការងារក្រោមដី) អនុសញ្ញា ១៩៦៥ ។

(២)ការចូលជាធរមាននៃអនុសញ្ញានេះ មិនត្រូវបិទចំពោះ អនុសញ្ញា (បន្ថែម) ១៩៣៦ អាយុអប្បបរមា (សមុទ្រ)- អនុសញ្ញា (បន្ថែម)១៩៣៧ អាយុអប្បបរមា (ឧស្សាហកម្ម) - អនុសញ្ញា (បន្ថែម) ១៩៣៧ អាយុអប្បបរមា (ការងារក្រៅឧស្សហកម្ម) - អនុសញ្ញា ១៩៥៩ អាយុអប្បបរមា (ការនេសាទ) ឬ អនុសញ្ញា ១៩៦៥ អាយុអប្បបរមា(ការងារក្រោមដី) ចំពោះការផ្តល់សច្ចាប័ន ។

(៣) អាយុអប្បបរមា (ឧស្សាហកម្ម) អនុសញ្ញា ១៩១៩ - អាយុអប្បបរមា (សមុទ្រ) អនុសញ្ញា ១៩២០ អាយុអប្បបរមា (កសិកម្ម) អនុសញ្ញា ១៩២១ - និង អាយុអប្បបរមា (ការថែរក្សា និងដុតភ្លើងឡចំហាយ ឬម៉ាស៊ីនចំហាយ) អនុសញ្ញា ១៩២១ ត្រូវបានបញ្ឈប់ការសម្រេចផ្តល់សច្ចាប័ន នៅពេលអ្នកចូលរួមទាំង អស់បានយល់ព្រមលើការបញ្ឈប់នេះ ដោយការផ្តល់សច្ចាប័នលើអនុសញ្ញានេះ ឬដោយធ្វើសេចក្តីថ្លែង ការណ៍ជូនទៅអគ្គនាយកនៃការិយាល័យពលកម្មអន្តរជាតិ ។

(៤)នៅពេលកាតព្វកិច្ចនៃអនុសញ្ញានេះត្រូវបានទទួលយក

(ក)ដោយសមាជិកដែលជាអ្នកចូលរួមក្នុងអនុសញ្ញា (បន្ថែម) ១៩៣៧ អាយុអប្បបរមា (ឧស្សាហកម្ម) និងអាយុអប្បបរមាមិនតិចជាង ១៥ ឆ្នាំ ដែលត្រូវបានកំណត់ ដូចមានចែងក្នុងមាត្រា ២ នៃអនុសញ្ញានេះ គឺចាំបាច់ត្រូវធ្វើដោយនីតិន័យសុំរំសាយភ្លាមនូវអនុសញ្ញានោះ។

(ខ) លក្ខណៈពិសេសនៃការងារមិនមែនឧស្សាហកម្ម ដូចបានកំណត់នៅក្នុងអាយុអប្បបរមា (មិនមែនការងារឧស្សាហកម្ម) អនុសញ្ញា១៩៣២ ដោយសមាជិកដែលជាអ្នកចូលរួមក្នុងអនុសញ្ញានោះ គឺចាំបាច់ត្រូវធ្វើដោយនីតិន័យសុំរំសាយភ្លាមនូវអនុសញ្ញានោះ ។

(គ) លក្ខណៈពិសេសនៃការងារមិនមែនឧស្សាហកម្ម ដូចបានកំណត់នៅក្នុងអនុសញ្ញា (បន្ថែម) ១៩៣៧ អាយុអប្បបរមា (មិនមែនការងារឧស្សាហកម្ម) ដោយសមាជិកដែលជាអ្នកចូលរួមក្នុងអនុសញ្ញានោះ និងអាយុ អប្បបរមាមិនតិចជាង ១៥ ឆ្នាំ ដែលត្រូវបាន កំណត់ ដូចមានចែងក្នុងមាត្រា ២ នៃអនុសញ្ញានេះ គឺចាំបាច់ត្រូវ ធ្វើ ដោយនីតិន័យសុំរំសាយភ្លាមនូវអនុសញ្ញានោះ ។

(ឃ) លក្ខណៈពិសេសនៃការងារសមុទ្រ ដោយសមាជិកដែលជាអ្នកចូលរួមក្នុងអនុសញ្ញា (បន្ថែម) ១៩៣៦ ស្តីពីអាយុអប្បបរមា(សមុទ្រ)និងអាយុអប្បបរមាមិនតិចជាង ១៥ ឆ្នាំ ដែលត្រូវបាន កំណត់ ដូចមានចែង ក្នុងមាត្រា ២ នៃអនុសញ្ញានេះ ឬសមាជិកដែលបានបញ្ជាក់ថា មាត្រា ៣ នៃអនុសញ្ញានេះដាក់ស្នើចំពោះការងារសមុទ្រគឺចាំបាច់ត្រូវធ្វើដោយនីតិន័យសុំរំសាយភ្លាមនូវអនុសញ្ញានោះ។

(ង) លក្ខណៈពិសេសនៃការងារសមុទ្រ ដោយសមាជិកដែលជាអ្នកចូលរួមក្នុងអនុសញ្ញា ១៩៥៩ ស្តីពីអាយុអប្បបរមា(សមុទ្រ)និងអាយុអប្បបរមាមិនតិចជាង១៥ឆ្នាំ ដែលត្រូវបានកំណត់ដូចមានចែងក្នុងមាត្រា ២ នៃអនុសញ្ញានេះ ឬសមាជិកដែលបានបញ្ជាក់ថា មាត្រា ៣ នៃអនុសញ្ញានេះដាក់ស្នើចំពោះការងារសមុទ្រ គឺចាំបាច់ត្រូវធ្វើដោយនីតិន័យសុំរំសាយភ្លាមនូវអនុសញ្ញានោះ ។

(ច) ដោយសមាជិកដែលជាអ្នកចូលរួមក្នុងអនុសញ្ញា ១៩៦៥ ស្តី ពីអាយុអប្បបរមា (ការងារក្រោមដី) និង អាយុអប្បបរមាដែលមិនតិចជាងអាយុកំណត់ដូចមានចែងក្នុងអនុសញ្ញានោះបានត្រូវដូចមានចែងក្នុងមាត្រា២នៃអនុសញ្ញានេះ ឬសមាជិកដែលបានកំណត់ថា អាយុទាំងនោះ ដាក់ស្នើចំពោះការងារអណ្តូងរ៉ែក្រោមដីក្នុងមាត្រា ៣ នៃអនុសញ្ញានេះ គឺចាំបាច់ត្រូវធ្វើដោយនីតិន័យសុំរំសាយភ្លាមនូវអនុសញ្ញានោះ ប្រសិនបើ និងនៅពេល អនុសញ្ញានេះត្រូវចូលជាធរមាន។

(៥) ការព្រមទទួលយកនូវកាតព្វកិច្ចនៃអនុសញ្ញានេះ

(ក) ចាំបាច់ត្រូវធ្វើការសុំរំសាយនូវ អាយុអប្បបរមា (ឧស្សហកម្ម) អនុសញ្ញា ១៩១៩ ដោយអនុលោម ទៅតាមមាត្រា ១២ នៃអនុសញ្ញានេះ

(ខ) ក្នុងលក្ខណៈពិសេសនៃការងារកសិកម្មចាំបាច់ ត្រូវធ្វើការសុំរំសាយនូវអាយុអប្បបរមា (កសិកម្ម) អនុសញ្ញា ១៩២១ ដោយអនុលោមតាមមាត្រា ៥ នៃអនុសញ្ញានេះ

(គ) ក្នុងលក្ខណៈពិសេសនៃការងារសមុទ្រចាំបាច់ត្រូវធ្វើការសុំរំសាយនូវអាយុអប្បបរមា(សមុទ្រ) អនុសញ្ញា ១៩២0 ដោយអនុលោមតាមមាត្រា ១0 នៃអនុសញ្ញានេះ និងអាយុអប្បបរមា

(ការថែរក្សា និងដុតភ្លើងឡចំហាយ ឬម៉ាស៊ីនចំហាយ)អនុសញ្ញា ១៩២១ ដោយអនុលោមតាមមាត្រា ១២ នៃអនុសញ្ញានេះ ប្រសិនបើនិងនៅពេលអនុសញ្ញា នេះត្រូវចូលជាធរមាន។

មាត្រា១១

ការផ្តល់សច្ចាប័នត្រឹមត្រូវនៃអនុសញ្ញានេះ នឹងត្រូវបញ្ជូនទៅអគ្គនាយកនៃការិយាល័យពលកម្មអន្តរជាតិ ដើម្បីធ្វើការចុះបញ្ជី ។

មាត្រា១២

(១) អនុសញ្ញានេះអាចមានអានុភាពតែចំពោះសមាជិកទាំងឡាយនៃអង្គការពលកម្មអន្តរជាតិដូចខាងលើ ដែលបានចុះបញ្ជីការផ្តល់សច្ចាប័នជាមួយអគ្គនាយក ។

(២) អនុសញ្ញានេះត្រូវចូលជាធរមានដប់ពីរខែក្រោយកាលបរិច្ឆេទលើការផ្តល់សច្ចាប័ននៃសមាជិកពីរ ដែលត្រូវបានចុះបញ្ជីជាមួយអគ្គនាយក ។

(៣) ក្រោយមកអនុសញ្ញានេះ ត្រូវចូលជាធរមានសម្រាប់សមាជិកទាំងអស់ដប់ពីរខែក្រោយកាលបរិច្ឆេទ នៃការផ្តល់សច្ចាប័នរបស់ខ្លួនត្រូវបានចុះបញ្ជី ។

មាត្រា១៣

(១) សមាជិកដែលបានផ្តល់សច្ចាប័នលើអនុសញ្ញានេះ អាចសុំរំសាយខ្លួនក្រោយពីការផុតកំណត់នៃរយៈពេលដប់ឆ្នាំ ចាប់ពីពេលដែលអនុសញ្ញាចូលជាធរមានលើកទីមួយ ដោយធ្វើសេចក្តីជូនដំណឹងទៅអគ្គនាយកនៃការិយាល័យពលកម្មអន្តរជាតិសម្រាប់ធ្វើការចុះបញ្ជី។ ការសុំរំសាយខ្លួននេះមិនមានប្រសិទ្ធភាពឡើយ លុះត្រាមួយ ឆ្នាំក្រោយកាលបរិច្ឆេទនៃការសុំរំសាយត្រូវបានចុះបញ្ជី ។

(២) សមាជិកដែលបានផ្តល់សច្ចាប័នលើអនុសញ្ញានេះ និងអ្នកដែលមិនបានផ្តល់ នៅក្នុងឆ្នាំបន្ទាប់ ពីការផុតកំណត់នៃរយៈពេលដប់ឆ្នាំដូចបានចែងក្នុងកថាខណ្ឌមុន ការប្រើប្រាស់សិទ្ធិក្នុងការសុំរំសាយខ្លួនដែលបានផ្តល់ក្នុង មាត្រានេះនឹងមានអានុភាពសម្រាប់រយៈពេលដប់ឆ្នាំទៀត និងក្រោយមកអាចសុំរំសាយអនុសញ្ញានេះនៅពេលផុតកំណត់នៃរយៈពេលដប់ឆ្នាំម្តង ក្រោមលក្ខខណ្ឌដែលបានផ្តល់ក្នុងមាត្រានេះ ។

មាត្រា១៤

(១) អគ្គនាយកនៃការិយាល័យពលកម្មអន្តរជាតិ ត្រូវជូនដំណឹងដោយលាយលក្ខណ៍អក្សរទៅគ្រប់សមាជិកទាំងអស់នៃអង្គការពលកម្មអន្តរជាតិ នូវការចុះបញ្ជីនៃការផ្តល់សច្ចាប័ន និងផ្សព្វផ្សាយសេចក្តីប្រកាសនៃការរំសាយខ្លួនដោយសមាជិកទាំងឡាយរបស់អង្គការទៅអគ្គនាយក។

(២) នៅពេលសេចក្តីជូនដំណឹងដល់សមាជិកទាំងឡាយរបស់អង្គការ ពីការចុះបញ្ជីនៃការផ្តល់សច្ចាប័នលើកទីពីរបានបញ្ជូនទៅអគ្គនាយក ត្រូវទាញការប្រុងប្រយ័ត្ននៃសមាជិកទាំងឡាយរបស់អង្គការចំពោះកាលបរិច្ឆេទពេល ដែលអនុសញ្ញានឹងត្រូវចូលជាធរមាន ។

មាត្រា១៥

អគ្គនាយកនៃការិយាល័យពលកម្មអន្តរជាតិ ត្រូវបញ្ជូនទៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ដើម្បីធ្វើការចុះបញ្ជី ដោយអនុលោមតាមមាត្រា ១០២ នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ គ្រប់ករណីពិសេសនៃការផ្តល់សច្ចាប័នទាំងអស់ និងសេចក្តីប្រកាសនូវការរំសាយខ្លួនត្រូវបានធ្វើការចុះបញ្ជីដោយ អគ្គនាយកដោយយោងទៅតាម បទបញ្ញត្តិនៃមាត្រាមុន។

មាត្រា១៦

នៅពេលចាំបាច់ អាចធ្វើការពិនិត្យនោះ ស្ថាប័នគ្រប់គ្រងនៃការិយាល័យពលកម្មអន្តរជាតិ ត្រូវដាក់ជូនសន្និសីទសកលនូវរបាយការណ៍ស្តីពីសកម្មភាពការងារនៃអនុសញ្ញានេះ និងត្រូវធ្វើការពិនិត្យជ្រើសរើសទុកជាមុនដាក់នៅក្នុងរបៀបវារៈនៃសន្និសីទនូវបញ្ហានៃការផ្លាស់ប្តូរអនុសញ្ញាទាំងស្រុង ឬក្នុងផ្នែកណាមួយ ។

មាត្រា១៧

(១) ប្រសិនបើសន្និសីទអនុម័តលើអនុសញ្ញាថ្មីដែលកែបន្ថែមលើអនុសញ្ញានេះនៅក្នុងផ្នែកណាមួយ ឬ ទាំងស្រុងនោះ លុះត្រាអនុសញ្ញាថ្មីព្រមព្រៀងតាមបែប :

(a) ការផ្តល់សច្ចាប័នដោយសមាជិកនៃអនុសញ្ញាថ្មីកែបន្ថែមចាំបាច់ត្រូវប្រកាសរំសាយនូវអនុសញ្ញានេះភ្លាម ដូចក្នុងបទបញ្ញត្តិទាំងអស់នៃមាត្រា១៣ខាងលើ ប្រសិនបើនិងនៅពេលអនុសញ្ញាថ្មីកែបន្ថែមត្រូវចូលជាធរមាន

(b) ចាប់តាំងពីពេលដែលអនុសញ្ញាថ្មីកែបន្ថែមចូលជាធរមាន អនុសញ្ញានេះត្រូវបានបិទចំពោះការផ្តល់សច្ចាប័នដោយសមាជិកទាំងឡាយ។

(២) អនុសញ្ញានេះ យ៉ាងណាក៏នៅមានអានុភាពចំពោះសមាជិកទាំងឡាយដែលពេញចិត្ត ហើយដែលបានផ្តល់សច្ចាប័ន ប៉ុន្តែមិនផ្តល់សច្ចាប័នលើអនុសញ្ញាថ្មីកែបន្ថែម ។

មាត្រា១៨

ភាសាអង់គ្លេស និងបារាំង ការប្រែពីភាសាបរទេសមកភាសាកំណើតនៃអត្ថបទអនុសញ្ញានេះមានអានុភាពស្មើគ្នា ។

៥.អនុសញ្ញានៃអង្គការពលកម្មអន្តរជាតិលេខ១៨២ស្តីពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ឆ្នាំ១៩៩៩

អនុសញ្ញាទាក់ទងនឹងការហាមឃាត់ និងសកម្មភាពជាបន្ទាន់ក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្ម កុមារ
(កំណត់សម្គាល់ : កាលបរិច្ឆេទចូលជាធរមាន :១៩ វិច្ឆិកា ២000) សន្និសីទសកលនៃអង្គការពលកម្ម អន្តរជាតិ

- ដោយមានការកោះប្រជុំនៅទីក្រុងហ្សឺណែវ ដោយស្ថាប័នគ្រប់គ្រងរបស់ការិយាល័យពលកម្មអន្តរជាតិ និងធ្វើការជួបប្រជុំលើកទី៨៧ នាសម័យប្រជុំទី១ មិថុនា ១៩៩៩

និងដោយសង្កេតឃើញនូវសេចក្តីត្រូវការក្នុងការ ប្រើប្រាស់ឯកសារថ្មីក្នុងការដាក់បំរាម និងលុបបំបាត់នូវទម្រង់ធ្ងន់នៃពលកម្មកុមារដែលជាអាទិភាពសំខាន់សម្រាប់សកម្មភាពជាតិ និងអន្តរជាតិរួមបញ្ចូលទាំងជំនួយឧបត្ថម្ភនិងកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការអនុវត្តន៍អនុសញ្ញា និងសេចក្តីព្រមព្រៀងទាក់ទងនឹងអាយុអប្បរមាក្នុងការអនុញ្ញាតឱ្យចូលបំរើការងារ១៩៧៣ដែលនៅតែជាឯកសារគ្រឹះស្តីពីពលកម្មកុមារនិង

- ដោយសង្កេតឃើញថាប្រសិទ្ធភាពនៃការលុបបំបាត់នូវទម្រង់ធ្ងន់ធ្ងរ នៃពលកម្មកុមារឱ្យមានសកម្មភាពជាបន្ទាន់ និងទូលំទូលាយដោយគិតគូរដល់សារៈសំខាន់នៃការអប់រំមូលដ្ឋានដោយសេរី និងការក្នុងការយកកុមារទាក់ទិនទាំងនេះចេញពីការងារបែបនោះ និងផ្តល់ឱ្យពួកគេមានសម្បទាឡើងវិញ ហើយបញ្ចូល ពួកគេទៅក្នុងសង្គមវិញ នៅពេលប្រឈមទៅនឹងតម្រូវការរបស់គ្រួសារពួកគេ និង

- ដោយរំលឹកឡើងវិញនូវសេចក្តីសម្រេចទាក់ទងទៅនឹងការលុបបំបាត់នូវពលកម្មកុមារ ដែលបានអនុម័តដោយសន្និសីទពលកម្មអន្តរជាតិនាសម័យប្រជុំលើកទី៨៣ក្នុងឆ្នាំ ១៩៩៦ និងដោយទទួលស្គាល់ថាពលកម្មកុមារមានវិសាលភាពធំធេងបង្កឡើងដោយភាពក្រីក្រ និងត្រូវប្រើពេលយូរដែលអាចដោះស្រាយបាននៅក្នុងការលូតលាស់ផ្នែកសេដ្ឋកិច្ចទ្រទ្រង់ការដឹកនាំវឌ្ឍនភាពសង្គម ជាពិសេសធ្វើឱ្យធូរស្រាលនូវភាពក្រីក្រ និងការអប់រំជាសកលនិង

- ដោយរំលឹកឡើងវិញពីអនុសញ្ញាស្តីពីសិទ្ធិរបស់កុមារដែលបានអនុម័ត ដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី២0វិច្ឆិកា១៩៨៩និង

- ដោយរំលឹកឡើងវិញនូវសេចក្តីប្រកាសរបស់អង្គការពលកម្មអន្តរជាតិស្តីពីគោលការណ៍គ្រឹះ និងសិទ្ធិធ្វើការងារ និងការអនុវត្តន៍បន្ត ត្រូវបានអនុម័តដោយសន្និសិទអន្តរជាតិខាងការងារ ក្នុងសម័យប្រជុំលើក ទី៨៦ ក្នុងឆ្នាំ១៩៩៨ និង

- ដោយរំលឹកឡើងវិញថា ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារខ្លះក្នុងឯកសារអន្តរជាតិ ដទៃទៀតជាពិសេសពលកម្មដោយបង្ខិតខំអនុសញ្ញា១៩៣0និងអនុសញ្ញាបំពេញបន្ថែមអង្គការសហប្រជាជាតិស្តីពីការលុបបំបាត់នូវទាសភាពការលក់ដូរជាទាស ករការចាត់តាំង និងការប្រព្រឹត្តដែលប្រហាក់ប្រហែលនឹងទាសភាព ១៩៥0 និង

- ដោយមានសេចក្តីសម្រេចលើការអនុម័តនូវសំណើដ៏ត្រឹមត្រូវ ដែលទាក់ទងទៅនឹងពលកម្មកុមារ ដែលមាននៅក្នុងរបៀបវារៈបួននៃសម័យប្រជុំនីង

- ដោយមានការប្តេជ្ញាចិត្តជាសំណើទាំងនេះត្រូវទុកជាប្រភេទនៃអនុសញ្ញាអន្តរជាតិបានអនុម័តនៅ ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ១៩៩៤ អនុសញ្ញាខាងក្រោមដែលអាចចាត់ទុកជាទម្រង់ធ្ងន់ធ្ងរ នៃពលកម្មកុមារអនុសញ្ញា ១៩៩៩។

មាត្រា១

គ្រប់សមាជិកដែលផ្តល់សច្ចាប័នលើអនុសញ្ញានេះ ត្រូវប្រកាន់យករាល់វិធានការប្រកបដោយប្រសិទ្ធភាព និងជាបន្ទាន់ ក្នុងការធានាការដាក់បំរាម និងការលុបបំបាត់នូវទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារជាសកម្មភាពបន្ទាន់បំផុត។

មាត្រា២

ក្នុងគោលដៅនៃអនុសញ្ញានេះពាក្យថាកុមារត្រូវអនុវត្តចំពោះមនុស្សទាំងអស់ដែលមានអាយុក្រោម១៨ឆ្នាំ

មាត្រា៣

ក្នុងគោលដៅនៃអនុសញ្ញានេះពាក្យទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមាររាប់បញ្ចូល :

(ក) គ្រប់ទម្រង់នៃទាសភាព ឬការប្រព្រឹត្តប្រហាក់ប្រហែលនឹងទាសភាពដូចជាការលក់ និងការជួញដូរកុមារ ភាពជាខ្ញុំកញ្ជះ និងភាពជាខ្ញុំកញ្ជះដាច់ថ្លៃ ដើម្បីដោះបំណុល និងពលកម្មដោយការបង្ខិតបង្ខំ កុមារដើម្បីបម្រើក្នុងជម្លោះប្រដាប់អាវុធ។

(ខ) ការប្រើ ការផ្តល់ឱ្យ ឬការស្នើឱ្យកុមារធ្វើពេស្យាចារសម្រាប់ផលិតផលនៃកាមសាស្ត្រ ឬសម្តែងក្នុងរូបភាពអាសអាភាស។

(គ) ការប្រើប្រាស់ ការផ្តល់ ឬការស្នើឱ្យកុមារធ្វើនូវសកម្មភាពខុសច្បាប់ ជាពិសេសសម្រាប់ផលិត ឬជួញដូរគ្រឿងញៀនដូចបានកំណត់អត្ថន័យច្បាស់លាស់នៅក្នុងសន្ធិសញ្ញាអន្តរជាតិ។

(ឃ) ការងារណាដែលជាប្រភេទ ឬក្នុងករណីដែលធ្វើឱ្យប៉ះពាល់ដល់សុខភាព សុវត្ថិភាព និងសីលធម៌របស់កុមារ។

មាត្រា៤

(១) ប្រភេទនៃការងារយោងតាមមាត្រា៣ (ឃ) ត្រូវបានកំណត់ដោយច្បាប់ជាតិ ឬ បទបញ្ជា ឬ ដោយអាជ្ញាធរមានសមត្ថកិច្ចបន្ទាប់ពីពិភាក្សាពិគ្រោះយោបល់ជាមួយអង្គការនិយោជក និងអ្នកធ្វើការទាំងអស់ដែលទាក់ទិនដោយគិតគូរទៅដល់បទដ្ឋាន (ខ្នាតគំរូ) អន្តរជាតិជាពិសេសកថាខណ្ឌ៣ និង៤នៃសេចក្តីព្រមព្រៀង១៩៩៩ ស្តីពី ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។

(២) អាជ្ញាធរមានសមត្ថកិច្ចក្រោយពីពិគ្រោះយោបល់ជាមួយអង្គការនិយោជក និងអ្នកធ្វើការទាំងអស់ដែលទាក់ទិនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរនៅទីណាដែលប្រភេទការងារត្រូវបានកំណត់ឱ្យមាន។

(៣) បញ្ជីនៃប្រភេទការងារដែលបានកំណត់ក្នុងកថាខណ្ឌ១នៃមាត្រានេះត្រូវបានពិនិត្យយូរៗម្តង និងធ្វើការផ្លាស់ប្តូរប្រសិនបើចាំបាច់នៅក្នុងការពិគ្រោះយោបល់ជាមួយអង្គការនិយោជក និងអ្នកធ្វើការដែលទាក់ទិនទាំងអស់។

មាត្រា៥

ក្រោយការពិគ្រោះយោបល់ជាមួយអង្គការនិយោជក និងអ្នកធ្វើការដែលទាក់ទិនទាំងអស់ សមាជិកនីមួយៗត្រូវបង្កើតឱ្យមាន ឬជ្រើសរើសយកនូវរបៀបត្រួតពិនិត្យដ៏សមស្របនូវការអនុវត្តន៍បទបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះប្រកបដោយប្រសិទ្ធភាព។

មាត្រា៦

(១) គ្រប់សមាជិកទាំងអស់ត្រូវរៀបចំ និងអនុវត្តនូវកម្មវិធីទាំងឡាយនៃសកម្មភាពការងារលុបបំបាត់នូវទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារដែលជាការងារអាទិភាព។

(២) កម្មវិធីទាំងនេះត្រូវបានរៀបចំ និងអនុវត្តនៅក្នុងការពិគ្រោះយោបល់ជាមួយស្ថាប័នគ្រប់គ្រងដែលពាក់ព័ន្ធទាំងអស់ និងអង្គការនិយោជក និងអ្នកធ្វើការទាក់ទិនទាំងអស់ ដោយគិតគូរដ៏សមស្របពីទស្សនៃក្រុមឯទៀតដែលពាក់ព័ន្ធ ។

មាត្រា៧

(១) គ្រប់សមាជិកទាំងអស់ត្រូវប្រកាន់យកនូវរាល់វិធានការចាំបាច់ទាំងឡាយក្នុងការធានាការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពនិងការប្រតិបត្តិនូវបទបញ្ញត្តិទាំងឡាយដែលធ្វើឱ្យអនុសញ្ញានេះមានប្រសិទ្ធភាពរួមបញ្ចូលបទបញ្ញត្តិ និងសំណើនៃការដាក់ទោសទណ្ឌឬសំណើផ្សេងៗទៀតដែលសមស្រប ។

(២) គ្រប់សមាជិកទាំងអស់ត្រូវគិតគូរទៅដល់សារៈសំខាន់នៃការអប់រំនៅក្នុងការលុបបំបាត់ពលកម្មកុមារប្រកាន់យកវិធានការប្រកបដោយប្រសិទ្ធភាព និងឆ្ពោះទៅរក :

(ក) ការពារការជួលកុមារនៅក្នុងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

(ខ) ផ្តល់ឱ្យនូវជំនួយឧបត្ថម្ភដ៏សមស្រប និងចាំបាច់ដោយផ្ទាល់ក្នុងការយកកុមារចេញពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ និងក្នុងការធ្វើឱ្យពួកគេមានសម្បទាឡើងវិញ ហើយបញ្ចូលពួកគេទៅក្នុងសង្គមវិញ។

(គ) ធានាការទទួលបាននូវការអប់រំមូលដ្ឋានដោយសេរី និងការបណ្តុះបណ្តាលវិជ្ជាជីវៈដ៏សមស្រប និងអាចទទួលបាននៅគ្រប់ទីកន្លែងសម្រាប់កុមារដែលយកចេញពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។

(ឃ) កំណត់ឱ្យបាន និងទៅឱ្យដល់កុមារ ដែលស្ថិតនៅក្នុងស្ថានភាពប្រថុយប្រថាន និង

(ង) គិតគូទៅដល់ស្ថានភាពកុមារីជាពិសេស

(៣) គ្រប់សមាជិកទាំងអស់ត្រូវជ្រើសរើសអាជ្ញាធរមានសមត្ថកិច្ចដែលទទួលខុសត្រូវក្នុងការអនុវត្តន៍បទបញ្ញត្តិទាំងឡាយ ដែលធ្វើឱ្យអនុសញ្ញានេះមានប្រសិទ្ធភាព។

មាត្រា៨

រាល់សមាជិកត្រូវឈានជាជំហាន។ដ៏សមស្របក្នុងការជួយធ្វើឱ្យបទបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះមានប្រសិទ្ធភាពតាមរយៈការបង្កើនកិច្ចសហប្រតិបត្តិការ និង ឬ កិច្ចសង្គ្រោះអន្តរជាតិ រួមបញ្ចូលទាំងការឧបត្ថម្ភដើម្បីអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច កម្មវិធីបំបាត់ភាពក្រីក្រ និងសកលកម្មអប់រំ ។

មាត្រា៩

ទម្រង់នៃការផ្តល់សច្ចាប័នជាក់លាក់នៃអនុសញ្ញានេះ ត្រូវបានបញ្ជូនទៅអគ្គនាយកនៃការិយាល័យពលកម្មអន្តរជាតិ ដើម្បីធ្វើការចុះបញ្ជី ។

មាត្រា១០

(១) អនុសញ្ញានេះមានអានុភាពតែចំពោះសមាជិកទាំងឡាយនៃអង្គការពលកម្មអន្តរជាតិដូចខាងលើដែលបានចុះបញ្ជីការផ្តល់សច្ចាប័នជាមួយអគ្គនាយកនៃការិយាល័យពលកម្មអន្តរជាតិ ។

(២) អនុសញ្ញានេះត្រូវចូលជាធរមាន ១២ ខែ ក្រោយកាលបរិច្ឆេទនៃការផ្តល់សច្ចាប័នរបស់សមាជិកពីរត្រូវបានចុះបញ្ជីជាមួយអគ្គនាយក ។

(៣) ក្រោយមកអនុសញ្ញានេះត្រូវចូលជាធរមានសម្រាប់សមាជិកទាំងអស់ ១២ខែ ក្រោយកាលបរិច្ឆេទនៃការផ្តល់សច្ចាប័នរបស់ខ្លួនត្រូវបានចុះបញ្ជី ។

មាត្រា១១

(១)សមាជិកដែលបានផ្តល់សច្ចាប័នលើអនុសញ្ញានេះអាចរំសាយខ្លួនក្រោយពីរការផុតកំណត់នៃរយៈពេល ១០ឆ្នាំចាប់ពីពេលដែលអនុសញ្ញាចូលជាធរមានលើកទីមួយ ដោយធ្វើសេចក្តីជូនដំណឹងទៅអគ្គនាយកនៃការិយាល័យពលកម្មអន្តរជាតិដើម្បីធ្វើការចុះញ្ជី។

ការរំសាយខ្លួននេះមិនមានប្រសិទ្ធភាពឡើយ លុះត្រាមួយឆ្នាំក្រោយកាលបរិច្ឆេទនៃការរំសាយខ្លួនត្រូវបានចុះបញ្ជី ។

(២) សមាជិកដែលបានផ្តល់សច្ចាប័នលើអនុសញ្ញានេះ និងអ្នកដែលមិនបានផ្តល់នៅក្នុងឆ្នាំបន្ទាប់ពីការផុតកំណត់រយៈពេល១០ឆ្នាំ ដូចដែលបានចែងក្នុងកថាខណ្ឌមុន ការប្រើប្រាស់សិទ្ធិក្នុងការរំសាយខ្លួនដែលបានផ្តល់ក្នុងមាត្រានេះ នឹងមានអានុភាពសម្រាប់រយៈពេល១០ឆ្នាំទៀត និងបន្ទាប់មកអាចរំសាយអនុសញ្ញានេះ នៅពេលផុត កំណត់រយៈពេល១០ឆ្នាំម្តង ក្រោមលក្ខណ្ឌដែលបានផ្តល់ក្នុងមាត្រានេះ ។

មាត្រា១២

(១) អគ្គនាយកនៃការិយាល័យពលកម្មអន្តរជាតិ ត្រូវជូនដំណឹងដោយលាយលក្ខណ៍អក្សរទៅគ្រប់សមាជិកទាំងអស់នៃអង្គការពលកម្មអន្តរជាតិ នូវការចុះបញ្ជីនៃការផ្តល់សច្ចាប័ន និងបញ្ជូនសេចក្តីប្រកាសនៃការរំសាយ ខ្លួនដោយសមាជិកទាំងឡាយរបស់អង្គការទៅអគ្គនាយក ។

(២) នៅពេលសេចក្តីជូនដំណឹងដល់សមាជិកទាំងឡាយរបស់អង្គការពីការចុះបញ្ជីនៃការផ្តល់សច្ចាប័នលើកទីពីរបានបញ្ជូនទៅអគ្គនាយកត្រូវទាញការប្រុងប្រយ័ត្ននៃសមាជិកទាំងឡាយរបស់អង្គការចំពោះកាលបរិច្ឆេទដែល អនុសញ្ញាត្រូវចូលជាធរមាន ។

មាត្រា១៣

អគ្គនាយកនៃការិយាល័យពលកម្មអន្តរជាតិ ត្រូវបញ្ជូនទៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ដើម្បីធ្វើការចុះបញ្ជី ដោយអនុលោមតាមមាត្រា១០២ នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិគ្រប់ករណីពិសេសនៃការផ្តល់សច្ចាប័នទាំងអស់ និងសេចក្តីប្រកាសនូវការរំលាយខ្លួនបានធ្វើការចុះបញ្ជីដោយ អគ្គនាយកដោយយោងទៅតាមបទបញ្ញត្តិនៃមាត្រាមុន។

មាត្រា១៤

នៅពេលដែលចាំបាច់អាចធ្វើការពិនិត្យនោះ ស្ថាប័នគ្រប់គ្រងនៃការិយាល័យពលកម្មអន្តរជាតិ ត្រូវដាក់ជូនសន្និសីទសកលនូវរបាយការណ៍ស្តីពីសកម្មភាពការងារនៃអនុសញ្ញានេះ និងត្រូវធ្វើការពិនិត្យជ្រើសរើសទុកជាមុនដាក់នៅក្នុងរបៀបវារៈនៃសន្និសីទនូវបញ្ហានៃការផ្លាស់ប្តូរអនុសញ្ញាទាំងស្រុង ឬក្នុងផ្នែកណាមួយ។

មាត្រា១៥

(១) ប្រសិនបើសន្និសិទអនុម័តលើអនុសញ្ញាថ្មី ដែលកែបន្ថែមលើអនុសញ្ញានេះនៅក្នុងផ្នែកណាមួយ ឬទាំងស្រុងនោះ លុះត្រាអនុសញ្ញាថ្មីព្រមព្រៀងតាមបែប :

(a) ការផ្តល់សច្ចាប័នដោយសមាជិកនៃអនុសញ្ញាថ្មីកែបន្ថែម ចាំបាច់ត្រូវប្រកាសរំសាយនូវអនុសញ្ញានេះភ្លាមដូចក្នុងបទបញ្ញត្តិទាំងអស់នៃមាត្រា១១ខាងលើ ប្រសិនបើ និងនៅពេលអនុសញ្ញាថ្មីកែបន្ថែមត្រូវចូលជាធរមាន។

(b) ចាប់តាំងពីពេលដែលអនុសញ្ញាថ្មីកែបន្ថែមចូលជាធរមាន អនុសញ្ញានេះត្រូវបានបិទចំពោះការផ្តល់សច្ចាប័នរបស់សមាជិកទាំងឡាយ.

(២) អនុសញ្ញានេះនៅមានអានុភាពចំពោះសមាជិកទាំងឡាយដែលពេញចិត្ត ហើយដែលបានផ្តល់សច្ចាប័ន ប៉ុន្តែមិនផ្តល់សច្ចាប័នលើអនុសញ្ញាថ្មីកែបន្ថែម ។

មាត្រា១៦

អត្ថបទជាភាសាអង់គ្លេសនិងបារាំងនៃអនុសញ្ញានេះគឺ មានតម្លៃស្មើគ្នា ។

៥.សេចក្តីថ្លែងការណ៍នៃអង្គការពលកម្មអន្តរជាតិស្តីពីគោលការណ៍និងសិទ្ធិជាមូលដ្ឋានទៅកន្លែងការងារ

ដោយហេតុថាអង្គការពលកម្មអន្តរជាតិត្រូវបានស្ថាបនាឡើងនៅក្នុងការជឿជាក់ថា យុត្តិធម៌សង្គមមានសារៈសំខាន់ជាសាកល និងសន្តិភាពជារៀងរហូត ។

ដោយហេតុថាការលូតលាស់សេដ្ឋកិច្ចគឺជាការចាំបាច់ ប៉ុន្តែមិនគ្រប់គ្រាន់ទេក្នុងការធានានូវសមធម៌ វឌ្ឍនភាពសង្គម និងការលុបបំបាត់ភាពក្រីក្រ ការអះអាងរបស់អង្គការពលកម្មអន្តរជាតិពីការក្នុងការជំរុញនូវគោលនយោបាយដ៏រឹងមាំ ស្ថាប័នច្បាប់ និងប្រជាធិបតេយ្យ ។

ដោយហេតុថា អង្គការពលកម្មអន្តរជាតិ គួរតែលើកឡើងពីការកំណត់ច្បាប់ការឱ្យមានលក្ខណៈស្តង់ដា កិច្ចសហប្រតិបត្តិការបច្ចេកទេស និងរិះរកធនធានដែលមានសមត្ថភាពនៅក្នុងគ្រប់តំបន់របស់ខ្លួន ជាពិសេសការងារការបណ្តុះបណ្តាលវិជ្ជាជីវៈ និងលក្ខណៈការងារក្នុងការធានាថានៅក្នុងបរិបទនៃយុទ្ធសាស្ត្រទាំងអស់ដើម្បីការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម គោលនយោបាយ សង្គម និងសេដ្ឋកិច្ចធ្វើការពង្រឹង សមាភាពទៅវិញទៅមក ដើម្បីរៀបចំបង្កើតនូវការទ្រទ្រង់ការអភិឌ្ឍក្នុងស្ថានភាព ទូលំទូលាយ ។

ដោយហេតុថា អង្គការពលកម្មអន្តរជាតិត្រូវផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើបញ្ហាមនុស្សជាមួយនឹងតម្រូវការចាំបាច់ក្នុងសង្គម ជាពិសេសភាពគ្មានការងារធ្វើ អ្នកធ្វើការងារនៅក្រៅប្រទេស ការលើកទឹកចិត្តនិងការធ្វើឱ្យមានការប្រែប្រួលនូវកិច្ចប្រឹងប្រែងជាតិ អន្តរជាតិ និងក្នុងតំបន់ ក្នុងការដោះស្រាយបញ្ហារបស់ខ្លួន និងជំរុញប្រសិទ្ធភាព គោលនយោបាយក្នុងគោលដៅបង្កើតឱ្យមានការងារធ្វើ ។

ដោយហេតុថា ក្នុងការខិតខំរក្សានូវទំនាក់ទំនងរវាងវឌ្ឍនភាពសង្គម និងការលូតលាស់សេដ្ឋកិច្ច ការធានានូវគោលការណ៍គ្រឹះ និងសិទ្ធិក្នុងការងារ គឺជាផ្នែកដ៏សំខាន់ដែលក្នុងនោះបុគ្គលធ្វើការទាមទារដោយសេរី និងដោយផ្អែកលើមូលដ្ឋាននៃឱកាសស្មើភាពទទួលបានដោយយុត្តិធម៌នូវទ្រព្យសម្បត្តិដែលពួកគេត្រូវបាន និងសម្រេចពេញលេញនូវសក្តានុភាពរបស់ខ្លួន ។

ដោយហេតុថាអង្គការពលកម្មជាតិ ត្រូវបានប្រគល់អណត្តិឱ្យត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញនៃអង្គការអន្តរជាតិ និងស្ថាប័នមានសមត្ថកិច្ចរៀបចំ និងដោះស្រាយទៅតាមមាត្រដ្ឋាន (ខ្នាតតំរូ)ពលកម្មអន្តរជាតិ និងចូលរួមគាំទ្រជាសកល និងការទទួលស្គាល់ក្នុងការជំរុញសិទ្ធិគ្រឹះក្នុងការងារ ដែលជាការសម្តែងចេញនូវគោលការណ៍នៃរដ្ឋធម្មនុញ្ញរបស់ខ្លួន

ដោយហេតុថាជាការចាំបាច់នៅក្នុងស្ថានភាពអាស្រ័យគ្នាទៅវិញទៅមកនៃការលូតលាស់សេដ្ឋកិច្ច ក្នុងការបញ្ជាក់អះអាងជាថ្មីពីភាពមិនចេះប្រែប្រួលនៃគោលការណ៍គ្រឹះ និងសិទ្ធិតំណាងក្នុងរដ្ឋធម្មនុញ្ញរបស់អង្គការ និងជំរុញការអនុវត្តន៍ជាសកលរបស់ខ្លួន ។

សន្និសីទពលកម្មអន្តរជាតិ

១-រំលឹកឡើងវិញ :

(ក)ថាការចូលរួមដោយសេរីក្នុងអង្គការពលកម្មអន្តរជាតិ សមាជិកទាំងអស់បានយល់ព្រមនឹងគោលការណ៍និងសិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញរបស់ខ្លួន និងក្នុងសេចក្តីថ្លែងការណ៍នៃPhiladelphia ... និង បានសន្យាធ្វើឱ្យបានសម្រេចនូវគោលដៅទាំងមូលរបស់អង្គការក្នុងធនធានដ៏ល្អបំផុតរបស់ខ្លួន និងស្របទៅនឹងឱកាសដ៏ជាក់លាស់របស់ខ្លួន ។

(ខ) ថាគោលការណ៍ និងសិទ្ធិទាំងនេះត្រូវបានអភិវឌ្ឍ និងស្តែងចេញនៅក្នុងទម្រង់ជាសិទ្ធិ និងជាកាតព្វកិច្ចជាក់លាក់ក្នុងអនុសញ្ញាទាំងឡាយ ដែលទទួលស្គាល់ថាជាមូលដ្ឋានគ្រឹះទាំងក្នុង និងក្រៅអង្គការ ។

២- ប្រកាសថាសមាជិកទាំងឡាយ ទោះបីពួកគេពុំបានផ្តល់សច្ចាប័នលើអនុសញ្ញានេះក្តី ត្រូវមានកាតព្វកិច្ចក្នុងនាមជាសមាជិកភាពដ៏ពិតប្រាកដក្នុងអង្គការត្រូវគោរពជំរុញនិងធ្វើឱ្យជាក់ស្តែងនៅក្នុងការស្មើជាក់ច្បាស់ និងដោយអនុលោមទៅនឹងរដ្ឋធម្មនុញ្ញ គោលការណ៍ទាក់ទងទៅនឹងសិទ្ធិគ្រឹះ ដែលជាបញ្ញត្តិនៃអនុសញ្ញានោះគឺ :

ក-សេរីភាពនៃការចូលរួម និងការទទួលស្គាល់ប្រសិទ្ធភាពនៃសិទ្ធិក្នុងការព្រមព្រៀងការប្រមូលផ្តុំ (សហការណ៍)

ខ- ការបំបាត់ទាំងអស់នូវទម្រង់ពលកម្មដោយបង្ខិតបង្ខំ

គ-ប្រសិទ្ធភាពនៃការលុបបំបាត់នូវពលកម្មកុមារ និង

ឃ-ការបំបាត់នូវការរើសអើងនៅក្នុងការងារ និងអាជីព

៣- ទទួលស្គាល់នូវកាតព្វកិច្ចចំពោះអង្គការក្នុងការជួយឧបត្ថម្ភសមាជិកទាំងឡាយរបស់ខ្លួនក្នុងការឆ្លើយតបទៅនឹងការបង្កើតឱ្យមាន និងការសម្តែងនូវការរបស់ខ្លួន ដើម្បីនឹងសម្រេចបានគោលបំណងទាំងនេះដោយធ្វើការប្រើប្រាស់ទាំងស្រុងនូវរដ្ឋធម្មនុញ្ញរបស់ខ្លួន កិច្ចប្រតិបត្តិការ និងធនធានថវិកា

រួមបញ្ចូលទាំងការប្រែប្រួលធនធាន និងការឧបត្ថម្ភពីខាងក្រៅដូចជា ការលើកទឹកចិត្តអង្គការអន្តរជាតិឯទៀតដែល អង្គការពលកម្មអន្តរជាតិបានបង្កើតឱ្យមានទំនាក់ទំនង ដោយអនុលោមទៅនឹងមាត្រា ១២ នៃរដ្ឋធម្មនុញ្ញ របស់ខ្លួន ក្នុងការគាំទ្រនូវកិច្ចប្រឹងប្រែងទាំងនេះ :

ក- ដោយការផ្តល់កិច្ចសហប្រតិបត្តិការបច្ចេកទេស និងផ្តល់ការណែនាំក្នុងការជំរុញការផ្តល់សច្ចាប័ន និងការប្រតិបត្តិនូវអនុសញ្ញាគ្រឹះ ។

ខ- ដោយការជួយឧបត្ថម្ភសមាជិកទាំងឡាយនោះ ដែលពុំទាន់មានជំហរក្នុងការផ្តល់សច្ចាប័នលើអនុសញ្ញាខ្លះ ឬ អនុសញ្ញាទាំងអស់នេះនៅក្នុងកិច្ចប្រឹងប្រែងរបស់ខ្លួនក្នុងការជំរុញ និងធ្វើឱ្យជាក់ស្តែងនូវគោលការណ៍ទាក់ទងទៅនឹងសិទ្ធិគ្រឹះដែលជាបទបញ្ញត្តិនៃអនុសញ្ញាទាំងនោះ និង

គ- ដោយការជួយសមាជិកទាំងឡាយនៅក្នុងកិច្ចប្រឹងប្រែងរបស់ខ្លួន ក្នុងការបង្កើតឱ្យមានបរិយាកាសមួយ ដើម្បីការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម ។

៤- ប្តេជ្ញាថាផ្តល់អានុភាពពេញលេញចំពោះសេចក្តីថ្លែងការណ៍នេះការជំរុញការពិនិត្យតាមដានបន្ត ដែលមានសារៈសំខាន់ និងប្រកបដោយប្រសិទ្ធភាព ត្រូវអនុវត្តស្របទៅនឹងវិធានការណ៍ដែលបានកំណត់ទៅក្នុងឧបសម្ព័ន្ធដែលមាននៅទីនេះ ហើយដែលត្រូវបានចាត់ទុកថាជាផ្នែកទាំងមូលនៃសេចក្តីថ្លែងការណ៍នេះ ។

៥- បញ្ជាក់ថា មាត្រដ្ឋាន(ខ្នាតគំរូ) ការងារមិនត្រូវបានប្រើប្រាស់សម្រាប់គោលដៅធ្វើពាណិជ្ជកម្មឡើយ និងថាគ្មានបទបញ្ញត្តិណាមួយនៃសេចក្តីថ្លែងការណ៍ និងការពិនិត្យតាមដានសេចក្តីថ្លែងការណ៍នេះត្រូវបានប្រើប្រាស់ក្នុងគោលបំណងបែបនេះឡើយ ។

ឧបសម្ព័ន្ធ

សេកម្មភាពបន្តចំពោះសេចក្តីថ្លែងការណ៍

I .គោលបំណងរួម

១-គោលបំណងនៃការតាមដានបន្តបានរៀបរាប់ខាងក្រោមគឺ ជាការលើកទឹកចិត្ត ធ្វើឱ្យមានកិច្ចប្រឹងប្រែងរបស់សមាជិកនៃអង្គការក្នុងការជំរុញគោលការណ៍គ្រឹះ និងសិទ្ធិដែលបានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃអង្គការពលកម្មអន្តរជាតិ និងសេចក្តីថ្លែងការណ៍នៃ Philadelphia និងការអះអាងជាថ្មីនៅក្នុងសេចក្តីថ្លែងការណ៍នេះ។

២-ក្នុងការទាញភ្ជាប់ទៅនឹងគោលដៅនេះ ដែលជាប្រភេទនៃការជំរុញគាំទ្រដ៏ម៉ឺត់ចត់ ការពិនិត្យតាមដាននេះនឹងអនុញ្ញាតឱ្យឃើញនូវផ្នែកដែលជំនួយឧបត្ថម្ភរបស់អង្គការ តាមរយៈសកម្មភាពសហប្រតិបត្តិការបច្ចេកទេសអាចបង្ហាញឱ្យឃើញនូវផលប្រយោជន៍ចំពោះសមាជិករបស់ខ្លួន ក្នុងការជួយឱ្យពួកគេអនុវត្តនូវសិទ្ធិ និងគោលការណ៍គ្រឹះទាំងឡាយ។ មិនមែនជាការដាក់ជួសដោយបង្កើតជារបៀបអ្នកត្រួតត្រា ឬធ្វើឱ្យមាន ការរារាំង បង្អាក់នូវតួនាទីរបស់ពួកគេឡើយ ហេតុនេះហើយស្ថានភាពជាក់លាក់ស៊ីជំរៅនៃរបៀបទាំងនោះមិនត្រូវបានពិនិត្យ ឬពិនិត្យឡើងវិញនៅក្នុងក្របខណ្ឌការងារនៃការពិនិត្យតាមដាននេះឡើយ។

៣-ទិដ្ឋភាពពីរនៃការពិនិត្យតាមដាននេះ បានរៀបរាប់ខាងក្រោមត្រូវបានជាមូលដ្ឋានគ្រឹះស្តីពីនីតិវិធីដែលមាន : ការពិនិត្យតាមដានប្រចាំឆ្នាំអំពី ការមិនផ្តល់សច្ចាប័នអនុសញ្ញាគ្រឹះ នឹងត្រូវឱ្យគ្រាន់តែយកលំនាំតាមការបង្ហាញនូវបែបបទខ្លះនៃសំណើដែលមានក្នុងមាត្រា១៩ កថាខណ្ឌ៥(ង) នៃរដ្ឋធម្មនុញ្ញ និង របាយការណ៍សរុប នឹងជួយឱ្យបានលទ្ធផលប្រសើរពីនីតិវិធីដែលអនុវត្តតាមរដ្ឋធម្មនុញ្ញ។

II .សេកម្មភាពបន្តប្រចាំឆ្នាំ ពាក់ព័ន្ធនឹងការមិនផ្តល់សច្ចាប័នលើអនុសញ្ញាគ្រឹះ

ក- គោលបំណង និងវិសាលភាព

១- គោលបំណងគឺការផ្តល់ឱកាសក្នុងការពិនិត្យឡើងវិញជារៀងរាល់ឆ្នាំ ក្នុងន័យធ្វើឱ្យងាយស្រួលនូវនីតិវិធីក្នុងការដាក់ជំនួសការពិនិត្យឡើងវិញបួនឆ្នាំម្តង ដែលបានបង្ហាញដោយស្ថាប័នគ្រប់គ្រងក្នុងឆ្នាំ ១៩៩៥ កិច្ចប្រឹងប្រែងដែលធ្វើឡើងដោយអនុលោមទៅនឹងសេចក្តីថ្លែងការណ៍របស់សមាជិកដែលពុំទាន់ បានផ្តល់សច្ចាប័នលើអនុសញ្ញាគ្រឹះទាំងអស់ ។

២-ការពិនិត្យតាមដាននឹងធ្វើរៀងរាល់ឆ្នាំដោយគ្របដណ្តប់លើបួនផ្នែកនៃគោលការណ៍គ្រឹះ និងសិទ្ធិដែលបានកំណត់នៅក្នុងសេចក្តីថ្លែងការណ៍។

ខ-បែបបទ

១- ការពិនិត្យតាមដាន នឹងផ្តែកទៅលើរបាយការណ៍ដែលបានស្នើសុំពីសមាជិកទាំងឡាយនៅក្រោមមាត្រា ១៩កថាខណ្ឌ៥(ង) នៃរដ្ឋធម្មនុញ្ញ។ ទម្រង់របាយការណ៍នឹងបានប្រើប្រាស់ដើម្បីនឹងបានទទួលព័ត៌មានពីរដ្ឋាភិបាលទាំងឡាយដែលពុំបានផ្តល់សច្ចាប័នលើអនុសញ្ញាត្រឹមមួយ ឬច្រើន ស្តីពីការផ្លាស់ប្តូរទាំងឡាយ ដែលអាចដាក់នៅក្នុងច្បាប់ និងការអនុវត្តន៍របស់ពួកគេដោយយោងទៅលើមាត្រា២៣នៃរដ្ឋធម្មនុញ្ញ និង បើកឱ្យមានការអនុវត្តន៍។

២- របាយការណ៍ទាំងនេះ ដែលបានប្រមូលចងក្រងដោយការិយាល័យនឹងត្រូវបានពិនិត្យឡើងវិញដោយស្ថានប័ន្ធគ្រប់គ្រង ។

៣-ជាមួយនឹងគំនិតយោបល់ក្នុងការបង្ហាញការណែនាំនៅក្នុងរបាយការណ៍ដែលបានចងក្រងដូចនេះ ត្រូវយកចិត្តទុកដាក់លើទិដ្ឋភាពមួយចំនួនដែលអាចទាមទារឱ្យមានការពិនិត្យ ពិភាក្សាស៊ីជម្រៅក្នុងគោលដៅនេះ ការិយាល័យអាចបង្គាប់ឱ្យធ្វើការតែងតាំងអ្នកឯកទេសមួយក្រុមដោយស្ថាប័នគ្រប់គ្រង។

៤-ការសម្រួលឱ្យសមរម្យចំពោះស្ថាប័នគ្រប់គ្រងដែលមានទីតិវិធី អាចត្រូវបានពិនិត្យអនុញ្ញាតឱ្យសមាជិកទាំងឡាយដែលមានតំណាងនៅក្នុងការរៀបចំស្ថាប័នគ្រប់គ្រងក្នុងវិធីសមរម្យបំផុតអាចធ្វើការបញ្ជាក់ដែលអាចបង្ហាញឱ្យឃើញនូវភាពចាំបាច់ឬ ផលប្រយោជន៍ក្នុងកំឡុងពេលដែលស្ថាប័នគ្រប់ក្រងធ្វើការពិភាក្សា ដើម្បីបំពេញបន្ថែមនូវព័ត៌មានទៅក្នុងរបាយការណ៍របស់ខ្លួន។

III.**របាយការណ៍រួម**

ក- គោលបំណង និងវិសាលភាព

១. គោលបំណងនៃរបាយការណ៍នេះគឺផ្តល់នូវថាមវន្តក្នុងការពិពណ៌នាទាក់ទងទៅនឹងផ្នែកនីមួយៗ នៃគោលការណ៍គ្រឹះ និងសិទ្ធិដែលបានកំណត់ក្នុងកំឡុងនៃរយៈពេលបួនឆ្នាំមុន និងទុកជាមូលដ្ឋាននៃការប៉ាន់ប្រមាណវាយតម្លៃនូវប្រសិទ្ធភាពនៃជំនួយឧបត្ថម្ភ ដែលផ្តល់ឱ្យដោយអង្គការ និង ដើម្បីកំណត់អាទិភាពសម្រាប់រយៈពេលបន្តទៀតនៅក្នុងការបង្កើតផែនការសកម្មភាព ដើម្បីរៀបចំកិច្ចសហប្រតិបត្តិការបច្ចេកទេស ជាពិសេសក្នុងការប្រមែប្រមូលធនធានដែលចាំបាច់ខាងក្នុង និងខាងក្រៅដើម្បីអនុវត្ត។

២. របាយការណ៍ នឹងគ្របដណ្តប់លើផ្នែកមួយក្នុងផ្នែកបួននៃគោលការណ៍គ្រឹះ និងសិទ្ធិជារៀងរាល់ឆ្នាំតាមលំដាប់។

ខ- បែបបទ

១. របាយការណ៍ នឹងប្រើប្រាស់នៅក្រោមការទទួលខុសត្រូវរបស់អគ្គនាយកដោយផ្អែកលើព័ត៌មានជាផ្លូវការ ឬការប្រមែប្រមូលព័ត៌មាន និងការប៉ាន់ប្រមាណវាយតម្លៃដោយស្របទៅនឹងនីតិវិធីដែលបានបង្កើតឡើង។ ក្នុងករណីដែលរដ្ឋជាភាគីពុំបានផ្តល់សច្ចាប័នលើអនុសញ្ញាគ្រឹះ របាយការណ៍នឹងកសាងឡើង ជាពិសេសដោយផ្អែកលើលទ្ធផលនៃការពិនិត្យតាមដានប្រចាំឆ្នាំដែលបានធ្វើរួចហើយ។ ក្នុងករណីសមាជិកដែលបានផ្តល់សច្ចាប័នលើអនុសញ្ញាគ្រឹះ ហើយរបាយការណ៍នឹងកសាងឡើងដោយពិស្តារផ្អែកលើរបាយការណ៍ទាំងឡាយដែលទាក់ទងទៅនឹងមាត្រា ២២នៃរដ្ឋធម្មនុញ្ញ។

២. របាយការណ៍នេះនឹងបានដាក់ជូនទៅសន្និសីទសម្រាប់ត្រីភាគីជារបាយការណ៍នៃអគ្គនាយក។ សន្និសីទអាចញែកការបែងចែករបាយការណ៍នេះចេញពីរបាយការណ៍ទាំងឡាយ ដែលនៅក្នុងមាត្រា ១២នៃគណៈអចិន្ត្រៃយ៍របស់ខ្លួន និងអាចធ្វើការពិភាក្សាដោយភក្តីពេញលេញទៅនឹងរបាយការណ៍នេះ ឬក្នុងមធ្យោ បាយផ្សេងទៀតដ៏សមរម្យ ។បន្ទាប់មកសម្រាប់ស្ថាប័នគ្រប់គ្រងនាសម័យប្រជុំដំបូងនឹងទាញជាសេចក្តីសន្និដ្ឋានពីការពិភាក្សានេះ ដែលទាក់ទងទៅនឹងអាទិភាព និងផែនការសកម្មភាពសម្រាប់កិច្ចសហប្រតិបត្តិការបច្ចេកទេស ដើម្បីអនុវត្តសម្រាប់រយៈពេល ៤ឆ្នាំបន្តទៀត។

IV. **សកម្មភាពបន្តគឺ** :

១- សំណើទាំងឡាយត្រូវធ្វើឡើងដោយមានត្រានៃច្បាប់ក្នុងគណៈអចិន្ត្រៃនៃស្ថាប័នគ្រប់គ្រង និងសន្និសីទដែលត្រូវបានឱ្យអនុវត្តនូវបទបញ្ញត្តិមុនដែលផ្តល់ឱ្យ។

២- សន្និសីទត្រូវធ្វើការពិនិត្យឡើងវិញនូវកិច្ចប្រតិបត្តិការនៃការពិនិត្យតាមដាននេះ ដោយគិតទៅដល់បទពិសោធន៍ ដែលឱ្យមានក្នុងការប៉ាន់ប្រមាណវាយតម្លៃទោះជាបំពេញដោយភាពច្បាស់លាស់គ្រប់គ្រាន់នូវគោលដៅទាំងមូលក្នុងភាគ I ។

នៅខាងមុខជាសេចក្តីថ្លែងការណ៍របស់អង្គការពលកម្មអន្តរជាតិស្តីពីគោលការណ៍គ្រឹះ និងសិទ្ធិក្នុងការងារ និងការពិនិត្យតាមដាននូវសេចក្តីថ្លែងការណ៍នេះបានអនុម័តត្រឹមត្រូវដោយសន្និសិទ្ធិសកល នៃអង្គការពលកម្មអន្តរជាតិនៅកំឡុងសម័យប្រជុំទី៨៦ ដែលបានធ្វើឡើងនៅទីក្រុងហ្សឺណែវ និងបានបិទប្រកាសនៅថ្ងៃទី ១៨ ខែមិថុនា ឆ្នាំ១៩៩៨។

នៅក្នុងជំនឿទុកចិត្តតាំងពីពេលនេះយើងបានបន្ថែមហត្ថលេខារបស់យើងនៅថ្ងៃទី១៩ ខែ មិថុនា ឆ្នាំ ១៩៩៨នេះ។

ប្រធានសន្និសីទអគ្គនាយកនៃការិយាល័យពលកម្មអន្តរជាតិ

គណៈកម្មការជីកឆាំ និងគ្រប់គ្រង

១_លោក ភុង ហានស៊ីន	ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
២_លោក តូច ជឿន	អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៣_លោក គួច គូលំអ	អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៤_លោក ចាប គីមជុន	អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៥_លោក ណុប ទីម	ជំនួយការនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

គណៈកម្មការរៀបរៀង និងចងក្រង

១_លោក ភុង ហានស៊ីន	ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
២_លោក តូច ជឿន	អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៣_លោក គួច គូលំអ	អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៤_លោក ចាប គីមជុន	អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៥_លោក ណុប ទីម	ជំនួយការនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៦_លោក ឡង់ សុផាត	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

គណៈកម្មការបកប្រែ

១_លោកស្រី កង សុថាវី	ប្រធានការិយាល័យក្រោយអក្ខរកម្ម	២_លោកស្រី តុប ប៊ុនថា	ប្រធានការិយាល័យអក្ខរកម្ម
៣_លោក ព្ញ៉ែម ភីណារ៉ែត	អនុប្រធានការិយាល័យរដ្ឋបាល	៤_លោក តេះ ដារី	អនុប្រធានការ.ផែនការនិងគ្រប់គ្រងទិន្នន័យ
៥_លោក ជិន និវត្តន៍	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ	៦_លោកស្រី ទី វត្តី	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៧_លោក ភូ យន់	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ	៨_លោកស្រី ស្រ៊ុន ម៉ាទី	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៩_កញ្ញា អ៊ុក ធារី	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ	១០_លោក គ្រួច លក្ខិណា	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
១១_លោកស្រី លី ខេង	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ		

គណៈកម្មការផ្ទៀងផ្ទាត់

១_លោក សំ ចាន់ទិត	អនុប្រធានការិយាល័យអក្ខរកម្ម	២_លោក រង់ សូវង្ស	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៣_លោក ឈុំ ច័ន្ទមុនីរ៉ែត	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ	៤_លោកស្រី ជា សុផល	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៥_លោក កែវ គង់	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ	៦_កញ្ញា ម៉ៅ ផល្លី	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ
៧_លោកស្រី ស្រ៊ុន ម៉ាទី	មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ		

គណៈកម្មការឌីហ្សាញ និងកុំព្យូទ័រ

១_លោក ឈិន វិត	ប្រធានការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន
២_លោក ពេជ្រ និពន្ធ	មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន
៣_លោកស្រី ឈុំ សោភ័ណ	មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន
៤_លោកស្រី សួច ផាន់ណា	មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន
៥_លោកស្រី ទី វ៉ាដា	មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន
៦_កញ្ញា សន សុម៉ាលី	មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន

✕ បញ្ឈប់ពលកម្មកុមារ

Stop Child Labour

Supporting Children's Rights through Education, the Arts and the Media (SCREAM)

សូមថ្លែងអំណរគុណ

- ដល់អង្គការពលកម្មអន្តរជាតិ (ILO) ដែលបានជួយឧបត្ថម្ភថវិកា ក្នុងការបកប្រែ រៀបរៀង និងបោះពុម្ព។
- ចំពោះលោក **មេនណាធីរ៉ែ ចុំលេ យូសេហ្វ** ប្រធានទីប្រឹក្សាបច្ចេកទេស និងលោក **ថេង ឧត្តរិន្ទ** មន្ត្រីកម្មវិធីនៃ *អង្គការពលកម្មអន្តរជាតិ* (ILO) កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ (IPEC) គាំទ្រកម្មវិធីពេលវេលាកំណត់ (TBP SP) នៅកម្ពុជាដែលបានជួយផ្តល់ការណែនាំផ្សេងៗនិងការគាំទ្របច្ចេកទេស ព្រមទាំងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងនេះ ដើម្បី **ស្ក្រីម** (SCREAM) កើតមានឡើងនៅកម្ពុជា។

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ យុវជន និងកីឡា តាមសេចក្តីប្រកាស
លេខ 101 អយក ប្រក ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៦

នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ : លេខ ១៦៨ មហាវិថីព្រះនរោត្តម សង្កាត់បឹងកេងកង១
ខណ្ឌ ចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទលេខ : ០២៣ ៧២៦ ៥៦៣ / ២១៩ ២៥៨

Email : nfe@camnet.com.kh

ISBN-9789995088217